ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥

**បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

ក្នុងសម័យប្រជុំអាណត្តិទី១ លើកទី២៥ នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១០ ខែកក្កដា គ.ស.២០២៥


រៀបចំដោយ
**និយ័តករមូលបត្រកម្ពុជា**

*"ជំរុញការអភិវឌ្ឍវិស័យមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ តម្លាភាព ជវភាព ភាពធន់ បរិយាបន្ន និរន្តរភាព និងនវានុវត្តន៍ សំដៅចូលរួមលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ក្នុងបរិបទប្រក្រតីភាពថ្មី"*

**រៀបចំដោយ និយ័តករមូលបត្រកម្ពុជា**

**ខែកក្កដា ឆ្នាំ២០២៥**

# អារម្ភកថា

ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជានៃបញ្ហាភូមិសាស្ត្រនយោបាយ ជំងឺរាតត្បាត និងគ្រោះមហន្តរាយក្នុងគន្លងប្រក្រតីភាពថ្មី កម្ពុជា, ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងមុតស្រួចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រ កម្ពុជាក្នុងនីតិកាលអាណត្តិកន្លងទៅ** និងក្រោមការបន្តវេនដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** នៅតែអាចរក្សាបាននូវស្ថិរភាពនយោបាយ ភាពរីកចម្រើនសហគមន៍ និងកំណើនសេដ្ឋកិច្ចដ៏ល្អប្រសើរបើធៀបនឹងប្រទេស មួយចំនួនក្នុងតំបន់។ សមិទ្ធផលដ៏មានតម្លៃទាំងនេះ កើតចេញពីការដឹកនាំប្រកបដោយភាពប៉ិនប្រសប់ និងការត្រៀមខ្លួនទុកមុនជាស្រេច តាមរយៈការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍជាតិសំខាន់ៗ និងបានអនុវត្ត ដោយជោគជ័យ ដូចជាយុទ្ធសាស្ត្រត្រីកោណ, យុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០១-២០១០ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ និងចុងក្រោយទៅជា យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០។ ជាមួយនឹងការកសាងនូវគ្រឹះនយោបាយ និងសេដ្ឋកិច្ចដ៏រឹងមាំនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅដឹកនាំនាំកម្ពុជាឆ្លងកាត់បង្គោលចរនៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងប្រែក្លាយទៅជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ព្រមទាំងបានប្តេជ្ញាសម្រេចឱ្យបាននូវអព្យាក្រឹត្យកាបូននៅឆ្នាំ២០៥០។ ដើម្បីគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមភាព ប្រសិទ្ធភាព និងចីរភាព ហើយគោលដៅមូលដ្ឋាននៃយុទ្ធសាស្ត្រនេះ គឺជានាកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ។

សកម្មភាពសេដ្ឋកិច្ចរបស់កម្ពុជា ត្រូវបានជំរុញដោយការស្តារឡើងវិញ និងការពង្រឹងវិស័យសំខាន់ៗ ដូចជាវិស័យកាត់ដេរ ផលិតកម្មដែលផ្តោតលើការនាំចេញ និងវិស័យទេសចរណ៍ ព្រមទាំងការពង្រីកទៅដល់វិស័យថ្មីៗដូចជាថាមពលកកើតឡើងវិញ និងអាជីវកម្មកសិកម្មដែលមានតម្លៃបន្ថែមខ្ពស់។ ក្នុងរយៈពេលមធ្យមទៅវែង គឺទាមទារជាចាំបាច់នូវការវិនិយោគសំខាន់ៗដើម្បីសម្រេចនូវចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ ២០៥០។ យោងតាមយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣ បានប៉ាន់ស្មានថាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តោតសំខាន់លើគម្រោងដឹកជញ្ជូន និងភស្តុភារ មានតម្រូវការវិនិយោគសរុបប្រមាណជា ៣៧ ប៊ីលានដុល្លារអាម៉េរិក។ លើសពីនេះ ដើម្បីសម្រេចបាននូវអព្យាក្រឹត្យកាបូននៅឆ្នាំ២០៥០ កម្ពុជាត្រូវការការចូលរួមពីវិស័យឯកជនប្រមាណ ១,៤ ប៊ីលានដុល្លារអាម៉េរិក។

វិស័យមូលបត្រ ដែលមានមុខងារក្នុងការសម្រួលដល់ការកៀរគរមូលធន បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន

នូវចក្ខុវិស័យជាយុទ្ធសាស្ត្រ។ អាស្រ័យហេតុនេះ វាពិតជាមានភាពចាំបាច់ដែលត្រូវធានាឱ្យបាននូវការអភិវឌ្ឍវិស័យមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ភាពធន់ ជវភាព បរិយាបន្ន និរន្តរភាព និងនវានុវត្តន៍ តាមរយៈការដាក់ចេញនូវ**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** ដែលមានភាពគ្រប់ជ្រុងជ្រោយ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ នឹងបង្ហាញពីក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រនិងពង្រីកទីផ្សារមូលបត្រ ដែលរួមបញ្ចូលទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងហិរញ្ញវត្ថុចីរភាព និងគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ។ បច្ចេកវិទ្យាហិរញ្ញវត្ថុ និងហិរញ្ញវត្ថុចីរភាព ជាធាតុគ្រឹះដែលគាំទ្រដោយផ្ទាល់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងនវានុវត្តន៍ ដូចដែលបានកំណត់នៅក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០, យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹត្យកាបូន, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨, យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ក៏រួមបញ្ចូលផងដែរនូវសកម្មភាពជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដែលបានចូលរួមចំណែកនៅក្នុងការបង្កើតការងារប្រមាណ ៧០% និងរួមចំណែកនៅក្នុងផលិតផលក្នុងស្រុកសរុបប្រមាណជា ៦០% ដោយគិតគូរទៅលើការបំពេញនូវតម្រូវការហិរញ្ញវត្ថុ និងផ្តល់នូវជម្រើសហិរញ្ញប្បទានផ្សេងៗ ដែលអាចឆ្លើយតបនឹងលក្ខខណ្ឌ និងស្ថានភាពផ្សេងៗគ្នារបស់សហគ្រាសទាំងនោះ។

ដោយភាពប្រទាក់ក្រឡាគ្នារវាងសេដ្ឋកិច្ច ធុរកិច្ច និងវិស័យហិរញ្ញវត្ថុ ដូចនេះវាពិតជាចាំបាច់ដែលត្រូវមានអភិក្រមនៃកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីអភិវឌ្ឍវិស័យមូលបត្រ។ ភាគីពាក់ព័ន្ធទាំងអស់ ទាំងវិស័យសាធារណៈ និងវិស័យឯកជន ត្រូវយល់អំពីសារៈសំខាន់នៃវត្តមានរបស់វិស័យមូលបត្រ ថាជាវិស័យដែលមានភាពរស់រវើក និងភាពធន់ ចំពោះប្រទេសកម្ពុជា ដោយហេតុថាវិស័យនេះមិនត្រឹមតែគាំទ្រដល់សកម្មភាពធុរកិច្ច និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងបង្កើតនូវឥទ្ធិពលជាវិជ្ជមានដល់ប្រជាជនទូទៅ ផងដែរ។ អាស្រ័យហេតុនេះ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ នេះ គឺទាមទារនូវកិច្ចសហការយ៉ាងជិតស្និទ្ធ និងរស់រវើកនៅគ្រប់កម្រិតទាំងអស់។

ជារួម **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** ជាឯកសារយុទ្ធសាស្ត្រដ៏សំខាន់មួយដែលនឹងគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ របស់កម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ តាងនាមក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រសួង-ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកនៅក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ តាមរយៈការចែករំលែកនូវគំនិតយោបល់ និងសំណូមពរនានា។ ភាពចម្រុះនៃទស្សនៈ និងបទពិសោធន៍របស់ភាគីពាក់ព័ន្ធ បានធ្វើឱ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍

វិស័យមូលបត្រនេះ កាន់តែមានភាពមុតស្រួចដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ទីផ្សារ និងវិស័យទាំងមូល។ ខ្ញុំសូមសម្តែងនូវមូលវិចារកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) ក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រដ៏សំខាន់នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំបច្ចេកទេសនៃ **អ.ស.ហ.** និងជាពិសេស **ឯកឧត្តម ស៊ូ សុជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ ន.ម.ក.** ព្រមទាំងក្រុមការងារបច្ចេកទេសដែលបានខិតខំតាក់តែង សម្រិតសម្រាំង និងរៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ។

ជាទីបញ្ចប់ ខ្ញុំក៏សូមអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ គាំទ្រ និងចូលរួមអនុវត្តយុទ្ធសាស្ត្រនេះទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដើម្បីជានាបានថាវិធានការយុទ្ធសាស្ត្រមិនត្រឹមតែអាចអនុវត្តបានពេញលេញនោះទេ តែថែមទាំងផ្តល់នូវលទ្ធផលគួរជាទីគាប់ចិត្ត និងមោទនៈ។

ថ្ងៃពុធ ៦ រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកានុក្រម


**អារម្ភកថា** ..... ២

**បញ្ជីឈ្មោះអក្សរកាត់** ..... ៧

**ខ្លឹមសារសង្ខេប** ..... ៩

**ជំពូកទី១៖ សេចក្តីផ្តើម** ..... ១១

**១.១. ស្ថានភាពសេដ្ឋកិច្ច** ..... ១១

**១.២. វិស័យមូលបត្រ** ..... ១១

**១.៣. ផែនការ និងយុទ្ធសាស្ត្រជាតិ** ..... ១៨

**ជំពូកទី២៖ ការវិភាគអំពីស្ថានភាពនៃវិស័យមូលបត្រនៅកម្ពុជា** ..... ២០

**២.១. ការវិភាគអំពីភាពខ្លាំង** ..... ២១

**២.២. ការវិភាគអំពីភាពខ្សោយ** ..... ២២

**២.៣. ការវិភាគអំពីកាលានុវត្តភាព** ..... ២២

**២.៤. ការវិភាគអំពីការគំរាម** ..... ២៣

**ជំពូកទី៣៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ** ..... ២៨

**៣.១. ចក្ខុវិស័យ គោលបំណង និងគោលដៅ** ..... ២៨

៣.១.១. ចក្ខុវិស័យ ..... ២៨

៣.១. ២. គោលបំណង ..... ២៨

៣.១. ៣. គោលដៅ ..... ២៨

**៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះ** ..... ២៩

៣.២.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រ ..... ២៩

៣.២.១.១. វិធានការយុទ្ធសាស្ត្រពង្រឹងការបោះផ្សាយលក់មូលបត្រ និងការធ្វើពិពិធកម្មផលិតផល និងសេវា ..... ២៩

៣.២.១.២. វិធានការយុទ្ធសាស្ត្រពង្រឹងមូលដ្ឋានវិនិយោគិន និងប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ.. ៣០
៣.២.១.៣. វិធានការយុទ្ធសាស្ត្រពង្រឹងសណ្ដាប់ធ្នាប់ទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ............ ៣១
៣.២.១.៤. វិធានការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពទីផ្សារ........................................... ៣២
៣.២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រីកទីផ្សារមូលបត្រ................................................. ៣២
៣.២.២.១. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍហិរញ្ញវត្ថុចីរភាព............................................ ៣២
៣.២.២.២. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបច្ចេកវិទ្យាឌីជីថល ............ ៣៣
៣.២.២.៣. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ........................................ ៣៥
៣.២.២.៤. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌត្រួតពិនិត្យ ...................................... ៣៥
៣.២.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ ...................................... ៣៦
៣.២.៣.១. វិធានការយុទ្ធសាស្ត្រកសាងសមត្ថភាព លើកកម្ពស់ចំណេះដឹង និងអភិវឌ្ឍសមត្ថភាព៣៦
៣.២.៣.២. វិធានការយុទ្ធសាស្ត្រគ្រប់គ្រង និងវិភាគទិន្នន័យ ......................................... ៣៨
៣.២.៣.៣. វិធានការយុទ្ធសាស្ត្រសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងចែករំលែកធនធាន ..... ៣៨
៣.២.៣.៤. វិធានការយុទ្ធសាស្ត្រពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ.................. ៣៩
៣.២.៣.៥. វិធានការយុទ្ធសាស្ត្រពង្រឹង និងពង្រីកសមត្ថភាពក្នុងការអនុវត្ត........................ ៣៩
**ជំពូកទី៤៖ យន្តការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ**........................................ ៤០
**៤.១. យន្តការអនុវត្ត**........................................ ៤០
**៤.២. យន្តការត្រួតពិនិត្យ និងវាយតម្លៃ**........................................ ៤០
**ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន** ........................................ ៤២
**បរិសិដ្ឋ៖ ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥**............... ៤៣

# បញ្ជីឈ្មោះអក្សរកាត់

| ល.រ. | អក្សរកាត់ | អក្សរពេញ |
|---|---|---|
| ១ | គ.អ.ប.ក. | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា |
| ២ | ផមក | ផ្សារមូលបត្រកម្ពុជា |
| ៣ | ផសស | ផលិតផលក្នុងស្រុកសរុប |
| ៤ | ន.ម.ក. | និយ័តករមូលបត្រកម្ពុជា |
| ៥ | អ.ស.ហ. | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| ៦ | ABMF | ASEAN+3 Bond Market Forum - វេទិកាទីផ្សារសញ្ញាបណ្ណអាស៊ាន+៣ |
| ៧ | ABMI | ASEAN Bond Market Initiatives - គំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ី |
| ៨ | ACMF | ASEAN Capital Markets Forum - វេទិកាទីផ្សារមូលធនអាស៊ាន |
| ៩ | CIS | Collective Investment Scheme - គម្រោងវិនិយោគរួម |
| ១០ | DeFi | Decentralized Finance - ហិរញ្ញវត្ថុវិមជ្ឈការ |
| ១១ | ETF | Exchange-Traded Fund - មូលនិធិដែលអាចជួញដូរបាន |
| ១២ | FinTech | Financial Technology - បច្ចេកវិទ្យាហិរញ្ញវត្ថុ |
| ១៣ | IOSCO | International Organization of Securities Commissions - អង្គការគណៈកម្មការមូលបត្រអន្តរជាតិ |
| ១៤ | IPO | Initial Public Offering - ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង |
| ១៥ | MDB | Multilateral Development Bank - ធនាគារអភិវឌ្ឍន៍ពហុភាគី |
| ១៦ | ODA | Official Development Assistance - ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| ១៧ | RegTech | Regulatory Technology - បច្ចេកវិទ្យានិយ័តកម្ម |
| ១៨ | REIT | Real Estate Investment Trusts - បរធនបាលវិនិយោគអចលនវត្ថុ |
| ១៩ | SLC | Senior Level Committee - គណៈកម្មាធិការកម្រិតខ្ពស់អាស៊ាន |
| ២០ | SoE | State-Owned Enterprise - សហគ្រាសសាធារណៈ |
| ២១ | SupTech | Supervisory Technology - បច្ចេកវិទ្យាត្រួតពិនិត្យ |
| ២២ | SWOT | Strength, Weakness, Opportunities and Threats - ភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និងការគំរាម |

| | | |
|---|---|---|
| ២៣ | WC-CAL | Working Committee on Capital Account Liberalisation - គណៈកម្មាធិការការងារសេរីភាវូបនីយកម្មគណនីមូលធនអាស៊ាន |
| ២៤ | WC-CMD | Working Committee on Capital Market Development - គណៈកម្មាធិការការងារអភិវឌ្ឍន៍ទីផ្សារមូលធនអាស៊ាន |
| ២៥ | WC-FSL | Working Committee on Financial Services Liberalisation - គណៈកម្មាធិការការងារសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន |

# ខ្លឹមសារសង្ខេប

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានហេតុការណ៍សំខាន់ៗជាច្រើនបានកើតឡើងនៅទូទាំងពិភពលោក ដូចជាបញ្ហាជម្លោះ និងភាពតានតឹងនៃភូមិសាស្ត្រនយោបាយ សង្គ្រាមពាណិជ្ជកម្ម ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកាន់តែអាក្រក់ឡើង និងជំងឺរាតត្បាតកូវីដ១៩ជាដើម។ ព្រឹត្តិការណ៍ទាំងនេះបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចមានភាពមិនប្រាកដប្រជាក្នុងរយៈពេលយូរ ដែលកើតឡើងពីការកាត់ផ្តាច់ខ្សែសង្វាក់ផ្គត់ផ្គង់ សកម្មភាពធុរកិច្ច ការងារ និងកត្តាផ្សេងៗទៀត។ ខណៈដែលកត្តាមួយចំនួនកំពុងបង្ហាញពីសញ្ញាណនៃការងើបឡើងវិញ ក៏មានកត្តាមួយចំនួនផ្សេងទៀតនៅតែបន្ត ឬធ្លាក់ទៅក្នុងស្ថានភាពកាន់តែអាក្រក់ឡើង ថែមទាំងប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់សេដ្ឋកិច្ចសកល។ ក្នុងពេលជាមួយគ្នានេះ កាលានុវត្តភាពថ្មីៗក៏បានលេចឡើង រួមមាន ការធ្វើអន្តរកាលឆ្ពោះទៅចីរភាព និងការធ្វើឌីជីថលូប-នីយកម្ម។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍក្នុងស្រុកតាមរយៈការដាក់ចេញនូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធ កំពុងបង្កើតនូវកាលានុវត្តភាពជាច្រើនសម្រាប់សកម្មភាពផលិតក្នុងស្រុក ដែលអាចជំរុញកំណើនសេដ្ឋកិច្ចកម្ពុជារយៈពេលវែង។ ការណ៍នេះ ផ្តល់នូវឥទ្ធិពលជាវិជ្ជមានសម្រាប់វិស័យហិរញ្ញវត្ថុក៏ដូចជាសេដ្ឋកិច្ចទាំងមូល ជាពិសេសការកើនឡើងនូវតម្រូវការនៃការវិនិយោគ និងហិរញ្ញប្បទានសំខាន់ៗជាច្រើន ដើម្បីពង្រីកអាជីវកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ដូចនេះ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** ត្រូវបានរៀបចំឡើងក្នុងពេលវេលាដែលសមស្របបំផុត ដោយមានការវាយតម្លៃគ្រប់ជ្រុងជ្រោយអំពីភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម នៃវិស័យមូលបត្រ។ ដោយគិតគូរពិចារណាយ៉ាងល្អិតល្អន់នូវកត្តាទាំងនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ នឹងផ្តល់នូវដំណោះស្រាយសក្តានុពលចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងបញ្ហាប្រឈមដែលនឹងកើតឡើងនាពេលអនាគត ក៏ដូចជាការទាញយកផលប្រយោជន៍ពីកាលានុវត្តភាពនៃកំណើនថ្មីៗ ព្រមទាំងទប់ស្កាត់នូវបញ្ហា ឬបញ្ហាប្រឈមដែលនឹងអាចកើតឡើង នៅពេលដែលវិស័យមូលបត្រសម្រេចបាននូវការអភិវឌ្ឍក្នុងកម្រិតជាក់លាក់មួយនាពេលអនាគត។

ជារួម យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះផ្តោតលើក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះ ៣ ដូចខាងក្រោម៖

១. យុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រ៖ បង្កើតនូវសកម្មភាពផ្សេងៗ តាមរយៈការធ្វើពិពិធកម្មផលិតផល និងសេវានៅក្នុងទីផ្សារ ពង្រឹងមូលដ្ឋានវិនិយោគិន និងប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ ពង្រឹងសណ្តាប់ធ្នាប់ទីផ្សារ និងពង្រឹងប្រសិទ្ធភាពទីផ្សារ ដើម្បីរក្សាឱ្យបាននូវការអភិវឌ្ឍ និងការធ្វើនិយ័តកម្មវិស័យមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងយុត្តិធម៌។

២. យុទ្ធសាស្ត្រពង្រីកទីផ្សារមូលបត្រ៖ អភិវឌ្ឍបន្ថែមទៅលើកំណើនថ្មីៗ ដែលរួមមានហិរញ្ញវត្ថុចីរភាព បច្ចេកវិទ្យាហិរញ្ញវត្ថុ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអនុវត្តការងារ។

៣. យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ៖ កសាងសមត្ថភាព និងពង្រឹងនូវចំណេះដឹង ជំនាញ

និងធនធានរបស់ **ន.ម.ក.** និងបុគ្គលពាក់ព័ន្ធ ក៏ដូចជាដាក់ឱ្យអនុវត្តនូវដំណើរការ យន្តការ និងមធ្យោបាយសមស្របដើម្បីសម្រេចបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអភិវឌ្ឍទីផ្សារ។

ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះនេះ ផ្អែកលើបទពិសោធន៍ និងកិច្ចខិតខំប្រឹងប្រែងរបស់ **ន.ម.ក.** ក្នុងការបង្កើត និងអភិវឌ្ឍវិស័យមូលបត្ររយៈពេលជាង ១៥ ឆ្នាំមកនេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ ក៏បានគិតគូរពីឥទ្ធិពលឆ្លងវិស័យដែលអាចនឹងកើតឡើងជាមួយវិស័យហិរញ្ញវត្ថុផ្សេងៗទៀត ដូចជាវិស័យធនាគារ និងវិស័យធានារ៉ាប់រងជាដើម។

ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ គឺជាផែនការយុទ្ធសាស្ត្រថាមវន្តដែលនឹងត្រូវពិនិត្យឡើងវិញជាប្រចាំដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព និងអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍក្នុងរយៈពេល ១០ ឆ្នាំនេះ។

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. ស្ថានភាពសេដ្ឋកិច្ច

ក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាមានកំណើនផលិតផលក្នុងស្រុកសរុប (**ផសស**) ជាមធ្យមស្ថិតក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ។ គួរកត់សម្គាល់ថា ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ បន្ទាប់ពីការរាតត្បាតយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ **ផសស** របស់កម្ពុជាស្ថិតក្នុងទិសដៅកើន-ឡើង បើទោះបីអត្រាកំណើននេះទាបជាងកម្រិតមុនជំងឺកូវីដ-១៩ ក៏ដោយ។ កំណើននេះ មានការចូលរួមជាចម្បងពីវិស័យទេសចរណ៍ និងវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ដែលវិស័យទាំងនេះត្រូវបានរំពឹងថានឹងបន្តជំរុញសេដ្ឋកិច្ចកម្ពុជាតទៅមុខទៀត។ លើសពីនេះ ការស្ទុះងើបឡើងវិញនៃវិស័យកាត់ដេរសម្លៀក-បំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ នឹងក្លាយជាចលករជំរុញបន្ថែមដល់កំណើនសេដ្ឋកិច្ច។ **ផសស** របស់កម្ពុជាក្នុងឆ្នាំ ២០២៤ សម្រេចបានកំណើន ៦%។ ទោះបីជាស្ថិតក្នុងស្ថានភាពនៃភាពមិនប្រាកដប្រជាខ្ពស់ ដោយសារភាពតានតឹង, ការវិវត្តយ៉ាងរហ័ស និងពិបាកប៉ាន់ស្មានបាននៃស្ថានការណ៍ភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចជាសកល សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាមានកំណើនជាមធ្យមក្នុងរង្វង់ចន្លោះ ៥% ទៅ ៦% ក្នុងឆ្នាំ២០២៥ និងឆ្នាំ២០២៦។ កម្ពុជាបានដាក់ទិសដៅឆ្លងកាត់បង្គោលចរនៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្ពោះទៅឋានៈនៃប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច រយៈពេលវែងរបស់កម្ពុជា គឺទាមទារជាចាំបាច់នូវការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធសមស្រប ដែលត្រូវការសាច់ប្រាក់វិនិយោគសរុបប្រមាណ ៣៦,៦ ប៊ីលានដុល្លារអាមេរិក ក្នុងអំឡុងឆ្នាំ២០២៣-២០៣៣។ តម្រូវការសាច់ប្រាក់វិនិយោគដ៏ច្រើនបែបនេះ ត្រូវមានប្រភពហិរញ្ញប្បទានជាច្រើន ដែលទីផ្សារមូលបត្រជាប្រភពកៀរគរហិរញ្ញប្បទានដ៏សមស្របសម្រាប់គម្រោងនេះ។

## ១.២. វិស័យមូលបត្រ

វិស័យមូលបត្រនៅកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាង ១៥ ឆ្នាំមកនេះ ជាពិសេស ការរៀបចំបទប្បញ្ញត្តិ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងអន្តរការីមូលបត្រ។ **ន.ម.ក.** ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនក្នុងឆ្នាំ២០០៧ បានអនុវត្តគំនិតផ្តួចផ្តើមជាច្រើនក្នុងការអនុវត្តតួនាទីរបស់ខ្លួនលើការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ដែលរួមមាន៖ ការបង្កើតនិងការដាក់ចេញក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ការផ្តល់អាជ្ញាបណ្ណដល់អន្តរការីមូលបត្រ ការគ្រប់គ្រង ត្រួតពិនិត្យ និងឃ្លាំមើលទីផ្សារមូលបត្រ និងអ្នកចូលរួម ការលើកកម្ពស់ការយល់ដឹង និងការអប់រំវិនិយោគិន ជាដើម។ គិតត្រឹមឆ្នាំ២០២៤ **ន.ម.ក.** បានដាក់ចេញប្រកាស និងបទប្បញ្ញត្តិចំនួន ៨២ ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រ ដែលឆ្លើយតបនឹងតម្រូវការ និងបរិបទនៃវិស័យនេះ។

ហេដ្ឋារចនាសម្ព័ន្ធទីផ្សារដ៏សំខាន់ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ជាពិសេសផ្សារមូលបត្រកម្ពុជា (**ផមក**) ត្រូវបានបង្កើតឡើងដើម្បីជានាសណ្តាប់ធ្នាប់ប្រតិបត្តិការទីផ្សារ ព្រមជាមួយអន្តរការីមូលបត្រ

ជាច្រើន ដែលដើរតួនាទីក្នុងការបង្កើតនូវផលិតផល និងសេវាពាក់ព័ន្ធនឹងមូលបត្រ។ ទីផ្សារឧបករណ៍និស្សន្ទ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៦ បន្ទាប់ពីការអនុម័តដាក់ឱ្យប្រើប្រាស់ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ ដែលមានក្រុមហ៊ុនសមភាគីកណ្តាលជាអ្នកផ្តល់ថ្នាលជួញដូរ ឧបករណ៍និស្សន្ទ។ ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម ត្រូវបាន អនុម័តដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៨ និងប្រកាសស្តីពីការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោង វិនិយោគរួម ក្នុងឆ្នាំ២០២៣។ គិតត្រឹមឆ្នាំ២០២៤ **ន.ម.ក.** បានផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនគ្រប់គ្រង មូលនិធិចំនួន២ ធ្វើការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម។

បន្ថែមពីនេះ **ន.ម.ក.** បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ដល់អន្តរការីមូលបត្រ ជាច្រើនរួមមាន៖ ក្រុមហ៊ុនធានាទិញមូលបត្រ, ពាណិជ្ជករមូលបត្រ, ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ, ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ, ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ, ក្រុមហ៊ុនចែកចាយលក់មូលបត្រ, ក្រុមហ៊ុនសមភាគី កណ្តាល, ឈ្មួញជើងសាឧបករណ៍និស្សន្ទ, ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ, ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិ ជំនួស, ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិ ។ល។ ជាមួយគ្នានេះ គំនិតផ្តួចផ្តើម ដូចជាកម្មវិធីឧត្តមភាព (Excellence Program - EP) និងកម្មវិធីការជំរុញការ បោះផ្សាយលក់សញ្ញាបណ្ណចីរភាពនៅកម្ពុជា (Cambodia Sustainable Bond Accelerator - CSBA) ត្រូវបានដាក់ចេញ ដើម្បីលើកកម្ពស់ការកសាងសមត្ថភាពក្រុមហ៊ុនបោះផ្សាយសក្តានុពល និងជំរុញការ បោះផ្សាយលក់មូលបត្រ។

សម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ **ន.ម.ក.** ជាសមាជិកសកម្មរបស់វេទិកាទីផ្សារមូលធនអាស៊ាន (ASEAN Capital Markets Forum - ACMF) និងគណៈកម្មាធិការការងារអភិវឌ្ឍន៍ទីផ្សារមូលធនអាស៊ាន (Working Committee on Capital Market Development - WC-CMD)។ **ន.ម.ក.** ក៏ជាសមាជិកវេទិកា ទីផ្សារសញ្ញាបណ្ណអាស៊ាន+៣ (ASEAN Bond Markets Forum - ABMF), គណៈកម្មាធិការការងារសេរី ភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន (Working Committee on Financial Services Liberalisation - WC-FSL) និងគណៈកម្មាធិការការងារសេរីភាវូបនីយកម្មគណនីមូលធនអាស៊ាន (Working Committee on Capital Accounts Liberalisation - WC-CAL)។ ក្នុងឆ្នាំ២០២២ ក្នុងនាមជាប្រធាន ACMF **ន.ម.ក.** បាន បង្កើតនូវសមិទ្ធផលសំខាន់ៗជាច្រើន រួមមាន៖ ស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់នឹងចីរភាពអាស៊ាន ស្តង់ដា មូលនិធិប្រកបដោយចីរភាពនិងការទទួលខុសត្រូវអាស៊ាន និងបណ្តុំឯកសារផ្លូវច្បាប់សម្រាប់សញ្ញាបណ្ណ គោលដៅប្រកបដោយចីរភាពអាស៊ាន។

**ន.ម.ក.** បានចូលជាសមាជិកសមាការីរបស់អង្គការគណៈកម្មការមូលបត្រអន្តរជាតិ (International Organisation of Securities Commissions - IOSCO) ក្នុងឆ្នាំ២០១៧ និងកំពុងបន្តនីតិវិធីដើម្បីក្លាយជា សមាជិកពេញសិទ្ធិរបស់អង្គការនេះ។ ក្នុងទិសដៅលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព **ន.ម.ក.** បាន ចូលជាសមាជិកបណ្តាញធនាគារនិងហិរញ្ញវត្ថុចីរភាព (Sustainable Banking and Finance Network - SBFN) ក្នុងឆ្នាំ២០២៤។

តារាងទិន្នន័យស្ថិតិសង្ខេបខាងក្រោមនេះឆ្លុះបញ្ចាំងពីការរីកចម្រើននៃវិស័យមូលបត្រក្នុងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ៖

| ការពិពណ៌នា | | គិតត្រឹមឆ្នាំ ២០១៤ | គិតត្រឹមឆ្នាំ ២០២៤ |
|---|---|---|---|
| **ចំនួនក្រុមហ៊ុន** | | | |
| ប្រតិបត្តិករទីផ្សារមូលបត្រ | | ១ | ១ |
| ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ | | ១ | ១ |
| ប្រតិបត្តិកររក្សាទុកមូលបត្រ | | ១ | ១ |
| ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ | | ២ | ១១ |
| ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុល | | - | ១២ |
| ក្រុមហ៊ុនធានាទិញមូលបត្រ | | ៦ | ៧ |
| ក្រុមហ៊ុនពាណិជ្ជករមូលបត្រ | | ៦ | ៧ |
| ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ | | ៨ | ១១ |
| ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ | | - | ៣ |
| ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ | | ១ | ១ |
| ក្រុមហ៊ុនសមភាគីកណ្ដាល | | - | ៥ |
| ឈ្មួញជើងសាឧបករណ៍និស្សន្ទ | | - | ២០ |
| ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ | | - | ១២ |
| ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស | | - | ៨ |
| ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង | | - | ៦ |
| ក្រុមហ៊ុនអភិបាលមូលនិធិ | | - | ៦ |
| ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម | | ៦ | ១១ |
| ក្រុមហ៊ុនផ្ដល់សេវាវាយតម្លៃ | | ៣ | ២ |
| ការិយាល័យមេធាវី | | ១០ | ២២ |
| ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ | | - | ១ |
| ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល | | - | ៣ |
| ភ្នាក់ងារវាយតម្លៃលទ្ធភាពសង | | - | ១ |
| ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ | | ៣ | ៧ |
| ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ | | ២ | ៤ |
| **ទីផ្សារមូលបត្រកម្មសិទ្ធិ** | | | |
| សាច់ប្រាក់ដែលប្រមូលបានសរុប | រៀល (លាន) | ១៥៩.៣០៩,៦៤ | ៥១៦.៦៥៧,៥៧ |
| | ដុល្លារអាម៉េរិក(លាន) | ៣៩,៨៣ | ១២៨,៩២ |
| មូលធនូបនីយកម្មទីផ្សារ | រៀល (លាន) | ៦៤៣.០២៧ | ១១.១៧១.៥៩៣ |
| | ដុល្លារអាម៉េរិក(លាន) | ១៥៧,៨០ | ២.៧៧៥,៥៥ |
| ទំហំជួញដូរ (ភាគហ៊ុន) | | ១០.៩៣៦.៩២៦ | ២១៩.០៦៦.៩៣៥ |
| តម្លៃជួញដូរ | រៀល (លាន) | ៧៩.៣៥៦,១២ | ១.៥៤០.៩៨៣,៣១ |

| | | | |
|---|---|---|---|
| | ដុល្លារអាម៉េរិក(លាន) | ១៩,៤៧ | ៣៨២,៨៥ |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ | | ១៧,៧៦ | ៧២,៣៥ |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ | រៀល (លាន) | ១២៨,៦០ | ៥០៨,៩១ |
| | ដុល្លារអាម៉េរិក(លាន) | ០,០៣ | ០,១៣ |
| សន្ទស្សន៍ ផមក (សន្ទស្សន៍បិទ) | | ៤៣២,៣៨ | ៤១២,៧៥ |
| **ទីផ្សារមូលបត្របំណុល** | | | |
| សាច់ប្រាក់ដែលប្រមូលបានសរុប | រៀល (លាន) | - | ១.០៤៤.២១៣,១ |
| | ដុល្លារអាម៉េរិក(លាន) | - | ២៥៨,៣០ |
| ចំនួនសញ្ញាបណ្ណចុះបញ្ជីសរុប | | - | ១០.៤៤២.១៣១ |
| ចំនួនសញ្ញាបណ្ណដល់ឥណប្រតិទាន | | - | ៤.៩២០.២១០ |
| ទំហំជួញដូរ | | - | ៤៦០.៧៥២ |
| តម្លៃជួញដូរ | រៀល (លាន) | - | ៤៦.៣៨៦,៦៦ |
| | ដុល្លារអាម៉េរិក(លាន) | - | ១១,៥២ |
| **វិនិយោគិននៃទីផ្សារមូលបត្រកម្មសិទ្ធិ និងទីផ្សារមូលបត្របំណុល** | | | |
| ចំនួនវិនិយោគិន | | ៦.១៩១ | ៥៧.៥៦៦ |
| វិនិយោគិនសញ្ជាតិខ្មែរ | | ៣.៩៨៦ | ៥១.៦៥៨ |
| វិនិយោគិនសញ្ជាតិបរទេស | | ២.២០៥ | ៥.៩០៨ |
| ចំនួនគណនីជួញដូរ | | ៦.៣៦៣ | ៥៧.៦៤៦ |
| **ទីផ្សារឧបករណ៍និស្សន្ទ** | | | |
| ចំនួនឧបករណ៍និស្សន្ទអនុញ្ញាតឱ្យជួញដូរ | | - | ២៤៩ |
| ទំហំនៃការជួញដូរសរុប (ឯកតាជួញដូរ) | | - | ២.០៦៦.៧៩៩,១៨ |
| តម្លៃជួញដូរសរុប (លានដុល្លារអាម៉េរិក) | | - | ២.២៨៦,៥៨ |
| ចំនួនគណនីជួញដូរឧបករណ៍និស្សន្ទ | | - | ១១.៦៥២ |


មូលធនូបនីយកម្មទីផ្សារ (គិតជាលានដុល្លារអាមេរិក)
3,500.00
3,000.00
2,500.00
2,000.00
1,500.00
1,000.00
500.00
-
157.80
176.89
199.29
304.85
440.94
688.54
2,429.60
1,766.01
1,816.67
3,134.66
2,775.55
2014
2015
2016
2017
2018
2019
2020
2021
2022
2023
2024
មូលធនូបនីយកម្មទីផ្សារ (គិតជាលានដុល្លារអាមេរិក)


ទីផ្សារមូលបត្រកម្មសិទ្ធិ
គិតជាលានដុល្លារអាមេរិក
ចំនួនក្រុមហ៊ុនចុះបញ្ជី
3,500
3,000
2,500
2,000
1,500
1,000
500
-
7
6
5
4
3
2
1
0
157.80
176.89
199.29
304.85
440.94
688.54
2,429.60
1,766.01
1,816.67
3,134.66
2,775.55
1
1
1
1
2
1
1
2
2014
2015
2016
2017
2018
2019
2020
2021
2022
2023
2024
ចំនួនក្រុមហ៊ុនចុះបញ្ជី (មូលបត្រកម្មសិទ្ធិ)
មូលធនូបនីយកម្មទីផ្សារ (គិតជាលានដុល្លារអាមេរិក)


សន្ទស្សន៍ទីផ្សារ
40,000,000
35,000,000
30,000,000
25,000,000
20,000,000
15,000,000
10,000,000
5,000,000
-
1000
800
600
400
200
0
Q1
Q3
2014
2015
2016
2017
2018
2019
2020
2021
2022
2023
2024
ទំហំជួញដូរ
សន្ទស្សន៍ ផមក

## ការជួញដូរជាមធ្យមក្នុងទីផ្សារគិតចាប់ឆ្នាំ ២០១៤-២០២៤




## ទីផ្សារមូលបត្របំណុល




## អត្រាគូប៉ុង និងរយៈពេលឥណប្រតិទាននៃមូលបត្របំណុល




វិនិយោគិនក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល
70,000
60,000
50,000
40,000
30,000
20,000
10,000
-
2014 2015 2016 2017 2018 2019 2020 2021 2022 2023 2024
6,191 7,309 7,859 8,836 20,550 22,447 26,621 30,798 35,969 46,857 57,566
684 1,118 550 977 11,714 1,897 4,174 4,177 5,170 10,888 10,709
វិនិយោគិន
វិនិយោគិនសរុប


វិនិយោគិនក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ និង មូលបត្របំណុល
37%
63%
វិនិយោគិនភេទប្រុស
វិនិយោគិនភេទស្រី


វិនិយោគិនក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ និង មូលបត្របំណុល
10%
90%
វិនិយោគិនសញ្ជាតិខ្មែរ
វិនិយោគិនបរទេស


ការជួញដូរក្នុងទីផ្សារឧបករណ៍និស្សន្ទ
700.00
600.00
500.00
400.00
300.00
200.00
100.00
-
450,000
400,000
350,000
300,000
250,000
200,000
150,000
100,000
50,000
-
2016 2017 2018 2019 2020 2021 2022 2023 2024
0.05 3.74 86.67 183.31 598.25 476.16 314.96 277.81 190.88
តម្លៃជួញដូរសរុប (លានដុល្លារអាមេរិក)
ទំហំនៃការជួញដូរសរុប (ឯកតាជួញដូរ)




### ១.៣. ផែនការ និងយុទ្ធសាស្រ្តជាតិ

ក្នុងការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិរយៈពេលវែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្រ្តមួយចំនួន ដើម្បីជាផ្លូវឆ្ពោះទៅរកភាពរីកចម្រើនប្រកបដោយសណ្តាប់ធ្នាប់ និងនិរន្តរភាព ដែលក្នុងនោះរួមមាន៖

❖ **យុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១**

យុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១ បានកំណត់គោលដៅរយៈពេលវែងដែលមានភាពច្បាស់លាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនាពេលអនាគត ក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅការសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដោយផ្តោតលើអាទិភាពគន្លឹះចំនួន ៥ គឺ៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

❖ **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា**

ផែនការយុទ្ធសាស្រ្តនេះជាផែនទីបង្ហាញផ្លូវដល់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ និងជាឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១ និងវិធានការគន្លឹះទាំង៥ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

❖ **យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០**

យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គឺជាផែនទីបង្ហាញផ្លូវដែលរំលេចពីសកម្មភាពយុទ្ធសាស្រ្តសម្រាប់អនុវិស័យហិរញ្ញវត្ថុនីមួយៗស្របតាមតម្រូវការសេដ្ឋកិច្ច-សង្គម។

❖ **យុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨**

យុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច មានគោលបំណងបង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ធន់, ប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមកសំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និងលើកកម្ពស់ការបំពេញអនុលោមភាព។

❖ **ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**

ក្របខ័ណ្ឌគោលនយោបាយនេះមានគោលបំណងកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលប្រកបដោយភាពរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក(បន្សាំ) និងការធ្វើបរិវត្តកម្មឌីជីថល នៅគ្រប់តួអង្គ រួមមាន៖ រដ្ឋាភិបាល ពលរដ្ឋ និងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លងប្រក្រតីថ្មី។

❖ **គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**

គោលនយោបាយនេះ មានគោលបំណងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គសំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឱ្យកាន់តែរស់រវើក។

❖ **ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ឆ្នាំ២០១៦-២០៣០**

ក្របខ័ណ្ឌ **គ.អ.ច.ក.** ជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មសកម្មភាព **គ.អ.ច.ក.** ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងតាមដានត្រួតពិនិត្យនូវសមិទ្ធផលសម្រេច តាមរយៈកិច្ចខិតខំប្រឹងប្រែងនិងសកម្មភាពនានារបស់រាជរដ្ឋាភិបាល វិស័យឯកជន ពលរដ្ឋ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត។

## ជំពូកទី២៖ ការវិភាគអំពីស្ថានភាពនៃវិស័យមូលបត្រនៅកម្ពុជា

ដើម្បីបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយបរិយាបន្ន និរន្តរភាព និងភាពធន់ វិស័យមូលបត្រត្រូវពង្រីកវិសាលភាព និងមានប្រព័ន្ធអេកូឡូស៊ីពេញលេញ ដើម្បីជួយលើកស្ទួយសកម្មភាពផលិតភាពផ្សេងៗ តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដែលឆ្លើយតបនឹងភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម (SWOT) ចំពោះវិស័យមូលបត្រ។ វិស័យមូលបត្រនៅកម្ពុជាត្រូវបានវិភាគយ៉ាងល្អិតល្អន់និងគ្រប់ជ្រុងជ្រោយ ដោយរំលេចចេញនូវភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម ដូចខាងក្រោម៖

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| - ស្ថានភាពនយោបាយមានស្ថិរភាព<br>- ការប្តេជ្ញាចិត្តរបស់និយ័តករហិរញ្ញវត្ថុក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ<br>- អត្រាប្រើប្រាស់ទូរសព្ទខ្ពស់<br>- ចំនួនប្រជាជនវ័យកណ្តាល អាយុជាមធ្យម (ប្រហែល ២៧ ឆ្នាំ) ទាបជាងមធ្យមភាគសកល (ប្រហែល ៣១ ឆ្នាំ)<br>- ក្របខ័ណ្ឌបទប្បញ្ញត្តិមានភាពរឹងមាំ<br>- ការបន្តអភិវឌ្ឍមូលបត្ររដ្ឋគឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកភាពស៊ីជម្រៅនៃទីផ្សារមូលបត្របំណុលនៅកម្ពុជា | - ធនធានទំនេរក្នុងការវិនិយោគនៅមានកម្រិត<br>- ទីផ្សារនៅមានទំហំតូច ជាពិសេសក្នុងបរិបទសកលភាវូនីយកម្ម<br>- កង្វះអ្នកជំនាញហិរញ្ញវត្ថុ ឬអ្នកមានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុ<br>- អត្រាប្រតិបត្តិការប្រាក់ដុល្លារអាមេរិកខ្ពស់ |
| **កាលានុវត្តភាព** | **ការគំរាម** |
| - ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាកាន់តែច្រើន/ឌីជីថលូបនីយកម្ម<br>- ការអភិវឌ្ឍនៃផ្នែកកំណើនដូចជា ហិរញ្ញវត្ថុបៃតង និងបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ការបោះផ្សាយលក់មូលបត្ររដ្ឋនឹងផ្តល់នូវស្តង់ដាខ្សែកោងទិន្នផលគោល (benchmark yield) មួយសម្រាប់ទីផ្សារមូលបត្រ, បង្កើនសន្ទនីយភាពទីផ្សារ, ផ្តល់ភាពងាយស្រួល និងទាក់ទាញមូលដ្ឋានវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសឱ្យកាន់ទូលំទូលាយ | - អ្នកចូលរួមក្នុងទីផ្សារមានជម្រើសតិចតួច<br>- ការផ្គត់ផ្គង់ និងតម្រូវការហិរញ្ញវត្ថុមិនឆ្លើយតបគ្នា<br>- ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជនមានកម្រិតទាប<br>- ការកៀរគរទុនវិនិយោគឯកជនយឺត<br>- ថ្លៃដើមនៃការទទួលបានមូលធននៅមានកម្រិតខ្ពស់ |

| | |
|---|---|
| - ការអនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធ-សាស្ត្រដែលពាក់ព័ន្ធ<br>- ការចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមអាស៊ាន<br>- ការវិនិយោគសំខាន់ៗក្នុងការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធ | |

## ២.១. ការវិភាគអំពីភាពខ្លាំង

ស្ថានភាពនយោបាយនៅប្រទេសកម្ពុជាមានស្ថិរភាពរយៈពេលជាង ២ ទសវត្សរ៍មកហើយ ដែលធ្វើឱ្យគោលនយោបាយសេដ្ឋកិច្ចកម្ពុជាមានលំនឹង អាចឱ្យធុរជនរៀបចំផែនការអាជីវកម្មរយៈពេលវែង និងពង្រីកអាជីវកម្ម ដែលផ្តល់លទ្ធផលល្អដល់ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមូលបត្រ។

អាជ្ញាធរនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា បានប្តេជ្ញាចិត្តខ្ពស់ក្នុងការធានាឱ្យបាននូវការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុប្រកបដោយយុត្តិធម៌ និងសណ្តាប់ធ្នាប់។ ការប្តេជ្ញាចិត្តនេះ មិនត្រឹមតែជួយជំរុញគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍវិស័យប៉ុណ្ណោះទេ ថែមទាំងជួយបង្កើនទំនុកចិត្តនៅក្នុងទីផ្សារហិរញ្ញវត្ថុ រួមបញ្ចូលទាំងទីផ្សារមូលបត្រផងដែរ ជាពិសេសក្នុងទិដ្ឋភាពនៃកំណើនអន្តរទំនាក់ទំនង (inter-linkages) នៅគ្រប់ផ្នែកនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាការកើនឡើងនៃផលិតផលហិរញ្ញវត្ថុដែលមានភាពស្មុគស្មាញជាច្រើនទៀត។

ប្រទេសកម្ពុជាមានអត្រាប្រើប្រាស់ទូរសព្ទដៃខ្ពស់ ដែលនេះជាកត្តាអំណោយផលមួយ ជាមួយនឹងកំណើនយ៉ាងឆាប់រហ័សនៃការទទួលយកបច្ចេកវិទ្យា។ សម្រាប់វិស័យមូលបត្រ អត្រានៃការប្រើប្រាស់ទូរសព្ទដៃខ្ពស់បានបង្ហាញថា ប្រជាជនបានយល់ច្បាស់ពីបច្ចេកវិទ្យាដែលមាននៅក្នុងកម្មវិធីទូរសព្ទចល័តទូទៅ ដែលការណ៍នេះធ្វើឱ្យការប្រើប្រាស់បច្ចេកវិទ្យាកាន់តែលឿននិងមានភាពទូលំទូលាយ និងផ្តល់ភាពងាយស្រួលក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ផលិតផលនិងសេវា នវានុវត្តន៍ពាក់ព័ន្ធនឹងមូលបត្រ និងការវិនិយោគលើមូលបត្រ។

ប្រទេសកម្ពុជាមានប្រជាជនវ័យកណ្តាលដែលមានអាយុជាមធ្យម (ប្រហែល ២៧ ឆ្នាំ) ទាបជាងអាយុមធ្យមភាគសាកល (ប្រហែល ៣១ ឆ្នាំ) ដែលយុវជនទាំងនេះនឹងក្លាយជាធនធានដែលផ្តល់ផលប្រយោជន៍ដល់វិស័យមូលបត្រ។ យុវជនជាប្រភពកម្លាំងពលកម្មដ៏ធំ ដែលទទួលបានការបណ្តុះបណ្តាលខ្ពស់ ដែលឆ្លុះបញ្ចាំងពីចំនួនអ្នកប្រើប្រាស់ ឬវិនិយោគិនដែលមានសក្តានុពលខ្ពស់នាថ្ងៃអនាគត ក្នុងការជួយគាំទ្រសកម្មភាពក្នុងទីផ្សារមូលបត្រ។ បន្ថែមពីនេះ យុវជនជំនាន់ក្រោយស្គាល់បច្ចេកវិទ្យាច្រើន ដែលការណ៍នេះជួយឱ្យការសម្របខ្លួនទៅនឹងបច្ចេកវិទ្យាកាន់តែងាយស្រួល និងប្រើប្រាស់បច្ចេកវិទ្យាដើម្បីចូលរួមជំរុញការអភិវឌ្ឍវិស័យមូលបត្រ។

ក្របខ័ណ្ឌបទប្បញ្ញត្តិក្នុងវិស័យមូលបត្រមានភាពពេញលេញនិងរឹងមាំដែលស្របតាមគោល-ការណ៍របស់ IOSCO និងការអនុវត្តអន្តរជាតិ ព្រមទាំងត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធកម្មដើម្បីឆ្លើយតបនិន្នាការទីផ្សារនិងនិន្នាការសកល។

ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ នឹងក្លាយជាផ្នែកដ៏សំខាន់មួយនៃការគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្របំណុលនៅកម្ពុជាឱ្យកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀត។

## ២.២. ការវិភាគអំពីភាពខ្សោយ

**ផសស** ក្នុងមនុស្សម្នាក់នៅកម្ពុជានៅមានកម្រិតទាប ដែលបង្ហាញថាសាច់ប្រាក់ដែលមានសម្រាប់សន្សំ និងសាច់ប្រាក់ដែលមានក្នុងប្រព័ន្ធហិរញ្ញវត្ថុនៅមានកម្រិតទាប ដែលនេះជាឧបសគ្គក្នុងការបង្កើតឱ្យមានតម្រូវការផលិតផលនិងសេវាក្នុងទីផ្សារមូលបត្រ។ បន្ថែមពីនេះ ភាពខុសគ្នានៃប្រាក់ចំណូលរវាងប្រជាជននៅទីក្រុង និងជនបទ បង្ហាញពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍនិងការអនុវត្តគំនិតផ្តួចផ្តើមថ្មីៗសម្រាប់វិស័យមូលបត្រ ដោយទាមទារឱ្យមានយុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗគ្នា ដែលធ្វើឱ្យប៉ះពាល់ដល់ទំហំ ប្រសិទ្ធភាព និងការចំណាយ។

នៅពេលដែលបរិបទសេដ្ឋកិច្ច និងធុរកិច្ចកាន់តែមានលក្ខណៈសកល កម្ពុជាត្រូវមានទីតាំងយុទ្ធសាស្ត្រ (strategic positioning) ដើម្បីរក្សាឱ្យបាននូវភាពប្រកួតប្រជែងរបស់ខ្លួន ដែលនឹងផ្តល់នូវអត្ថប្រយោជន៍សម្រាប់វិស័យមួយចំនួន ខណៈដែលវិស័យមួយចំនួនផ្សេងទៀតអាចទទួលរងផលប៉ះពាល់អវិជ្ជមាន ព្រោះតែចំនួនប្រជាជនតិច និងទំហំសេដ្ឋកិច្ចនៅតូចជាដើម។

បញ្ហាកង្វះខាតអ្នកជំនាញហិរញ្ញវត្ថុ ឬអ្នកដែលមានបទពិសោធន៍ ដើម្បីបម្រើការងារក្នុងវិស័យមូលបត្រ ក៏ធ្វើឱ្យប៉ះពាល់ដល់ល្បឿននៃការអភិវឌ្ឍវិស័យនេះផងដែរ។

បន្ថែមលើចំណុចដែលបានគូសបញ្ជាក់ខាងលើ អត្រាប្រតិបត្តិការប្រាក់ដុល្លារអាម៉េរិកមានកម្រិតខ្ពស់ក្នុងប្រទេសកម្ពុជា ប៉ុន្តែការបោះផ្សាយលក់មូលបត្រត្រូវបានកំណត់ជាប្រាក់រៀល ដែលការណ៍នេះក៏ជាឧបសគ្គមួយដ៏សំខាន់ក្នុងការជំរុញការបោះផ្សាយលក់មូលបត្រ និងការវិនិយោគលើមូលបត្រ។

## ២.៣. ការវិភាគអំពីកាលានុវត្តភាព

បច្ចេកវិទ្យា គឺជាធាតុដ៏សំខាន់នៅក្នុងការជំរុញ និងគាំទ្រការអភិវឌ្ឍវិស័យនានានៅក្នុងសេដ្ឋកិច្ច។ ចំពោះវិស័យមូលបត្រ ការប្រើប្រាស់បច្ចេកវិទ្យាពិតជាមានសារៈសំខាន់សម្រាប់ទាំងការអភិវឌ្ឍទីផ្សារ និងការធ្វើនិយ័តកម្ម។ ការប្រើប្រាស់បច្ចេកវិទ្យា និងការបង្កើនឌីជីថលូបនីយកម្ម នឹងជួយពង្រឹងប្រសិទ្ធភាពនៃដំណើរការការងារ កាត់បន្ថយការចំណាយប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ហិរញ្ញវត្ថុជាដើម ដែលការណ៍នេះនឹងជួយជំរុញវិស័យមូលបត្រឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។

ខណៈពេលដែលវិស័យមូលបត្រកំពុងប្រែក្លាយខ្លួនទៅជាទីផ្សារកំពុងងើបឡើង (Frontier market status) វិស័យនេះអាចទាញយកប្រយោជន៍ពីនិន្នាការសកលថ្មីៗ ដោយរួមបញ្ចូលនូវកត្តាដែលអំណោយផលដល់ការអភិវឌ្ឍផ្នែកថ្មីៗដែលជាផ្នែកមួយនៃការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីរបស់វិស័យមូលបត្រ។ ក្នុងន័យនេះ ហិរញ្ញវត្ថុចីរភាព និងបច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាធាតុសំខាន់ពីរដែលជួយឱ្យវិស័យមូលបត្រអាចទាក់ទាញការចូលរួមក្នុងទីផ្សារកាន់តែច្រើន ក៏ដូចជាជំរុញការសាយភាយផលវិជ្ជមាន។

ការបោះផ្សាយលក់មូលបត្ររដ្ឋនឹងផ្តល់នូវស្តង់ដាខ្សែកោងទិន្នផលគោល (benchmark yield)

មួយសម្រាប់ទីផ្សារមូលបត្រ បង្កើនសន្ទនីយភាពទីផ្សារ ផ្តល់ភាពងាយស្រួល និងទាក់ទាញមូលដ្ឋានវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសឱ្យកាន់ទូលំទូលាយ។

ដូចដែលបានគូសបញ្ជាក់ខាងលើ ប្រទេសកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសំខាន់ៗ ដែលការអនុវត្តដោយជោគជ័យនូវគោលនយោបាយ និងផែនការទាំងនេះ នឹងផ្តល់អត្ថប្រយោជន៍សម្រាប់វិស័យដែលបានកំណត់ និងសេដ្ឋកិច្ចទាំងមូល ដែលជាកាលានុវត្តភាពសម្រាប់វិស័យមូលបត្រ ទាំងផ្នែកប្រភពហិរញ្ញប្បទាន និងប្រភពវិនិយោគ។

**ន.ម.ក.** គឺជាសមាជិកដ៏សកម្មរបស់អាស៊ាន ដែលឆ្លុះបញ្ចាំងតាមរយៈសមិទ្ធផលដែលបានបង្កើតឡើងក្នុងអំឡុងពេលដែល **ន.ម.ក.** ធ្វើជាប្រធាន ACMF ក្នុងឆ្នាំ២០២២។ **ន.ម.ក.** បាន និងកំពុងចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមអាស៊ានជាច្រើនក្នុងក្របខ័ណ្ឌវិស័យមូលបត្រ តាមរយៈ ACMF, WC-CMD, គំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ី (ASEAN Bond Markets Initiative – ABMI) និងគណៈកម្មាធិការកម្រិតខ្ពស់អាស៊ាន (ASEAN Senior Level Committee – SLC)។ ការចូលរួមយ៉ាងសកម្មក្នុងក្រុមការងារទាំងនេះ បានពង្រីកកាលានុវត្តភាព និងសក្តានុពលសម្រាប់កម្ពុជាក្នុងការជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងបង្កើតឱ្យមានការអភិវឌ្ឍទីផ្សារមូលបត្រដែលមានភាពស៊ីសង្វាក់គ្នាជាមួយប្រទេសជាសមាជិកដទៃទៀត។

ការវិនិយោគសំខាន់ៗក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ថាជាការគាំទ្រ និងសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដូចមានបញ្ជាក់នៅក្នុងផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣។ ការអនុវត្តគំនិតផ្តួចផ្តើមនៅក្នុងផែនការមេនេះ ត្រូវការថវិកាយ៉ាងច្រើនពីវិស័យសាធារណៈនិងឯកជន ដូចនេះ វិស័យមូលបត្រជាជម្រើសដ៏សមស្របសម្រាប់ការប្រមូលដើមទុនដើម្បីអភិវឌ្ឍគម្រោងទាំងនេះ។

### ២.៤. ការវិភាគអំពីការគំរាម

ភាពមានកម្រិតនៃទំហំទីផ្សារ ផលិតផល និងសេវានៅក្នុងវិស័យមូលបត្រនាពេលបច្ចុប្បន្ន ធ្វើឱ្យទីផ្សារមូលបត្រកម្ពុជាមិនសូវមានភាពទាក់ទាញ ដែលបង្កើតជាឧបសគ្គដល់ការពង្រីកផលិតផល ឬសេវាថ្មីៗក្នុងវិស័យមូលបត្រ។

ទន្ទឹមនឹងនេះ ភាពមានកម្រិតនៃផលិតផលក្នុងទីផ្សារ ធ្វើឱ្យការផ្គត់ផ្គង់ និងតម្រូវការដើមទុនមិនអាចឆ្លើយតបគ្នា។ ខណៈពេលដែលគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកអាជីវកម្មភាគច្រើន ត្រូវការហិរញ្ញប្បទានរយៈពេលវែង ក៏ប៉ុន្តែសាច់ប្រាក់ភាគច្រើនត្រូវបានដាក់សន្សំនៅក្នុងប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លី។ ដូចនេះ ភាពអសកម្មនៃទីផ្សារមូលបត្របំណុល ជាបញ្ហាប្រឈមសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់គម្រោងរយៈពេលវែង។

អត្រាអក្ខរកម្មហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជានៅមានកម្រិតទាប ដែលជាហេតុធ្វើឱ្យពួកគាត់អាចមានភាពស្ទាក់ស្ទើរក្នុងការវិនិយោគ ងាយនឹងទទួលរងការបោកប្រាស់ និងអាចធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុមិនបានត្រឹមត្រូវ។ ស្ថានភាពបែបនេះ ជាបញ្ហាប្រឈមសម្រាប់វិស័យមូលបត្រក្នុងការទាក់ទាញ

ការចូលរួមពីសាធារណជន ឬអាចបង្កជាហានិភ័យសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេស និងការអនុវត្តគំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍនានា គឺមានតម្រូវការមូលនិធិដ៏ច្រើនសន្ធឹកសន្ធាប់ និងត្រូវការកៀរគរពីវិស័យសាធារណៈនិងឯកជន។ ប៉ុន្តែការកៀរគរមូលនិធិវិនិយោគសម្រាប់អភិវឌ្ឍ និងអនុវត្តគំនិតផ្តួចផ្តើមទាំងនេះមានភាពយឺតយ៉ាវ ដែលធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។

បន្ថែមពីនេះទៀត ការចំណាយខ្ពស់ក៏ជាឧបសគ្គចម្បងសម្រាប់ការពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន និងការវិនិយោគ។ ភាពលំបាកក្នុងការទទួលបានហិរញ្ញប្បទាន និងតម្រូវការក្នុងការបង្កើតប្រាក់ចំណូលខ្ពស់ពីការវិនិយោគ បានរឹតត្បិតក្រុមហ៊ុនក្នុងការអភិវឌ្ឍ និងពង្រីកអាជីវកម្ម។ ការណ៍នេះនឹងធ្វើឱ្យមានភាពលំបាកក្នុងការរក្សាកំណើនសេដ្ឋកិច្ច។

❖ **សេចក្តីសន្និដ្ឋានអំពីការវិភាគ SWOT ការវាយតម្លៃ និងការកំណត់ចំណុចសំខាន់**

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ វិស័យមូលបត្រនៅកម្ពុជាបានអនុវត្តគំនិតផ្តួចផ្តើម និងកម្មវិធីជាច្រើន ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីវិស័យមូលបត្រ តាមរយៈការបង្កើនសមត្ថភាពនិងលទ្ធភាពការជំរុញការបង្កើនការផ្គត់ផ្គង់ និងតម្រូវការផលិតផលនិងសេវាក្នុងវិស័យមូលបត្រឱ្យកាន់តែខ្ពស់ និងការពង្រឹងសណ្តាប់ធ្នាប់និងសុចរិតភាពទីផ្សារ។ ផ្អែកលើគំនិតផ្តួចផ្តើមទាំងនេះ, ការព្យាករណ៍នៃសេដ្ឋកិច្ចនិងទីផ្សារមូលបត្រ និងការគិតគូរយ៉ាងល្អិតល្អន់ដែលទាញចេញពីការវិភាគ SWOT មានការកំណត់នូវសកម្មភាពមួយចំនួនដែលត្រូវដាក់ចេញជាវិធានការដោះស្រាយបញ្ហា និងទាញយកកាលានុវត្តភាពនាពេលខាងមុខ។

សកម្មភាពដែលបានកំណត់ទាំងនោះ ត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

- **បញ្ហាដែលទាមទារដំណោះស្រាយភ្លាមៗ ឬរយៈពេលខ្លី ដោយសារបញ្ហាទាំងនោះជាធាតុផ្សំដ៏សំខាន់នៃប្រព័ន្ធអេកូឡូស៊ីទាំងមូល**
- **កាលានុវត្តភាពនៅក្នុងកំណើនថ្មី ដែលអាចក្លាយជាកត្តាចម្បងក្នុងការជំរុញ និងគាំទ្រការអភិវឌ្ឍ**
- **បញ្ហាប្រឈមដែលអាចនឹងកើតមាន នៅពេលវិស័យមូលបត្រអភិវឌ្ឍដល់កម្រិតមួយ។**

• *បញ្ហាដែលទាមទារដំណោះស្រាយភ្លាមៗ ឬរយៈពេលខ្លី ដោយសារបញ្ហាទាំងនោះជាធាតុផ្សំដ៏សំខាន់នៃប្រព័ន្ធអេកូឡូស៊ីទាំងមូល*

- **ផមក** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ដែលជាតំណាងឱ្យជាធាតុផ្សំដ៏សំខាន់នៃប្រព័ន្ធអេកូឡូស៊ីក្នុងវិស័យមូលបត្រ។ ដោយឡែក ក្នុងរយៈពេល ១៣ ឆ្នាំមកនេះ (គិតត្រឹមឆ្នាំ២០២៤) ក្រុមហ៊ុនដែលបានចុះបញ្ជីមានចំនួនត្រឹមតែ ២៣ ដែលក្នុងនោះ ១២ ក្រុមហ៊ុនបានបោះផ្សាយសញ្ញាបណ្ណសាជីវកម្ម។ ដូចនេះ មានការទាមទារនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីទាក់ទាញក្រុមហ៊ុនចុះបញ្ជីបន្ថែមនៅ **ផមក** ក្នុងគោលដៅផ្តល់នូវប្រភពហិរញ្ញប្បទាននិងជម្រើសវិនិយោគកាន់តែច្រើន, ផ្តល់កាលានុវត្តភាពឱ្យក្រុមហ៊ុនគ្រប់គ្រងមូលនិធិបង្កើតមូលនិធិនិងផលបត្រ

វិនិយោគក្នុងស្រុក ព្រមទាំងបង្កើនសកម្មភាពជួញដូរក្នុងទីផ្សារ។ បន្ថែមពីនេះ ផលិតផល និងសេវាផ្សេងទៀតក្នុងវិស័យមូលបត្រ ក៏ត្រូវពង្រីកបន្ថែមដើម្បីបំពេញតម្រូវការរបស់បុគ្គល និងសាជីវកម្មដែលចូលរួមក្នុងទីផ្សារមូលបត្រ។ ផ្សារភ្ជាប់នឹងករណីនេះ នាពេលបច្ចុប្បន្ន សេវាដែលផ្តល់ដោយអន្តរការីមូលបត្រដែលទទួលបានអាជ្ញាបណ្ណឬការអនុញ្ញាតពី **ន.ម.ក.** ក៏នៅមានកម្រិតផងដែរ។

- គិតត្រឹមឆ្នាំ២០២៤ វិនិយោគិនមានចំនួនខ្ពស់គួរឱ្យកត់សម្គាល់ (ប្រហែល ៥៧.៥៦៦ នាក់) ដែលបានបើកគណនីជួញដូរ ប៉ុន្តែវិនិយោគិនសកម្មក្នុងទីផ្សារនៅមានចំនួនតិចនៅឡើយ។ **ន.ម.ក.** គួរដាក់ចេញនូវវិធានការជំរុញ និងលើកទឹកចិត្តវិនិយោគិនរូបវន្តបុគ្គលនិងស្ថាប័ន ដើម្បីជំរុញការជួញដូរ និងបង្កើតទីផ្សារមួយដ៏សកម្ម។ ការចូលរួមរបស់ស្ថាប័នបរទេសក៏គួរតែត្រូវបានគិតគូរបន្ថែម ដើម្បីពង្រីក និងធ្វើពិពិធកម្មមូលដ្ឋានវិនិយោគិន។ ដោយការទទួលបានព័ត៌មានដែលអាចជួយឱ្យវិនិយោគិនមានការយល់ដឹងកាន់តែច្រើនសម្រាប់ធ្វើការសម្រេចចិត្តក៏ជាកត្តាសំខាន់ ដូចនេះ គួរតែបង្កើតបណ្តាញផ្តល់ព័ត៌មានប្រកបដោយនវានុវត្តន៍ ដែលមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន។
- និយ័តករ និងអ្នកចូលរួមក្នុងទីផ្សារបានដាក់ចេញនូវគំនិតផ្តួចផ្តើមមួយចំនួនដើម្បីបង្កើនការយល់ដឹងផ្នែកហិរញ្ញវត្ថុនិងអក្ខរកម្មហិរញ្ញវត្ថុដល់សាធារណជន។ កិច្ចខិតខំប្រឹងប្រែងដាក់បញ្ចូលចំណេះដឹងផ្នែកមូលបត្រទៅក្នុងកម្មវិធីសិក្សាសម្រាប់សិស្ស-និស្សិតក៏ត្រូវបានអនុវត្តផងដែរ។ នៅពេលដែលវិស័យមូលបត្រកាន់តែមានការអភិវឌ្ឍ តម្រូវការសម្រាប់កម្មវិធីមានភាពចម្រុះ និងវិធីសាស្ត្រនៃការផ្សព្វផ្សាយមានកាន់តែច្រើន ដើម្បីឆ្លើយតបទៅនឹងកម្រិតផ្សេងៗនៃចំណេះដឹង ក៏ដូចជាការកើនឡើងនៃភាពស្មុគស្មាញនៅក្នុងវិស័យនេះ។ ខណៈដែលទីផ្សារបច្ចុប្បន្នខ្វះអ្នកជំនាញក្នុងវិស័យមូលបត្រ ការកសាងសមត្ថភាព និងការអភិវឌ្ឍទេពកោសល្យក្នុងវិស័យនេះកាន់តែមានភាពចាំបាច់ ដើម្បីធានាបានថាទីផ្សារនេះមានអ្នកជំនាញវិជ្ជាជីវៈគ្រប់គ្រាន់នៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍ។
- នីតិវិធីត្រួតពិនិត្យបច្ចុប្បន្នមួយចំនួនអនុវត្តជាលក្ខណៈប្រពៃណី (manually) នៅឡើយ ដូចនេះការអភិវឌ្ឍក្របខ័ណ្ឌបច្ចេកវិទ្យានិយ័តកម្ម (RegTech) និងបច្ចេកវិទ្យាត្រួតពិនិត្យ (SupTech) គឺមានភាពចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពត្រួតពិនិត្យ ព្រមជាមួយនឹងការរៀបចំនូវក្របខ័ណ្ឌត្រួតពិនិត្យពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យថ្មីៗ ជាពិសេសហានិភ័យផ្នែកបច្ចេកវិទ្យា និងសន្តិសុខសាយប័រ។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសម្រាប់ការត្រួតពិនិត្យប្រតិបត្តិករទីផ្សារក៏សំខាន់ផងដែរ។ វិស័យមូលបត្រទទួលរងផលប៉ះពាល់បណ្តាលមកពីការឆបោក ឬការប៉ុនប៉ងឆបោកផ្នែកហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់រូបភាពវិនិយោគក្នុងវិស័យមូលបត្រ ដែលមាននិន្នាការកើនឡើងជាបន្តបន្ទាប់ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ទំនុកចិត្តវិនិយោគិន ដែលការណ៍នេះទាមទារឱ្យមានក្របខ័ណ្ឌសមស្របដើម្បីគ្រប់គ្រងការងារនេះប្រកបដោយ

ប្រសិទ្ធភាព។ ជាមួយគ្នានេះ ដើម្បីគ្រប់គ្រងធនធាននិងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការធ្វើអន្តរកាលឆ្ពោះទៅការចាប់យកអភិក្រមត្រួតពិនិត្យផ្អែកលើហានិភ័យ គួរតែត្រូវបាន ពិចារណា។

- គំនិតផ្ដួចផ្ដើមជំរុញការអភិវឌ្ឍវិស័យមូលបត្រជាច្រើន ទាមទារឱ្យមានការចូលរួមពីភាគី ពាក់ព័ន្ធទាំងវិស័យសាធារណៈនិងវិស័យឯកជន។ គំនិតផ្ដួចផ្ដើមដែលមានការចូលរួមពីក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវតែផ្ដល់អាទិភាពដល់ផលប្រយោជន៍ជាតិជាធំ និងផ្ដល់នូវកិច្ចសហការ ខ្ពស់។ ការចែករំលែកធនធានសម្រាប់កិច្ចសហប្រតិបត្តិការជាមួយវិស័យសាធារណៈនិងវិស័យ ឯកជន នាំឱ្យសម្រេចបានលទ្ធផលកាន់តែមានប្រសិទ្ធភាព។

- *កាលានុវត្តភាពនៅក្នុងកំណើនថ្មី ដែលអាចក្លាយជាកត្តាចម្បងក្នុងការជំរុញនិងគាំទ្រការអភិវឌ្ឍ*

- ចីរភាព គឺជារបៀបវារៈជាតិដ៏សំខាន់។ ក្នុងន័យនេះ ហិរញ្ញវត្ថុចីរភាពជាផ្នែកមួយដែលកំពុង រីកចម្រើនយ៉ាងឆាប់រហ័ស និងជាកាលានុវត្តភាពសម្រាប់ជំរុញការអភិវឌ្ឍវិស័យមូលបត្រ។ អាស្រ័យហេតុនេះ ប្រព័ន្ធអេកូឡូស៊ីនៃវិស័យនេះ គឺត្រូវតែអភិវឌ្ឍដោយរួមបញ្ចូលក្របខ័ណ្ឌ បទប្បញ្ញត្តិ សម្រាប់ផលិតផល និងសេវា, ឃ្លាំងទិន្នន័យ និងព័ត៌មាន, កម្មវិធីលើកកម្ពស់ការ យល់ដឹង និងការកសាងសមត្ថភាព ជាដើម។
- ការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ របស់ រាជរដ្ឋាភិបាលកម្ពុជា បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដូច្នេះ វិធានការ ស្ថិតក្រោមគោលនយោបាយនេះ គួរត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការចាប់ យកនិងការប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងវិស័យមូលបត្រ គួរត្រូវបានផ្ដល់អាទិភាព និងស្របតាមភាពរួចរាល់របស់អ្នកចូលរួមក្នុងទីផ្សារ។ ដូចនេះ គួរតែមានការគិតគូរលើកទឹកចិត្ត គាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យា។
- ទិន្នន័យ គឺជាធាតុចូលដ៏សំខាន់សម្រាប់ការធ្វើសេចក្ដីសម្រេចចិត្ត។ ស្របពេលវិស័យមូលបត្រ នៅកម្ពុជាកាន់តែរីកចម្រើន ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យនិងការពង្រឹង សមត្ថភាពវិភាគទិន្នន័យ បានក្លាយជាអាទិភាពចម្បង ដែលលទ្ធផលនៃការវិភាគទិន្នន័យនឹង ត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើតជាគំនិតផ្ដួចផ្ដើមសំខាន់ៗ។

- *បញ្ហាប្រឈមដែលអាចកើតមាននៅពេលវិស័យមូលបត្រអភិវឌ្ឍដល់កម្រិតមួយ*

- នៅពេលដែលចំនួននិងភាពស្មុគស្មាញនៃផលិតផលនិងសេវា និងការចូលរួមរបស់វិនិយោគិន ក្នុងវិស័យមូលបត្រកាន់តែកើនឡើង នោះទាមទារជាចាំបាច់នូវការពង្រឹងនិងពង្រីកយន្តការ ការពារវិនិយោគិន ដើម្បីរក្សាសុចរិតភាពទីផ្សារមូលបត្រ។ ទន្ទឹមនឹងនេះ សមត្ថភាពសម្រប-សម្រួលនិងការអនុវត្តច្បាប់ គួរត្រូវបានផ្ដល់អាទិភាព។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ក៏ ត្រូវរក្សាល្បឿនស្របជាមួយនឹងការពង្រីកចំនួននិងភាពស្មុគស្មាញនៃផលិតផលផងដែរ។ ដើម្បី

អភិវឌ្ឍទីផ្សារប្រកបដោយសណ្តាប់ធ្នាប់ បទប្បញ្ញត្តិផ្តល់អាជ្ញាបណ្ណឬការអនុញ្ញាត គ្រប់គ្រង និងត្រួតពិនិត្យអន្តរការីមូលបត្រ ត្រូវពិនិត្យឡើងវិញជាប្រចាំ ដើម្បីធានាបាននូវប្រតិបត្តិការអាជីវកម្មប្រកបដោយនិរន្តរភាព។ លើសពីនេះ នៅពេលដែលវិស័យមូលបត្រមានការរីកចម្រើន នោះហានិភ័យរបស់វិស័យនេះក៏នឹងមានការកើនឡើងផងដែរ ដែលទាមទារឱ្យមាននូវអភិក្រមនៃការត្រួតពិនិត្យមួយដែលគិតគូរលើហានិភ័យផ្សេងៗក្នុងទីផ្សារ។

- នៅពេលវិស័យហិរញ្ញវត្ថុមានការពង្រីកនូវផលិតផល និងសេវាហិរញ្ញវត្ថុកាន់តែច្រើន នោះការប្រកួតប្រជែងតម្លៃក្លាយជាកត្តាសំខាន់ក្នុងការទាក់ទាញការចូលរួមក្នុងទីផ្សារមូលបត្រជាពិសេស នៅពេលដែលសកម្មភាពឆ្លងដែនកើនឡើង ដែលជំរុញឱ្យអ្នកចូលរួមអន្តរជាតិអាចប្រៀបធៀបជម្រើសផ្សេងៗ។ ជាងនេះទៅទៀត សម្រាប់ផ្នែកដែលកម្ពុជាមានបំណងពន្លឿនការអភិវឌ្ឍ ឬការប្រកួតប្រជែងជាមួយយុត្តាធិការផ្សេងទៀត ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព គួរតែត្រូវបានពិចារណា។ បច្ចេកវិទ្យាបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជំរុញប្រសិទ្ធភាពទីផ្សារ ដែលទាំងនិយ័តករនិងអ្នកចូលរួមក្នុងទីផ្សារត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរ។

# ជំពូកទី៣៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ

## ៣.១. ចក្ខុវិស័យ គោលបំណង និងគោលដៅ

### ៣.១.១. ចក្ខុវិស័យ

តាមរយៈការអនុវត្តយុទ្ធសាស្ត្រនេះ ទីផ្សារមូលបត្រកម្ពុជានឹងក្លាយជាទីផ្សារមួយដែលមានភាពសកម្ម និងសម្បូរបែប ព្រមទាំងប្រកបដោយវិជ្ជាជីវៈភាពខ្ពស់ ដោយក្រុមហ៊ុនចុះបញ្ជីមានការកើនឡើង ផលិតផល និងសេវាផ្សេងៗ ត្រូវបានដាក់ឱ្យដំណើរការពេញលេញ និងមានភាពបត់បែនតាមតម្រូវការនៃទីផ្សារ និងជាប្រភពហិរញ្ញប្បទានដ៏សំខាន់ក្នុងតំបន់ សម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៣.១. ២. គោលបំណង

ដើម្បីចូលរួមគាំទ្រាជរដ្ឋាភិបាលសម្រេចបាននូវចក្ខុវិស័យ ២០៥០ ព្រមទាំងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥**" មានគោលបំណងរៀបចំនូវផែនទីបង្ហាញផ្លូវពេញលេញ សម្រាប់ការបន្តអភិវឌ្ឍទីផ្សារមូលបត្ររយៈពេល ១០ ឆ្នាំទៅមុខ ដើម្បីធានាថាទីផ្សារមូលបត្រកម្ពុជានឹងមានដំណើរការប្រកបដោយសណ្ដាប់ធ្នាប់ តម្លាភាព ជវភាព ភាពធន់ ចីរភាព និងនវានុវត្តន៍ ស្របតាមនិន្នាការវិវត្តន៍ និងឧត្តមានុវត្តន៍ក្នុងតំបន់និងសាកល។

### ៣.១. ៣. គោលដៅ

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ មានគោលដៅលើកកម្ពស់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាប្រកបដោយសណ្ដាប់ធ្នាប់ តម្លាភាព ជវភាព ភាពធន់ ចីរភាព និងនវានុវត្តន៍ តាមរយៈការជំរុញអនុវត្តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះ ៣ ដូចខាងក្រោម៖

- **ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រ៖** វិធានការយុទ្ធសាស្ត្រចំនួន ៤ រួមមាន ការពង្រឹងការបោះផ្សាយលក់មូលបត្រ និងការធ្វើពិពិធកម្មផលិតផលនិងសេវា, ការពង្រឹងមូលដ្ឋានវិនិយោគិន និងប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ, ការពង្រឹងសណ្ដាប់ធ្នាប់ទីផ្សារនិងហេដ្ឋារចនា-សម្ព័ន្ធទីផ្សារ និងការពង្រឹងប្រសិទ្ធភាពទីផ្សារ។
- **ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រីកទីផ្សារមូលបត្រ៖** វិធានការយុទ្ធសាស្ត្រចំនួន ៤ រួមមាន ការអភិវឌ្ឍហិរញ្ញវត្ថុចីរភាព, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបច្ចេកវិទ្យាឌីជីថល, ការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ និងការអភិវឌ្ឍក្របខ័ណ្ឌត្រួតពិនិត្យ។
- **ក្របខ័ណ្ឌយុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ៖** វិធានការយុទ្ធសាស្ត្រចំនួន ៥ រួមមាន ការកសាងសមត្ថភាព ការលើកកម្ពស់ចំណេះដឹង និងការអភិវឌ្ឍសមត្ថភាព, ការគ្រប់គ្រងនិងវិភាគទិន្នន័យ, ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងការចែករំលែកធនធាន, ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការពង្រឹងនិងពង្រីកសមត្ថភាពក្នុងការអនុវត្ត។

## ៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រគន្លឹះ

### ៣.២.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រ

#### ៣.២.១.១. វិធានការយុទ្ធសាស្ត្រពង្រឹងការបោះផ្សាយលក់មូលបត្រ និងការធ្វើពិពិធ-កម្មផលិតផល និងសេវា

ក្នុងស្ថានភាពបច្ចុប្បន្ន ការធ្វើពិពិធកម្មផលិតផល និងសេវាឱ្យមានភាពស៊ីជម្រៅ គឺជាគន្លឹះនៃការអភិវឌ្ឍវិស័យមូលបត្រប្រកបដោយចីរភាព ដែលនឹងផ្តល់ជម្រើសកាន់តែច្រើនដើម្បីបំពេញតម្រូវការរបស់អ្នកចូលរួមក្នុងទីផ្សារ សំដៅបង្កើតភាពសកម្មនិងបង្កើនសន្ទនីយភាពទីផ្សារ។ ដើម្បីសម្រេចបាននូវលទ្ធផលនេះ គឺត្រូវការបង្កើនចំនួនក្រុមហ៊ុនបោះផ្សាយនិងចុះបញ្ជីលក់មូលបត្រ តាមរយៈ៖

- ការរៀបចំប្រព័ន្ធអេកូឡូស៊ីសម្រាប់ការបោះផ្សាយនិងការចុះបញ្ជីលក់មូលបត្រឱ្យកាន់តែអំណោយផលក្នុងការទាក់ទាញ។ ក្នុងន័យនេះ ដំណើរការនៃការបោះផ្សាយនិងចុះបញ្ជីលក់មូលបត្រ និងលក្ខខណ្ឌតម្រូវ ត្រូវពិនិត្យឡើងវិញជាប្រចាំ ដើម្បីធានាថាអាចអនុវត្តបាន និងឆ្លើយតបនឹងការវិវត្តនៃទីផ្សារ
- ការផ្តល់ការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម តាមដំណាក់កាលលូតលាស់ ដើម្បីត្រៀមខ្លួនចុះបញ្ជីលក់មូលបត្រនាពេលអនាគត ដោយត្រូវបង្កើននូវជម្រើសហិរញ្ញប្បទានបន្ថែមដែលអាចឱ្យសហគ្រាសធុនតូចនិងមធ្យមមានលទ្ធភាពទទួលបានទុនបន្ថែមទៅតាមដំណាក់កាលលូតលាស់។ គំនិតផ្តួចផ្តើមទាំងនេះពិតជាមានសារៈសំខាន់ ព្រោះសហគ្រាសធុនតូចនិងមធ្យម ចូលរួមចំណែកយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ច និងតំណាងឱ្យបណ្តុំសាជីវកម្មរបស់កម្ពុជា ដែលមានសក្តានុពលសម្រាប់ការចុះបញ្ជីលក់មូលបត្រនៅថ្ងៃអនាគត
- ការរៀបចំសិក្ខាសាលា ដែលផ្តោតសំខាន់លើទិដ្ឋភាពបច្ចេកទេសដែលពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រសម្រាប់ក្រុមហ៊ុនចុះបញ្ជីសក្តានុពល។

ក្រៅពីការចុះបញ្ជីលក់មូលបត្រនៅ **ផមក** ដែលមានចំនួនតិច សកម្មភាពទីផ្សារក៏នៅមានកម្រិតផងដែរ ដែលតម្រូវឱ្យមានដំណោះស្រាយតាមរយៈ៖

- ការដាក់ឱ្យអនុវត្តនូវគំនិតផ្តួចផ្តើមដែលបង្កើនបរិយាកាសអំណោយផល ដើម្បីទាក់ទាញការប្រមូលទុនដោយស្ថាប័ននានាកាន់តែច្រើន និងធ្វើពិពិធកម្មផលិតផលសម្រាប់វិនិយោគឱ្យកាន់តែច្រើន
- ការជំរុញឱ្យមានការបោះផ្សាយនិងចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មឱ្យបានកាន់តែច្រើន
- ការដាក់ឱ្យដំណើរការនូវផ្នែកថ្មីៗ ដើម្បីពន្លឿនការអភិវឌ្ឍ ដូចជា ការអភិវឌ្ឍផលិតផល, ការគ្រប់គ្រងមូលនិធិ និងការប្រឹក្សាវិនិយោគ ដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីរួម។

ជារួម ការដាក់ចេញនូវផលិតផលនិងសេវាថ្មីៗ នឹងត្រូវធ្វើឡើងជាដំណាក់កាល ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ ស្របជាមួយការត្រៀមខ្លួននៃទីផ្សារ និងអនុញ្ញាតឱ្យមានការយល់ដឹង និងការអប់រំឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យស្គាល់ពីផលិតផលនិងសេវាទាំងនោះ។ ផលិតផលថ្មីៗ

បន្ថែមនៃទីផ្សារមូលនិធិនឹងត្រូវដាក់ចេញក្នុងរយៈពេលខ្លី ខណៈដែលផលិតផលឌុម៉ូឌីជីអនាគត និងឧបករណ៍និស្សន្ទហិរញ្ញវត្ថុបន្ថែមដែលមានភាពស្មុគស្មាញ នឹងត្រូវដាក់ចេញក្នុងរយៈពេលមធ្យម។

#### ៣.២.១.២. វិធានការយុទ្ធសាស្ត្រពង្រឹងមូលដ្ឋានវិនិយោគិន និងប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ

មូលដ្ឋានវិនិយោគិនធំទូលាយ គឺជាកត្តាដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍវិស័យមូលបត្ររយៈពេលវែង ក៏ប៉ុន្តែការចូលរួមរបស់វិនិយោគិននាពេលបច្ចុប្បន្ននៅមានកម្រិត ដែលតម្រូវឱ្យមានដំណោះស្រាយតាមរយៈ៖

- ការយកចិត្តទុកដាក់ខ្ពស់លើការបំពេញតម្រូវការរបស់វិនិយោគិនរូបវន្តបុគ្គលទាំងអស់ដែលរួមមាន វិនិយោគិនធនវន្តខ្ពស់(high-net-worth) និងវិនិយោគិនរូបវន្តបុគ្គលទូទៅ
- ការដាក់ចេញនូវគំនិតផ្តួចផ្តើម ដើម្បីទាក់ទាញការចូលរួមរបស់វិនិយោគិនស្ថាប័នឱ្យកាន់តែច្រើន ដូចខាងក្រោម៖
    - ដាក់ចេញយន្តការដែលពង្រឹងទំនុកចិត្តស្ថាប័នបរទេសឱ្យចូលរួមយ៉ាងសកម្មក្នុងទីផ្សារមូលបត្រកម្ពុជាក្នុងរយៈពេលខ្លី មធ្យម និងវែង និងរៀបចំធ្វើរ៉ូដស្ហូ (Roadshows) នៅមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗ ដើម្បីបង្ហាញពីសក្តានុពលនិងកាលានុវត្តភាពវិនិយោគក្នុងវិស័យមូលបត្រនៅកម្ពុជា ព្រមទាំងពិនិត្យបញ្ចូលសន្ទស្សន៍ទីផ្សារមូលបត្រកម្ពុជាក្នុងសន្ទស្សន៍ទីផ្សារអន្តរជាតិ
    - លើកទឹកចិត្តដល់ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ដើម្បីវិនិយោគកាន់តែច្រើនក្នុងទីផ្សារមូលបត្រ
    - ពិនិត្យឡើងវិញនូវលក្ខខណ្ឌតម្រូវសម្រាប់ក្រុមហ៊ុនចុះបញ្ជី និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដើម្បីធានាបាននូវឧត្តមានុវត្តន៍លើផ្នែកដូចជា អភិបាលកិច្ចសាជីវកម្ម ការបង្ហាញព័ត៌មានសាជីវកម្ម និងការរាយការណ៍របាយការណ៍ហិរញ្ញវត្ថុ ដើម្បីពង្រឹងទំនុកចិត្តវិនិយោគិនស្ថាប័ន
- ការបង្កើតមូលនិធិអភិវឌ្ឍន៍ទីផ្សារមូលបត្រដើម្បីជំរុញសន្ទនីយភាពទីផ្សារ និងលើកកម្ពស់ការអភិវឌ្ឍទីផ្សារ។ ទន្ទឹមនឹងនេះ **ន.ម.ក.** ក៏នឹងសិក្សាពីយន្តការនៃការចូលរួមរបស់មូលនិធិទ្រព្យសម្បត្តិរដ្ឋក្នុងទីផ្សារមូលបត្រ ផងដែរ។

ដូចនេះ វិធានការដែលដាក់ចេញ នឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើនភាពទាក់ទាញវិនិយោគិនថ្មីៗ និងភាពចម្រុះនៃប្រភេទវិនិយោគិន ដែលបង្ហាញនូវសក្តានុពលរឹងមាំក្នុងការជំរុញការអភិវឌ្ឍវិស័យមូលបត្រ។

ការពង្រឹងនិងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ នឹងជួយសម្រួលដល់ដំណើរការជួញដូរមូលបត្រ និងបង្កើតបទពិសោធន៍នៃការវិនិយោគងាយស្រួលដែលនឹងទាក់ទាញការចូលរួមរបស់វិនិយោគិនកាន់តែច្រើន តាមរយៈ៖

- ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា
- ការផ្តល់ការលើកទឹកចិត្ត ដើម្បីជំរុញការជួញដូរ
- ការផ្តល់ព័ត៌មានទាន់ពេលនិងទូលំទូលាយ ដើម្បីឱ្យវិនិយោគិនធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ តួយ៉ាង៖
    - ប្រើប្រាស់បណ្តាញផ្សព្វផ្សាយ ដើម្បីចែកចាយព័ត៌មានសំខាន់ៗ និងការវិវត្តថ្មីៗនៃទីផ្សារមូលបត្រ
    - បង្កើតផលិតផលសម្រាប់ផ្តល់ព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងការវិនិយោគ និងហិរញ្ញវត្ថុ
    - ពង្រឹងទំនាក់ទំនងរវាងក្រុមហ៊ុនចុះបញ្ជី និងវិនិយោគិន ដើម្បីពង្រឹងទំនុកចិត្ត និងទាក់ទាញ ឱ្យមានការចូលរួមវិនិយោគកាន់តែច្រើន

ជាមួយនឹងការចែកចាយព័ត៌មានកាន់តែទូលំទូលាយ ត្រូវត្រួតពិនិត្យឱ្យបានហ្មត់ចត់ និងត្រូវចាត់វិធានការឱ្យបានសមស្រប (ការកែតម្រូវ ឬដាក់ទណ្ឌកម្ម) ទៅលើព័ត៌មានដែលមិនត្រឹមត្រូវ ដើម្បីធានានូវសុចរិតភាពទីផ្សារ។

### ៣.២.១.៣. វិធានការយុទ្ធសាស្ត្រពង្រឹងសណ្តាប់ធ្នាប់ទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ

និយ័តករមានទំនួលខុសត្រូវចម្បងក្នុងការធានាសណ្តាប់ធ្នាប់ទីផ្សារ និងរក្សាបាននូវសុចរិតភាពទីផ្សារ។ នៅពេលចូលរួមវិនិយោគក្នុងវិស័យមូលបត្រ វិនិយោគិនទាមទារឱ្យមាននូវការការពារសិទ្ធិ។ ដូចនេះ យន្តការការពារវិនិយោគិន ត្រូវពង្រឹងឱ្យកាន់តែរឹងមាំ តាមរយៈ៖

- ការពិនិត្យឡើងវិញនូវយន្តការនៃការដាក់ពិន័យដែលកំពុងអនុវត្ត ដើម្បីធានាថាយន្តការនោះមានប្រសិទ្ធភាព
- ការពិនិត្យឡើងវិញនូវមុខងារផ្សះផ្សា និងដោះស្រាយវិវាទ និងកែលម្អបន្ថែមតាមការចាំបាច់
- ការបង្កើតមជ្ឈមណ្ឌលដោះស្រាយវិវាទឯករាជ្យ
- ការពិនិត្យលទ្ធភាពក្នុងការបង្កើតមូលនិធិការពារវិនិយោគិន
- ការតម្រូវឱ្យអន្តរការីមូលបត្រពិនិត្យឡើងវិញជាប្រចាំនូវនីតិវិធីនៃការដោះស្រាយបណ្តឹងរបស់អតិថិជន ដើម្បីធានាបាននូវប្រសិទ្ធភាព
- ការតម្រូវឱ្យបុគ្គលិកជំនាញផ្នែកច្បាប់នៃអន្តរការីមូលបត្រអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីការពារវិនិយោគិន
- ការពង្រឹងការធ្វើនិយ័តកម្ម និងសមត្ថភាពក្នុងការពង្រឹងការអនុវត្តច្បាប់ រួមបញ្ចូលទាំងកិច្ច-សហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ ដោយស្ថាប័នពាក់ព័ន្ធនឹងផ្តល់កិច្ចសហការបានទាន់ពេលវេលា មានប្រសិទ្ធភាព និងជាប្រចាំ ចំពោះសកម្មភាពទាំងឡាយណាដែលល្មើសនឹងបទប្បញ្ញត្តិ ដើម្បីពង្រឹងទំនុកចិត្តវិនិយោគិន

អន្តរការីមូលបត្រក៏មានទំនួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់ទីផ្សារផងដែរ។ អន្តរការីមូលបត្រត្រូវបន្តនិរន្តរភាពអាជីវកម្ម ដែលរួមទាំងការបំពេញលក្ខខណ្ឌតម្រូវមុនប្រតិបត្តិការ និងបន្តរក្សាអនុលោម-

ភាពតាមបទប្បញ្ញត្តិ ក៏ដូចជាចាប់យកគំរូអាជីវកម្មប្រុងប្រយ័ត្នផ្នែកហិរញ្ញវត្ថុ និងមានគោលនយោបាយគ្រប់គ្រងហានិភ័យសមស្រប ព្រមទាំងត្រូវមានបុគ្គលិកជំនាញផ្នែកច្បាប់ និងធនធានគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ។ **ន.ម.ក.** ត្រូវដាក់ចេញនូវអភិក្រមត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់អន្តរការីមូលបត្រ។

ដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារជារួម **ន.ម.ក.** នឹងធ្វើការវិភាគគ្រប់ជ្រុងជ្រោយនៃខ្សែសង្វាក់ប្រតិបត្តិការទីផ្សារ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីពិនិត្យលទ្ធភាពរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារឡើងវិញ ដើម្បីឱ្យការចូលទៅក្នុងទីផ្សារកាន់តែងាយស្រួល។ ការធ្វើទំនើបកម្មបច្ចេកវិទ្យា និងការកាត់បន្ថយហានិភ័យនៃការផាត់ទាត់និងទូទាត់ នឹងធ្វើឱ្យទីផ្សារមូលបត្រកម្ពុជាក្លាយជាទីផ្សារមួយដែលមានសន្ទនីយភាពខ្ពស់។

### ៣.២.១.៤. វិធានការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពទីផ្សារ

ការចូលរួមក្នុងទីផ្សារ ត្រូវតែមានការចំណាយ ដែលរួមមានកម្រៃសេវា និងចំណាយផ្សេងៗសម្រាប់ការបោះផ្សាយលក់មូលបត្រ, វិនិយោគិន និងអន្តរការីមូលបត្រ។ ដូចនេះ ការប្រកួតប្រជែងថ្លៃ នឹងជំរុញឱ្យមានការចូលរួមកាន់តែច្រើន និងជំរុញឱ្យទីផ្សារមានប្រសិទ្ធភាពនិងមានភាពរស់រវើក តាមរយៈ៖

- ការវាយតម្លៃថ្លៃចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងការចូលរួមក្នុងទីផ្សារមូលបត្រ
- ការសិក្សាស្រាវជ្រាវលើវិធានការដែលអាចរួមចំណែកដល់ការកាត់បន្ថយចំណាយ ដោយរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យាកាន់តែច្រើន
- ការសិក្សាលើការកំណត់រចនាសម្ព័ន្ធថ្លៃដែលមានភាពប្រកួតប្រជែងជាងមុន
- ការវាយតម្លៃពីប្រភេទនៃការលើកទឹកចិត្តដែលសមស្រប ដូចជាការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ ឬមិនមែនហិរញ្ញវត្ថុ, អចិន្ត្រៃយ៍ ឬក្នុងរយៈពេលកំណត់ណាមួយ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អន្តរការីមូលបត្រ និង/ឬវិនិយោគិន
- ការពិនិត្យលទ្ធភាពនៃការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់វិស័យមូលបត្ររយៈពេលវែង
- ការកំណត់អត្តសញ្ញាណផ្នែកទីផ្សារជាក់លាក់ដែលនឹងត្រូវផ្តល់ការលើកទឹកចិត្ត និងផ្តល់អាទិភាព ដល់ផ្នែកដែលមានសក្តានុពលនៃកំណើនខ្លាំងបំផុត និង/ឬឥទ្ធិពលជាវិជ្ជមានបំផុតលើការអភិវឌ្ឍជារួមនៃវិស័យមូលបត្រ
- ការដោះស្រាយបញ្ហាសំខាន់ៗ រួមមាន បញ្ហាទាក់ទងនឹងកាតព្វកិច្ចពន្ធដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

## ៣.២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រីកទីផ្សារមូលបត្រ

### ៣.២.២.១. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍហិរញ្ញវត្ថុចីរភាព

ហិរញ្ញវត្ថុចីរភាពក្លាយជាផ្នែកដែលកាន់តែសំខាន់ក្នុងវិស័យហិរញ្ញវត្ថុ ដូចនេះទាមទារនូវការជំរុញការអភិវឌ្ឍផ្នែកនេះក្នុងវិស័យមូលបត្រ ដែលយន្តការនៃការអភិវឌ្ឍគួរតែមានលក្ខណៈរួម ដើម្បីធានាថាភាគីពាក់ព័ន្ធមានភាពងាយស្រួលក្នុងការទទួលបានហិរញ្ញប្បទាន និងការវិនិយោគប្រកបដោយចីរភាព

ដែលសមស្របនឹងតម្រូវការ ឬលក្ខខណ្ឌរបស់ពួកគេ។ ដូចនេះ ការអភិវឌ្ឍទីផ្សារមូលបត្រចីរភាព នឹងផ្តោតទៅលើទាំងផ្នែកអភិវឌ្ឍន៍ និងនិយ័តកម្ម ដូចជា៖

- បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសមស្រប ដើម្បីសម្រួលដល់ការបោះផ្សាយលក់មូលបត្រដោយផ្អែកលើចីរភាព ដែលផ្តោតសំខាន់លើសញ្ញាបណ្ណ និងមូលនិធិនៃគម្រោងវិនិយោគរួម
- រៀបចំក្របខ័ណ្ឌរួមសម្រាប់ហិរញ្ញវត្ថុអន្តរកាលដើម្បីគាំទ្រសកម្មភាពអន្តរកាល ដែលអនុញ្ញាតឱ្យធុរកិច្ចនិងឧស្សាហកម្មអាចវិវត្តខ្លួនឈានឆ្ពោះទៅគោលដៅចីរភាពរបស់ប្រទេស ដូចជាស្តង់ដានៃការបង្ហាញព័ត៌មាន ដែលអនុលោមតាមស្តង់ដាក្នុងតំបន់ ឬអន្តរជាតិ ឬឧត្តមានុវត្តន៍ ដើម្បីទាក់ទាញវិនិយោគិន ឬស្ថាប័នបរទេស
- សិក្សាពីលទ្ធភាពនៃការអភិវឌ្ឍទីផ្សារកាបូនស្ម័គ្រចិត្ត ហិរញ្ញវត្ថុផ្អែកលើធម្មជាតិ (Nature-Based Finance) និងការធ្វើហិរញ្ញប្បទានចម្រុះ (Blended Finance) ដើម្បីពង្រីកបន្ថែមផ្នែកហិរញ្ញវត្ថុចីរភាព
- ចូលរួមបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គម្រោងដែលពាក់ព័ន្ធនឹងចីរភាព ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់អ្នកចូលរួមក្នុងទីផ្សារ ក៏ដូចជាអភិវឌ្ឍទីផ្សារមូលបត្រចីរភាព
- ចូលរួមគំនិតផ្តួចផ្តើមនៃការបង្កើតទិន្នន័យដើម្បីសម្រួលដល់ការប្រមូលនិងគ្រប់គ្រងទិន្នន័យ និងការបង្ហាញព័ត៌មានចីរភាព
- រៀបចំក្របខ័ណ្ឌនៃការបង្ហាញព័ត៌មានចីរភាព ស្របតាមក្របខ័ណ្ឌអន្តរជាតិដែល **ន.ម.ក.** នឹងធ្វើការវាយតម្លៃពីតម្រូវការថ្នាលទិន្នន័យដើម្បីគាំទ្រដល់ការរាយការណ៍ និងការបង្ហាញព័ត៌មានចីរភាព
- រៀបចំកម្មវិធីកសាងសមត្ថភាព និងចែករំលែកចំណេះដឹងដើម្បីបង្កើនការយល់ដឹងផ្នែកបច្ចេកទេសហិរញ្ញវត្ថុចីរភាពដល់អ្នកចូលរួមក្នុងទីផ្សារ
- បង្កើតមជ្ឈមណ្ឌលចំណេះដឹងពាក់ព័ន្ធនឹងហិរញ្ញវត្ថុចីរភាព
- បង្កើតកិច្ចសហប្រតិបត្តិការរវាងសមាគមក្នុងវិស័យមូលបត្រក្នុងតំបន់
- វាយតម្លៃដើម្បីកំណត់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ឬមិនមែនហិរញ្ញវត្ថុដែលសមស្រប ដើម្បីពន្លឿនការអភិវឌ្ឍហិរញ្ញវត្ថុចីរភាពជារួម ឬសម្រាប់ផ្នែកជាក់លាក់ណាមួយ
- សិក្សាពីសក្តានុពលនៃការបោះផ្សាយលក់សញ្ញាបណ្ណបៃតងរបស់រដ្ឋាភិបាល។

ការបោះផ្សាយលក់មូលបត្ររដ្ឋ នឹងពង្រឹងរបៀបវារៈជាតិ និងដើរតួជាស្តង់ដាគោលសម្រាប់ទីផ្សារ។ ភាគីពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ, អន្តរការីមូលបត្រ និងវិនិយោគិន ត្រូវទទួលខុសត្រូវជាចម្បងក្នុងការជំរុញកំណើនហិរញ្ញវត្ថុចីរភាព តាមរយៈការបង្កើតឱ្យមានការផ្គត់ផ្គង់ និងតម្រូវការសម្រាប់ផលិតផលនិងសេវាទាំងនោះ។

### ៣.២.២.២. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបច្ចេកវិទ្យាឌីជីថល

បច្ចេកវិទ្យាត្រូវបានប្រើប្រាស់សម្រាប់តភ្ជាប់វិស័យផ្សេងៗ និងបំពេញមុខងារសេវាហិរញ្ញវត្ថុដែល

បង្កើតជាកាលានុវត្តភាពនៃការរីកចម្រើនផ្សេងៗ ប៉ុន្តែក៏បានបង្កើតភាពស្មុគស្មាញសម្រាប់ការធ្វើនិយ័តកម្មផងដែរ។ ដូចនេះ វិធានការពាក់ព័ន្ធនឹងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបច្ចេកវិទ្យាឌីជីថល គួរត្រូវបានដាក់ចេញដូចខាងក្រោម៖

- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ
- សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ និងផ្នែកជាក់លាក់ដូចជា ហិរញ្ញវត្ថុវិមជ្ឈការ (DeFi)
- ដាក់ចេញនូវបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ និងបង្កើតក្រុមអ្នកជំនាញពហុភាគីបច្ចេកវិទ្យាហិរញ្ញវត្ថុ (Multi-Stakeholder FinTech Think Tank) ដើម្បីជំរុញការចាប់យកនវានុវត្តន៍
- រៀបចំកម្មវិធីកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយសហការជាមួយភាគីពាក់ព័ន្ធទាំងវិស័យសាធារណៈនិងឯកជន
- បង្កើតកិច្ចសហការជាមួយនិយ័តករ និងយុត្តាធិការក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍
- អភិវឌ្ឍ និងបន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
- ជំរុញការធ្វើស្វ័យប្រវត្តិកម្ម ដើម្បីបង្កើនប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន ដូចខាងក្រោម៖
  - វាយតម្លៃលម្អិត ដើម្បីកំណត់ផ្នែកសក្តានុពលជាអាទិភាពសម្រាប់ការរៀបចំស្វ័យ-ប្រវត្តិកម្មដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា
  - ផ្ទៀងផ្ទាត់លទ្ធផលវាយតម្លៃជាមួយនឹងការត្រៀមខ្លួនរួចរាល់របស់ទីផ្សារ សម្រាប់ការចាប់យកបច្ចេកវិទ្យាដែលពាក់ព័ន្ធ ដើម្បីធានាបាននូវសង្គតិភាព
  - ផ្តល់ការលើកទឹកចិត្ត និងការគាំទ្រដើម្បីសម្រួលដល់ការអនុវត្តតាមស្ថានភាពជាក់ស្តែង
  - ត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាព និងឥទ្ធិពលនៃស្វ័យប្រវត្តិកម្មសម្រាប់ការកែលម្អ និងកែសម្រួលទៅលើយុទ្ធសាស្ត្ររួម។

ទន្ទឹមនឹងការកើនឡើងនៃការពឹងផ្អែកលើបច្ចេកវិទ្យា អន្តរការីមូលបត្រត្រូវមានគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាឱ្យបានសមស្រប។ ក្របខ័ណ្ឌបទប្បញ្ញត្តិ RegTech និង SupTech ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តជាដំណាក់កាល ដើម្បីសម្រួលដល់ការចាប់យក RegTech និង SupTech សម្រាប់និយ័តករ និងអន្តរការីមូលបត្រ។ ដើម្បីសម្រេចបាននូវគំនិតផ្តួចផ្តើមទាំងនេះ ភាគីពាក់ព័ន្ធ ត្រូវត្រៀមថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង។

ដើម្បីគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសន្តិសុខសាយប័រក្នុងវិស័យមូលបត្រ និងហានិភ័យពាក់ព័ន្ធដែលកំពុងកើតមាន **ន.ម.ក.** ត្រូវដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដូចជា ការប្រមូលទិន្នន័យ និងការសិក្សាសមិទ្ធិលទ្ធភាពនៃការស្នើសុំជំនួយបច្ចេកទេសពីអ្នកជំនាញការ។ ដោយផ្អែកនេះជានិន្នាការថ្មី

**ន.ម.ក.** ត្រូវបង្កើតក្រុមការងារជំនាញផ្នែកគ្រប់គ្រងហានិភ័យ ដើម្បីទទួលបន្ទុកពិនិត្យលម្អិត។ កិច្ចសហប្រតិបត្តិការជាមួយនិយ័តករទូរគមនាគន៍ និងស្ថាប័នពាក់ព័ន្ធលើសន្តិសុខសាយប័រ ត្រូវបន្តពង្រឹងបន្ថែម។

### ៣.២.២.៣. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ

ក្របខ័ណ្ឌបទប្បញ្ញត្តិរឹងមាំ គឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍវិស័យមូលបត្រប្រកបដោយសណ្តាប់ធ្នាប់។ ដូចនេះ ស្របជាមួយនឹងគំនិតផ្តួចផ្តើមនៃការធ្វើពិពិធកម្មផលិតផលនិងសេវាក្នុងវិស័យមូលបត្រ **ន.ម.ក.** ចាំបាច់ត្រូវ៖

- បង្កើតក្របខ័ណ្ឌ និងគោលការណ៍ណែនាំសម្រាប់ផលិតផលឬសេវាជាក់លាក់ ដែលឆ្លើយតបនឹងតម្រូវការ និងធ្វើឱ្យមានតុល្យភាពរវាងការធ្វើនិយ័តកម្មនិងការអភិវឌ្ឍ ដោយត្រូវកំណត់ថាជាកាតព្វកិច្ច ឬជាការលើកទឹកចិត្ត ដើម្បីសម្រួលដល់អនុលោមភាព
- ដាក់ចេញនូវគោលការណ៍ណែនាំដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើន និងសម្របសម្រួលឱ្យមានអន្តរប្រតិបត្តិការ។

ខណៈពេលដែលការពង្រីកផលិតផលនិងសេវាកំពុងបន្តអនុវត្ត ការវាយតម្លៃពីភាពរួចរាល់របស់ទីផ្សារ គឺជាកត្តាសំខាន់នៅក្នុងការសម្រេចចិត្តពីពេលវេលាសមស្របសម្រាប់ដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិជាក់លាក់ តាមរយៈ៖

- ការបង្កើតវេទិកាសន្ទនា និងពិគ្រោះយោបល់ជាទៀងទាត់រវាងនិយ័តករនិងភាគីពាក់ព័ន្ធក្នុងទីផ្សារ ដើម្បីចែករំលែកទស្សនៈ និងការប្រមើលមើលនិន្នាការនិងតម្រូវការទីផ្សារ
- ការរៀបចំផែនការអភិវឌ្ឍន៍ក្របខ័ណ្ឌបទប្បញ្ញត្តិច្បាស់លាស់ ពោលគឺការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិទាំងឡាយណាដែលស្មុគស្មាញ ត្រូវគិតគូរពីចម្ងាយដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការងារនេះដោយជោគជ័យ ដែលមានដូចជា ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ទីផ្សារខុម៉ូឌីធីអនាគត និងទីផ្សារឧបករណ៍និស្សន្ទហិរញ្ញវត្ថុបន្ថែម
- ការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិដើម្បីពង្រីកផលិតផលនិងសេវាផ្សេងទៀត (ឧទាហរណ៍៖ មូលនិធិចុះបញ្ជី និងទ្រព្យឌីជីថលជាដើម) និងលើកកម្ពស់ផលិតផលឬសេវាដែលមានស្រាប់ (ឧទាហរណ៍៖ ការជួញដូរមូលបត្រតាមម៉ាជីន, ហិរញ្ញប្បទានពីបុគ្គលទៅបុគ្គលដែលពាក់ព័ន្ធនឹងមូលបត្រ និងប្រេកនៃការចែកចាយលក់មូលបត្រ)
- ការបង្កើនសមត្ថភាពនិងភាពរហ័សរហួនក្នុងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលមិនបានគ្រោងទុកជាមុន ដើម្បីដាក់ចេញនូវផលិតផលឬសេវាថ្មីៗដែលឆ្លើយតបនឹងតម្រូវការនិងការអភិវឌ្ឍនៃទីផ្សារ។

### ៣.២.២.៤. វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌត្រួតពិនិត្យ

ការត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួនលើផលិតផល សេវា និងអ្នកចូលរួមក្នុងទីផ្សារ គឺជាតួនាទីដ៏សំខាន់របស់ **ន.ម.ក.**។ ការធ្វើនិយ័តកម្មដោយផ្អែកលើហានិភ័យ គួរតែដាក់ឱ្យអនុវត្តដើម្បីបង្កើតនូវបរិយាកាសធុរកិច្ចដែលមានតុល្យភាព និងធ្វើឱ្យការត្រួតពិនិត្យនិងការឃ្លាំមើលអនុលោមភាពកាន់តែមានប្រសិទ្ធភាព។

ក្នុងន័យនេះ ឧបករណ៍ត្រួតពិនិត្យដ៏សំខាន់មួយសម្រាប់និយ័តករ គឺត្រូវមានក្របខ័ណ្ឌគ្រប់គ្រងហានិភ័យពេញលេញ ដូចខាងក្រោម៖

- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យផ្អែកលើហានិភ័យចំពោះប្រតិបត្តិករទីផ្សារ
- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យផ្អែកលើហានិភ័យចំពោះអន្តរការីមូលបត្រ ដើម្បីធានាថាការអភិវឌ្ឍនិងការធ្វើនិយ័តកម្មទីផ្សារប្រព្រឹត្តទៅដោយសណ្តាប់ធ្នាប់ល្អ
- បង្កើតក្របខ័ណ្ឌសមស្រប និងសមត្ថភាពនៃការកំណត់និងការគ្រប់គ្រងការប្រព្រឹត្តល្មើសក្នុងទីផ្សារ ដោយការកើនឡើងនៃហានិភ័យដែលពាក់ព័ន្ធ។ ក្នុងន័យនេះ បទប្បញ្ញត្តិនឹងត្រូវដាក់ចេញដើម្បីបង្ការ ខណៈដែលប្រព័ន្ធឃ្លាំមើលនឹងត្រូវដាក់ឱ្យដំណើរការសម្រាប់កំណត់អត្តសញ្ញាណ និងស្វែងរកសកម្មភាពប្រព្រឹត្តល្មើសឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រព្រឹត្តល្មើសក្នុងទីផ្សារ ដូច្នេះ កិច្ចសហប្រតិបត្តិការត្រូវមានជាចាំបាច់ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីកាត់បន្ថយហានិភ័យ និងដើម្បីគ្រប់គ្រងករណីដែលអាចកើតមានប្រកបដោយប្រសិទ្ធភាព។

### ៣.២.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ

#### ៣.២.៣.១. វិធានការយុទ្ធសាស្ត្រកសាងសមត្ថភាព លើកកម្ពស់ចំណេះដឹង និងអភិវឌ្ឍសមត្ថភាព

**ន.ម.ក.** និងអន្តរការីមូលបត្រ បាននិងកំពុងបន្តអនុវត្តគំនិតផ្តួចផ្តើមលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងអក្ខរកម្មហិរញ្ញវត្ថុ ប៉ុន្តែនៅតែទាមទារនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដោយត្រូវមានការចូលរួមកាន់តែទូលំទូលាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងស្ថានភាពអភិវឌ្ឍន៍នៃវិស័យមូលបត្រ។ វិធានការដែលត្រូវដាក់ចេញមានដូចខាងក្រោម៖

- បង្កើតក្រុមប្រឹក្សាអក្ខរកម្មហិរញ្ញវត្ថុដោយមានការចូលរួមពីភាគីពាក់ព័ន្ធ
- ដាក់បញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងវិស័យមូលបត្រក្នុងកម្មវិធីសិក្សា សម្រាប់សិស្សានុសិស្ស និងយុវជន ដែលក៏នឹងផ្តោតទៅលើក្មេងស្រី និងស្ត្រីវ័យក្មេងដែរ
- បោះពុម្ពផ្សាយឯកសារអំពីវិស័យមូលបត្រ និងផ្នែកពាក់ព័ន្ធផ្សេងៗទៀតដែលងាយស្រួលអាន
- បង្កើតគំនិតផ្តួចផ្តើមផ្សេងៗដែលធ្វើឱ្យការរៀនសូត្រកាន់តែទាក់ទាញ ដូចជាការប្រកួតជួញដូរមូលបត្រ ដែលអាចជួយបង្កើនការយល់ដឹងនិងផ្តល់បទពិសោធន៍អំពីដំណើរការជួញដូរមូលបត្រ
- បង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលដើម្បីពង្រឹងនិងពង្រីកនូវទំនាក់ទំនង និងការចែករំលែកចំណេះដឹងបន្តកាន់តែទូលំទូលាយ និងគាំទ្រដល់គំនិតផ្តួចផ្តើមខាងលើឱ្យកាន់តែមានប្រសិទ្ធភាព
- ដាក់ចេញនូវគំនិតផ្តួចផ្តើមនានាក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការឬក្រុមគោលដៅផ្សេងៗ
- បង្កើតកម្មវិធីដែលមានភាពស្មុគស្មាញ និងស៊ីជម្រៅ ដើម្បីឆ្លើយតបទៅនឹងកម្រិតនៃការយល់ដឹង

ផ្សេងៗគ្នា

- អនុវត្តគំនិតផ្តួចផ្តើមនិងកម្មវិធីទាំងនេះជាប្រចាំ និងបន្តធ្វើជាអចិន្ត្រៃយ៍ក្នុងរយៈពេលវែង ដើម្បីឱ្យមានប្រសិទ្ធភាព។ មាតិកានៃកម្មវិធីត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំ ដើម្បីធានាថាភាគីពាក់ព័ន្ធទទួលបាននូវចំណេះដឹងពីការវិវត្តថ្មីៗក្នុងវិស័យមូលបត្រ
- ប្រើប្រាស់បណ្ដាញសង្គម និងបណ្ដាញផ្សព្វផ្សាយផ្សេងទៀត សម្រាប់អនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងការផ្សាយពាណិជ្ជកម្មនានា ដើម្បីទាក់ទាញចំណាប់អារម្មណ៍ភាគីពាក់ព័ន្ធ
- បង្កើតវិទ្យាស្ថានជាតិមូលបត្រ
- ប្រើប្រាស់បច្ចេកវិទ្យាដើម្បីគាំទ្រការអនុវត្តកម្មវិធីទាំងនេះ។

ដោយវិស័យមូលបត្រកំពុងប្រឈមនឹងការខ្វះខាតអ្នកដែលមានជំនាញ ដូចនេះដើម្បីធានានូវការអភិវឌ្ឍវិស័យមូលបត្រប្រកបដោយចីរភាព គឺទាមទារជាចាំបាច់នូវការកសាងនូវអ្នកជំនាញការដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ។ ក្រៅពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ត្រូវការនូវការអភិវឌ្ឍធនធានមនុស្សក្នុងផ្នែកចំណេះដឹងផ្សេងៗទៀត ដូចជា ច្បាប់ គណនេយ្យ ការវិភាគទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន ជាដើម។ ក្នុងន័យនេះ **ន.ម.ក.** ត្រូវៈ

- បង្កើតឬពង្រីកបន្ថែមនូវកិច្ចសហការជាមួយភាគីពាក់ព័ន្ធក្នុងវិស័យ និងស្ថាប័នសិក្សាពាក់ព័ន្ធ ជាពិសេសសាកលវិទ្យាល័យ និងវិទ្យាស្ថានបច្ចេកទេស ដើម្បីផ្ដល់នូវជំនាញ និងចំណេះដឹងសមស្រប
- បន្តអនុវត្តការពង្រឹងនិងពង្រីកកម្មវិធីសិក្សា ដើម្បីបញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងវិស័យមូលបត្រ ក្នុងន័យបណ្តុះធនធានមនុស្សសក្តានុពល នៅពេលដែលពួកគេចូលទៅក្នុងទីផ្សារការងារ
- រៀបចំកម្មវិធីបណ្ដុះបណ្ដាលសម្រាប់អ្នកដែលកំពុងបម្រើការងារក្នុងវិស័យនេះ ដើម្បីទទួលបាននូវជំនាញបន្ថែម និងចំណេះដឹងថ្មីៗ សំដៅបំពេញការងារក្នុងវិស័យមូលបត្រប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈខ្ពស់។ វិស័យមូលបត្រត្រូវការជំនាញជាច្រើនកម្រិតផ្សេងៗទៀត ដើម្បីបំពេញតួនាទី និងមុខងារផ្សេងៗ ទៅតាមកម្រិតនិងប្រភេទនៃការងារ ដូច្នេះ កម្មវិធីបណ្ដុះ-បណ្ដាលត្រូវរៀបចំបំពេញទៅតាមតម្រូវការ និងស្ថានភាពជាក់ស្តែង
- គាំទ្របរិយាបន្នហិរញ្ញវត្ថុស្ត្រី ដោយពិចារណារៀបចំកម្មវិធីលើកកម្ពស់ស្តង់ដាក្នុងវិស័យដើម្បីប្រមូល និងប្រើប្រាស់ទិន្នន័យដែលបែងចែកតាមភេទ ដើម្បីពង្រឹងការវិភាគយេនឌ័រ និងពង្រីកកាលានុវត្តភាពសម្រាប់សមភាពយេនឌ័រក្នុងវិស័យមូលបត្រ
- ពង្រឹងការចូលរួម និងសមត្ថភាពជាអ្នកដឹកនាំរបស់ស្ត្រីដែលប្រកបវិជ្ជាជីវៈជំនាញក្នុងវិស័យមូលបត្រ
- ទាក់ទាញអ្នកជំនាញវិជ្ជាជីវៈពីទីផ្សារបរទេស ដើម្បីបំពេញនូវចន្លោះខ្វះខាតចំពោះមុខ
- ពិនិត្យលទ្ធភាពផ្តល់ការលើកទឹកចិត្តសម្រាប់អ្នកមានជំនាញដើម្បីចូលរួមក្នុងវិស័យមូលបត្រ។

ការកសាងសមត្ថភាព និងការអភិវឌ្ឍទេពកោសល្យ ត្រូវអនុវត្តជារួមដោយភាគីពាក់ព័ន្ធក្នុងវិស័យ

មូលបត្រ ដោយសារអត្ថប្រយោជន៍នឹងទទួលបានជាក្រុមក្នុងរយៈពេលមធ្យមទៅវែង។ កិច្ចសហការរបស់ស្ថាប័នដែលផ្តល់កម្មវិធីសិក្សានឹងធ្វើឱ្យគំនិតផ្តួចផ្តើមទាំងនេះកាន់តែមានប្រសិទ្ធភាព ដោយសារកិច្ចខិតខំប្រឹងប្រែងមានភាពស្របគ្នា, ធនធានត្រូវបានប្រមូលផ្តុំ និងសារសំខាន់ៗត្រូវបានពង្រឹងបន្ថែម។

ទន្ទឹមនឹងនេះ គុណភាពសេវាកម្ម និងវិជ្ជាជីវៈរបស់អន្តរការីមូលបត្រដែលផ្តល់ដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនិងវិនិយោគិន ត្រូវពង្រឹងបន្ថែម។ លើសពីការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញទន់ ក៏ដូចជាការចែករំលែកអំពីឧត្តមានុវត្តន៍ បុគ្គលិករបស់អន្តរការីមូលបត្រត្រូវទទួលបាននូវមធ្យោបាយនិងបច្ចេកវិទ្យាសមស្រប ដើម្បីអាចកំណត់និងព្យាករណ៍ពីតម្រូវការរបស់អតិថិជនជាមុន និងអាចផ្តល់នូវដំណោះស្រាយដែលផ្តោតលើអត្ថប្រយោជន៍អតិថិជន ជាជាងការប្រើប្រាស់វិធីសាស្ត្រមួយសម្រាប់អនុវត្តគ្រប់ករណី។

### ៣.២.៣.២. វិធានការយុទ្ធសាស្ត្រគ្រប់គ្រងនិងវិភាគទិន្នន័យ

ទិន្នន័យគឺជាធាតុចូលដ៏សំខាន់សម្រាប់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យមូលបត្រ ដូចនេះ **ន.ម.ក.** ត្រូវដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងទិន្នន័យ និងប្រព័ន្ធមូលដ្ឋានទិន្នន័យ ដើម្បីអភិវឌ្ឍជំនាញ និងសមត្ថភាពក្នុងការប្រមូលផ្តុំ វិភាគ គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ ដែលរួមបញ្ចូលទាំងទិន្នន័យដែលបែងចែកតាមភេទ តាមរយៈ៖

- ការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់អាទិភាពប្រភេទទិន្នន័យដែលត្រូវប្រមូលចងក្រង ដោយធ្វើការវាយតម្លៃពីអត្ថប្រយោជន៍ និងបច្ច័យនៃទិន្នន័យ ក៏ដូចជាកម្រិតនៃភាពត្រឹមត្រូវ និងភាពពេញលេញនៃទិន្នន័យ
- បង្កើតវិធីសាស្ត្រក្នុងការប្រមូល ផ្ទុក និងវិភាគទិន្នន័យប្រកបដោយប្រសិទ្ធភាព
- ពិនិត្យឡើងវិញលើយុទ្ធសាស្ត្រនៃការប្រមូលនិងការគ្រប់គ្រងទិន្នន័យជាទៀងទាត់ និងធ្វើបច្ចុប្បន្នកម្មក្នុងករណីចាំបាច់
- ពិនិត្យសមិទ្ធិលទ្ធភាពវាយតម្លៃទិន្នន័យវិស័យមូលបត្រទាំងមូល ដែលបែងចែកតាមភេទ និងកំណត់កាលានុវត្តភាពដើម្បីអនុវត្តឱ្យស្របតាមស្តង់ដាសកល ដូចជាក្រុមហិរញ្ញវត្ថុសហគ្រិនស្ត្រី ដើម្បីធានាថាទិន្នន័យអាចប្រើប្រាស់ដើម្បីកំណត់គោលដៅ និងដាក់ចេញនូវគោលនយោបាយពាក់ព័ន្ធនឹងបរិយាបន្នហិរញ្ញវត្ថុស្ត្រី ប្រកបដោយប្រសិទ្ធភាព។

**ន.ម.ក.** ត្រូវអភិវឌ្ឍវិធីសាស្ត្រ ឬជំនាញដែលពាក់ព័ន្ធនឹងការវិភាគទិន្នន័យ។ ទិន្នផលដែលបានរៀបចំ និងឆ្លងកាត់ការវិភាគ ត្រូវយកទៅប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំជាយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមនានា។

### ៣.២.៣.៣. វិធានការយុទ្ធសាស្ត្រសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងចែករំលែកធនធាន

ការអភិវឌ្ឍវិស័យមូលបត្រទាមទារឱ្យមានការចូលរួម និងការគាំទ្រពីភាគីពាក់ព័ន្ធជាច្រើន ទាំងវិស័យសាធារណៈនិងឯកជន ដូចនេះ កិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធគឺពិតជាមានសារៈសំខាន់។

អភិក្រមនៃកិច្ចសហប្រតិបត្តិការនឹងត្រូវប្រើសម្រាប់ដោះស្រាយបញ្ហាជាក់លាក់ តាមរយៈ៖

- ការកំណត់អត្តសញ្ញាណលើផ្នែកដែលត្រូវសម្របសម្រួល និងភាគីពាក់ព័ន្ធដែលត្រូវចូលរួម
- ការកំណត់លក្ខខណ្ឌដែលផ្តោតសំខាន់លើតួនាទី និងទំនួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនីមួយៗ
- ការរៀបចំ និងការដាក់ចេញនូវយន្តការនៃការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព
- ការបង្កើតភាពជាដៃគូ និងការសហការគ្នារវាងនិយ័តករនិងភាគីពាក់ព័ន្ធក្នុងទីផ្សារ ជាពិសេសក្នុងផ្នែកដែលអាចប្រើប្រាស់ធនធានរបស់ភាគីពាក់ព័ន្ធក្នុងទីផ្សារ
- ការរួមគ្នាបង្កើតគំនិតផ្តួចផ្តើម ដូចជាកម្មវិធីផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹង, វគ្គបណ្តុះបណ្តាល, ការស្រាវជ្រាវនិងកម្មវិធីអភិវឌ្ឍន៍ និងការធ្វើនិយ័តកម្មផ្សេងៗ។

កិច្ចសហការទាំងនេះនឹងអាចដោះស្រាយទាំងតម្រូវការទូទៅ និងជាក់លាក់របស់ភាគីពាក់ព័ន្ធក្នុងទីផ្សារ និងអាចពង្រឹងទំនុកចិត្តទីផ្សារតាមរយៈការរៀបចំកម្មវិធីរួមគ្នាដែលបង្ហាញពីការការពារក្នុងទីផ្សារមូលបត្រ និងការបង្កើតនូវប្រេកទំនាក់ទំនងដែលអាចជួយសម្រួលដល់ការចែករំលែកព័ត៌មានសើបរបស់ទីផ្សារ។

### ៣.២.៣.៤. វិធានការយុទ្ធសាស្ត្រពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ

នៅពេលដែលសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់តែមានលក្ខណៈសកល វិស័យមូលបត្រត្រូវពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយទីផ្សារអន្តរជាតិលើការអភិវឌ្ឍ និងការធ្វើនិយ័តកម្ម។ **ន.ម.ក.** ត្រូវពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធក្នុងយុត្តាធិការផ្សេង ដើម្បីជំរុញការអភិវឌ្ឍផ្នែកថ្មីៗដូចជា ហិរញ្ញវត្ថុចីរភាព និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាដើម ដើម្បីអាចផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹងដោយមានការបង្កើតនូវយន្តការនៃកិច្ចសហប្រតិបត្តិការ សម្រួលដល់កិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្មដូចជាការអនុវត្តច្បាប់ រួមទាំងការអនុវត្តឧត្តមានុវត្តន៍ និងការបន្សីនូវក្របខ័ណ្ឌនៃការធ្វើនិយ័តកម្ម។

កិច្ចសហប្រតិបត្តិការក្នុងតំបន់ត្រូវបន្តពង្រឹងបន្ថែមទៀត ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីសមាជិកភាពអាស៊ាន។ បន្ថែមពីនេះ ក្នុងចំណោមកិច្ចសហប្រតិបត្តិការនានា គំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាពក្នុងតំបន់ នឹងត្រូវស្នើឡើងដោយមានការគាំទ្រដោយភាគីពាក់ព័ន្ធក្នុងតំបន់ ដូចជាកម្មវិធីបណ្តុះបណ្តាលដែលរៀបចំដោយមជ្ឈមណ្ឌល IOSCO អាស៊ីប៉ាស៊ីហ្វិក ជាដើម។

### ៣.២.៣.៥. វិធានការយុទ្ធសាស្ត្រពង្រឹងនិងពង្រីកសមត្ថភាពក្នុងការអនុវត្ត

ការអនុវត្តវិធានការក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ នឹងត្រូវការធនធានយ៉ាងច្រើនដូចនេះ **ន.ម.ក.** ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនលើផ្នែកដូចជា ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ប្រព័ន្ធបច្ចេកវិទ្យា និងផ្នែកជាច្រើនទៀត ពោលគឺត្រូវពង្រឹងនិងពង្រីកបន្ថែមនូវកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី, ចរចាលើការបែងចែកថវិកានិងកំណត់អាទិភាពឱ្យបានត្រឹមត្រូវ, ពង្រឹងបន្ថែមនូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជំនួសប្រតិបត្តិការមួយចំនួន។

## ជំពូកទី៤៖ យន្តការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ

គន្លឹះនៃភាពជោគជ័យនៃផែនការយុទ្ធសាស្ត្រ គឺក្របខ័ណ្ឌនៃការអនុវត្តប្រកបដោយប្រសិទ្ធភាព ដែលរួមបញ្ចូលទាំងការត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាព។

### ៤.១. យន្តការអនុវត្ត

ន.ម.ក. ត្រូវដឹកនាំសម្របសម្រួលការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាឱ្យការអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** នេះទទួលបានជោគជ័យ និងសម្រេចបានសមិទ្ធផលតាមការគ្រោងទុក ដោយមានកិច្ចសហការពីក្រសួង-ស្ថាប័ន និងគ្រប់ភាគីពាក់ព័ន្ធ។ ការងារអាទិភាពកំណត់ក្នុងបរិសិដ្ឋនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ ត្រូវដាក់បញ្ចូលក្នុងក្របខ័ណ្ឌគោល-នយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនានា ដូចជាផែនការអភិវឌ្ឍន៍ស្ថាប័ន និងផែនការសកម្មភាពបីឆ្នាំរំកិលជាដើម។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥ នឹងត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ និងពាក់កណ្ដាលអាណត្តិ តាមរយៈកិច្ចប្រជុំនិងការរៀបចំរបាយការណ៍ ដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តយុទ្ធសាស្ត្រឱ្យឆ្លើយតបនឹងតម្រូវការស្ថានភាព និងនិន្នាការវិវត្តនៃទីផ្សារមូលបត្រកម្ពុជា និងតំបន់។ អគ្គនាយកនៃ **ន.ម.ក.** ជាអ្នកដឹកនាំការងារត្រួតពិនិត្យ និងវាយតម្លៃ និងអាចបង្កើតក្រុមការងារជាមួយស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្តការងារ ដោយមានលេខាធិការដ្ឋានច្បាស់លាស់។

❖ **រយៈពេលនៃការអនុវត្ត**

ក្របខ័ណ្ឌពេលវេលានៃការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវបានបែងចែកជាបី៖

- រយៈពេលខ្លី៖ ពីឆ្នាំ២០២៥ ដល់ ឆ្នាំ២០២៧
- រយៈពេលមធ្យម៖ ពីឆ្នាំ២០២៨ ដល់ ឆ្នាំ២០៣០
- រយៈពេលវែង៖ ពីឆ្នាំ២០៣១ ដល់ ឆ្នាំ២០៣៥

ការបែងចែកក្របខ័ណ្ឌពេលវេលានៃការអនុវត្តនេះ គឺផ្អែកលើភាពសំខាន់ ឬភាពបន្ទាន់នៃវិធានការយុទ្ធសាស្ត្រ ធនធានដែលត្រូវការដើម្បីអនុវត្ត ភាពជាប់ពាក់ព័ន្ធ និងការស្របតាមផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត។ **ន.ម.ក.** អាចផ្លាស់ប្ដូររយៈពេលនៃការអនុវត្តតាមការចាំបាច់។

### ៤.២. យន្តការត្រួតពិនិត្យ និងវាយតម្លៃ

ក្នុងអំឡុងពេលនៃការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃពិតជាមានសារៈសំខាន់ក្នុងការផ្ដល់នូវវឌ្ឍនភាព ភាពទាន់ពេលវេលា និងប្រសិទ្ធភាពនៃការអនុវត្ត។ ក្នុងដំណើរការនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥ **ន.ម.ក.** ប្រើប្រាស់យន្តការត្រួតពិនិត្យ និងវាយតម្លៃ ដូចខាងក្រោម៖

- **របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ៖** ន.ម.ក. នឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

នៅដើមត្រីមាសទី១ ជារៀងរាល់ឆ្នាំ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ នឹងត្រូវធ្វើឡើងតាមរយៈការពិនិត្យ និងវាយតម្លៃតាមរយៈរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនអគ្គនាយកនៃ **ន.ម.ក.** និងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំដែលនឹងត្រូវរៀបចំ និងរាយការណ៍ជូនក្រុមប្រឹក្សា **អ.ស.ហ.**។

- **របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិ៖** ការពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥ ពាក់កណ្តាលអាណត្តិ គឺដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមដែលជួបប្រទះក្នុងអំឡុងពេលអនុវត្ត សំដៅធ្វើបច្ចុប្បន្នកម្មទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០៣១-២០៤០**"។ ន.ម.ក. នឹងរៀបចំរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំទី១ ដល់ឆ្នាំទី៥ ដែលនឹងត្រូវប្រើប្រាស់សម្រាប់សិក្សានិងវិភាគ សំដៅស្វែងរកគន្លឹះជោគជ័យ និងចំណុចខ្វះខាតជាមូលដ្ឋានសម្រាប់កែលម្អ និងជំរុញការអនុវត្តបន្ថែមទៀតនៅពាក់កណ្តាលអាណត្តិឱ្យសម្រេចបានជោគជ័យ និងឆ្លើយតបទៅនឹងចក្ខុវិស័យដែលបានកំណត់។

ដោយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ ជាឯកសាររស់ ដូចនេះ ការអនុវត្តការងារនឹងត្រូវពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាបាននូវភាពពាក់ព័ន្ធ ហើយវិធានការយុទ្ធសាស្ត្រមួយចំនួនអាចនឹងត្រូវកែសម្រួល ឬបន្ថែម ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ឬការវិវត្តថ្មីៗក្នុងទីផ្សារ។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន

**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** ជាឯកសាររស់ដែលត្រូវបានរៀបចំឡើងដោយមានការវិភាគគ្រប់ជ្រុងជ្រោយលើ SWOT និន្នាការវិវត្តន៍នៃវិស័យមូលបត្រ និងសេដ្ឋកិច្ចកម្ពុជា និងនិន្នាការវិវត្តន៍ក្នុងតំបន់និងសកល ព្រមទាំងមានសង្គតិភាពជាមួយយុទ្ធសាស្ត្រ និងគោលនយោបាយជាតិសំខាន់ៗដូចជា យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០, យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ និងក្របខ័ណ្ឌ គ.អ.ច.ក. ឆ្នាំ២០១៦-២០៣០ ព្រមទាំងជាឯកសារយុទ្ធសាស្ត្រដែលនឹងគាំទ្រដល់ការសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងៗទៀត ដូចជា យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹត្យកាបូន ជាដើម។ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥** នេះ ដាក់ចេញនូវចក្ខុវិស័យ គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់ មុតស្រួច និងមានភាពប្រទាក់ក្រឡាគ្នា ដែលអនុវត្តតាមអភិក្រម **"រៀនបណ្តើរ, ធ្វើបណ្តើរ, កែលម្អបណ្តើរ"**, **"ឆ្លងស្ទឹងស្ទាបថ្ម"** និង **"ចាប់យក, បន្សាំ និងធ្វើនវកម្មបន្ថែម"**។ ព្រមជាមួយគ្នានេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ ក៏ដាក់ចេញនូវយន្តការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងការរៀបចំនូវមូលធនមនុស្ស ធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្រាប់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រនេះ ប្រកបដោយភាពជោគជ័យ និងផ្លែផ្កាខ្ពស់។

**បរិសិដ្ឋ៖ ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រ ២០២៥-២០៣៥**

| យុទ្ធសាស្ត្រ | | រយៈពេលខ្លី (ឆ្នាំ២០២៥ - ឆ្នាំ២០២៧) | រយៈពេលមធ្យម (ឆ្នាំ២០២៨ - ឆ្នាំ២០៣០) | រយៈពេលវែង (ឆ្នាំ២០៣១ - ឆ្នាំ២០៣៥) |
|---|---|---|---|---|
| I. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រឹងទីផ្សារមូលបត្រ | | | | |
| ❖ វិធានការយុទ្ធសាស្ត្រជំរុញការបោះផ្សាយលក់មូលបត្រ និងការធ្វើពិពិធកម្មផលិតផល និងសេវា | | | | |
| ១. | **ទាក់ទាញក្រុមហ៊ុនឱ្យបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រ** | • បង្កើតយន្តការសម្របសម្រួលសំដៅលើកកម្ពស់ការចូលរួមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីចុះបញ្ជីលក់មូលបត្រ ដូចជាការចុះ MOU ឬការដាក់ចេញគោលការណ៍ណែនាំរួម | • សហការជាមួយធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញ-វត្ថុ ចុះបញ្ជីនៅ **ផមក** | • បន្តគាំទ្រការចុះបញ្ជីលក់មូលបត្ររបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ |
| | | • បង្កើនចំនួនចុះបញ្ជីលក់មូលបត្ររបស់សហគ្រាសធុនតូច និងមធ្យម ដោយគាំទ្រ និងពង្រីកកម្មវិធីគាំទ្របន្ថែមទៀត ដូចជាកម្មវិធីឧត្តមភាព និងការបង្កើតគ្លីនិកសហគ្រាសធុនតូច និងមធ្យម | • ពិនិត្យ និងកែសម្រួលឡើងវិញនូវកម្មវិធី និងគំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមការចាំបាច់ | • បន្តអនុវត្ត |
| | | • បង្កើតនូវច្រកនៃការទទួលបានហិរញ្ញប្បទាន និងទុនបន្ថែមទៅតាមដំណាក់កាលនៃសហគ្រាសធុនតូច | • ពិនិត្យមើលប្រសិទ្ធភាព នៃបណ្តាញផ្តល់ហិរញ្ញប្បទាន និងទុនបន្ថែម ហើយពង្រឹងការអនុវត្តបន្ថែម | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | និងមធ្យម ដើម្បីឱ្យពួកគេអាចពង្រីកសក្តានុពល ឈានទៅដល់ការចុះបញ្ជី | តាមការចាំបាច់ | |
| | | • ពិចារណាដាក់ឱ្យដំណើរការ ការចុះបញ្ជីលក់មូលបត្រដោយផ្ទាល់ និងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនហូលឌីង | • ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិតាមការចាំបាច់ ដើម្បីសម្រួលដល់ការចុះបញ្ជីលក់មូលបត្រ | • ពិនិត្យមើលប្រសិទ្ធភាពនៃបទប្បញ្ញត្តិ ដើម្បីជំរុញឱ្យមានការចុះបញ្ជីលក់មូលបត្របន្ថែមទៀត |
| | | • ដោះស្រាយបញ្ហាការប្រកួតប្រជែងដោយស្មើភាព (Level of playing field) រវាងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងក្រុមហ៊ុនដែលមិនបានចុះបញ្ជីលក់មូលបត្រ ដោយពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដាក់ចេញនូវវិធានការ ឬយន្តការកាត់បន្ថយគម្លាតនៃការអនុវត្តខុសគ្នា | • ធ្វើការត្រួតពិនិត្យជាប្រចាំដើម្បីកំណត់បញ្ហាជាក់លាក់ណាមួយដែលអាចរារាំងក្រុមហ៊ុនក្នុងការចុះបញ្ជីលក់មូលបត្រ | • បន្តអនុវត្ត |
| | | • ជំរុញឱ្យមានការចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្មឱ្យបានច្រើនដោយ៖<br>➢ បង្កើនកម្មវិធីលើកកម្ពស់ការយល់ដឹងដល់ក្រុមហ៊ុនបោះផ្សាយសក្តានុពល និងវិនិយោគិនស្ថាប័ន | • ពិនិត្យមើលក្របខ័ណ្ឌនៃការចុះបញ្ជីលក់សញ្ញាបណ្ណដើម្បីបង្កើនការចុះបញ្ជី | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ➢ សម្រួលដល់ការបោះផ្សាយសញ្ញា-បណ្ណ Thematic (ឧ.សញ្ញាបណ្ណបៃតង, សញ្ញាបណ្ណសង្គម, សញ្ញាបណ្ណចីរភាព) ដើម្បីទាក់ទាញវិនិយោគិនកាន់តែច្រើន<br>➢ ពិនិត្យលទ្ធភាពផ្តល់ការលើកទឹកចិត្តសមស្រប<br>➢ ពិនិត្យសមិទ្ធិលទ្ធភាពក្នុងការអនុញ្ញាតឱ្យមានការបោះផ្សាយសញ្ញាបណ្ណជាពហុរូបិយប័ណ្ណ<br>➢ អនុម័តសេចក្តីព្រាងប្រកាសស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ | | |
| | | • រៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រសម្រាប់ក្រុមហ៊ុនបោះផ្សាយសក្តានុពល | • បន្តអនុវត្ត | • បន្តអនុវត្ត |
| ២. | **ជំរុញសហគ្រាសសាធា-រណៈឱ្យចុះបញ្ជីលក់មូលបត្រ** | • ជំរុញសហគ្រាសសាធារណៈ (SoEs) ឱ្យចុះបញ្ជីលក់មូលបត្រ ដោយ៖ | • អនុញ្ញាតឱ្យក្រុមការងារចំពោះកិច្ចកែសម្រួលលក្ខខណ្ឌតម្រូវ ក្នុងការ | |

| | | | | |
|---|---|---|---|---|
| | | ➢ បង្កើតក្រុមការងារចំពោះកិច្ចអន្តរភាគី/ស្ថាប័ន ដើម្បីដាក់ចេញក្របខ័ណ្ឌស្តីពី លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីរបស់ SoEs<br>➢ កំណត់ SoEs ដែលអាចវិនិយោគបាន និងអនុវត្តការវាយតម្លៃលើភាពសមស្របរបស់ SoEs ក្នុងការចុះបញ្ជីលក់មូលបត្រ | គាំទ្រ SoEs ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការចុះបញ្ជីលក់មូលបត្រ | |
| ៣. | **អភិវឌ្ឍទីផ្សារបន្ទាប់សម្រាប់មូលបត្ររដ្ឋ** | • ពិនិត្យវាយតម្លៃលើយន្តការជួញដូរ និងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់<br>• រៀបចំកិច្ចពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីទទួលបានធាតុចូលលើការកែលម្អយន្តការ និងហេដ្ឋារចនាសម្ព័ន្ធ | • កែលម្អយន្តការ និងហេដ្ឋារចនា-សម្ព័ន្ធជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ | • ពិនិត្យមើលប្រសិទ្ធភាពនៃយន្តការហេដ្ឋារចនាសម្ព័ន្ធ និងកែសម្រួលឱ្យប្រសើរឡើង តាមការចាំបាច់ |
| ៤. | **អភិវឌ្ឍទីផ្សារខុម៉ូឌីធីអនាគត (commodity future market)** | • បង្កើតយុទ្ធសាស្ត្រសម្រាប់ការបង្កើតទីផ្សារដែលមាននិរន្តរភាពសម្រាប់ការជួញដូរខុម៉ូឌីធីអនាគត | • បង្កើតទីផ្សារខុម៉ូឌីធីអនាគត<br>• រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងដល់វិនិយោគិនអំពីការជួញដូរខុម៉ូឌីធីអនាគត | • លើកទឹកចិត្តឱ្យមានការចូលរួមក្នុងទីផ្សារខុម៉ូឌីធីអនាគតកាន់តែច្រើន |

| | | | | |
|---|---|---|---|---|
| | | • បង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ទីផ្សារខុម៉ូឌីធីអនាគត | | |
| ៥. | **អភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទហិរញ្ញវត្ថុបន្ថែម** | • សិក្សាសមិទ្ធិលទ្ធភាពបង្កើតឧបករណ៍និស្សន្ទជាប្រាក់ដុល្លារអាម៉េរិក/រៀលរួមទាំងការជួញដូរក្នុងទីផ្សារ<br>• វិភាគលើសមិទ្ធិលទ្ធភាពសម្រាប់ការបង្កើតឧបករណ៍និស្សន្ទហិរញ្ញវត្ថុដទៃទៀត<br>• អភិវឌ្ឍឧបករណ៍និស្សន្ទហិរញ្ញវត្ថុបន្ថែម | • រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទហិរញ្ញវត្ថុបន្ថែម ដោយផ្អែកលើលទ្ធផលនៃការវិភាគ | • អនុវត្តសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ |
| ៦. | **អភិវឌ្ឍទីផ្សារឥណទានកាបូន** | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតទីផ្សារឥណទានកាបូន<br>• រៀបចំយុទ្ធសាស្ត្រសម្រាប់បង្កើតទីផ្សារឥណទានកាបូន<br>• បង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ទីផ្សារឥណទានកាបូន | • បង្កើតទីផ្សារឥណទានកាបូន | • ពិនិត្យឡើងវិញលើប្រតិបត្តិការរបស់ទីផ្សារឥណទានកាបូន ដើម្បីកំណត់ផ្នែកដែលត្រូវកែលម្អ |
| ៧. | **ដាក់ចេញបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិ** | • រៀបចំកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងទីផ្សារ អំពីបទប្បញ្ញត្តិពាក់ព័ន្ធគម្រោងវិនិយោគរួម (CIS) | • ពិនិត្យឡើងវិញលើការអភិវឌ្ឍទីផ្សារ CIS និងកែសម្រួលបទប្បញ្ញត្តិ តាមការចាំបាច់ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធ CIS<br>• បញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនឹង CIS ឱ្យបានទូលំទូលាយ | | |
| | | • រៀបចំកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងទីផ្សារអំពីមូលនិធិដែលអាចជួញដូរបាន(ETFs)<br>• រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹង ETFs | • ពិនិត្យឡើងវិញលើការអភិវឌ្ឍទីផ្សារ ETFs និងកែសម្រួលបទប្បញ្ញត្តិ តាមការចាំបាច់ | • បន្តអនុវត្ត |
| | | • រៀបចំកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងទីផ្សារអំពីឌីប៉ូស៊ីតធីរីស៊ីប(DR)<br>• រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹង DR | • ពិនិត្យឡើងវិញលើការអភិវឌ្ឍទីផ្សារ DR និងកែសម្រួលបទប្បញ្ញត្តិតាមការចាំបាច់ | • បន្តអនុវត្ត |
| | | • រៀបចំកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងទីផ្សារអំពីបរធនបាលវិនិយោគអចលនវត្ថុ(REITs)<br>• រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងREITs | • ពិនិត្យឡើងវិញលើការអភិវឌ្ឍទីផ្សារ REIT និងកែសម្រួលបទប្បញ្ញត្តិ តាមការចាំបាច់ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ៨. | ជំរុញឱ្យមានការពង្រីកសេវារបស់ក្រុមហ៊ុនមូលបត្រ | • សិក្សាលទ្ធភាព និងលក្ខខណ្ឌតម្រូវសម្រាប់ក្រុមហ៊ុនមូលបត្រ ដែលផ្តល់សេវាជួញដូរមូលបត្របរទេសដល់អតិថិជនក្នុងស្រុក<br>• រៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនមូលបត្រផ្តល់សេវាជួញដូរមូលបត្របរទេសដល់អតិថិជនក្នុងស្រុក | • ពិនិត្យមើលប្រសិទ្ធភាពនៃលក្ខខណ្ឌតម្រូវ និងធ្វើការកែសម្រួល តាមការចាំបាច់ | • បន្តអនុវត្ត |
| ❖ វិធានការយុទ្ធសាស្ត្រពង្រឹងមូលដ្ឋានវិនិយោគិន និងប្រព័ន្ធអេកូឡូស៊ីនៃការវិនិយោគ | | | | |
| ១. | ការលើកទឹកចិត្តវិនិយោគិនបរទេសឱ្យវិនិយោគក្នុងទីផ្សារមូលបត្រ | • រៀបចំកម្មវិធីរ៉ូដសូនៅមជ្ឈមណ្ឌលហិរញ្ញវត្ថុធំៗ ដើម្បីផ្សព្វផ្សាយពីកាលានុវត្តភាពនៃការវិនិយោគដ៏មានសក្តានុពល ក្នុងវិស័យមូលបត្រនៅកម្ពុជា | | |
| | | • ផ្តួចផ្តើមកិច្ចពិភាក្សាជាមួយអ្នកផ្តល់សន្ទស្សន៍សាកល ដូចជា FTSE ឬ Dow Jones | • វាយតម្លៃកម្រិតបឋម និងរៀបចំខ្លួនដើម្បីបំពេញលក្ខខណ្ឌតម្រូវសម្រាប់ទីផ្សារកំពុងងើបឡើង | • បំពេញលក្ខខណ្ឌតម្រូវនៃទីផ្សារកំពុងងើបឡើង |
| | | • កំណត់ និងភ្ជាប់ទំនាក់ទំនងជាមួយធនាគារបរទេសសក្តានុពលដែលដើរតួនាទីជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុង | • តាមដានវឌ្ឍនភាពនៃការបំពេញតាមលក្ខខណ្ឌតម្រូវរបស់ធនាគារបរទេសដោយភ្នាក់ងាររក្សា | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | វិស័យមូលបត្រ ដោយផ្អែកលើលក្ខខណ្ឌតម្រូវរបស់ធនាគារនោះ | សុវត្ថិភាពក្នុងវិស័យមូលបត្រ និងកែសម្រួល តាមការចាំបាច់<br>• កែសម្រួលបទប្បញ្ញត្តិតាមការចាំបាច់ | |
| ២. | **ជំរុញការវិនិយោគរបស់ស្ថាប័ន សន្សំក្នុងស្រុកក្នុងវិស័យមូលបត្រ** | • ទំនាក់ទំនងជាមួយនិយ័តករជានាវ៉ាប់រងកម្ពុជា និងនិយ័តករសន្តិសុខសង្គម ដើម្បីកែសម្រួលលក្ខខណ្ឌវិនិយោគនៃមូលនិធិសន្សំរយៈពេលវែង និងកំណត់ស្តង់ដាសម្រាប់ការគ្រប់គ្រងបុព្វលាភរបស់ក្រុមហ៊ុនធានារ៉ាប់រង និងការគ្រប់គ្រងមូលនិធិសោធន ដើម្បីអាចវិនិយោគលើទ្រព្យសកម្មដែលមានហានិភ័យនៅក្នុងវិស័យមូលបត្រ | • ពិនិត្យ និងតាមដានការវិនិយោគរបស់ស្ថាប័នសន្សំក្នុងស្រុក | • បន្តអនុវត្ត |
| ៣. | **បង្កើតគំនិតផ្តួចផ្តើមដើម្បីទាក់ទាញវិនិយោ-គិនស្ថាប័នទាំងក្នុងស្រុក និងបរទេស** | • ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មស្តង់ដាដែលបានអនុវត្ត ដើម្បីធានាបាននូវឧត្តមានុវត្តន៍របស់ក្រុមហ៊ុនបោះ-ផ្សាយលក់មូលបត្រ និងបុគ្គលចុះបញ្ជីលក់មូលបត្រ លើផ្នែកៈ<br>○ អភិបាលកិច្ចសាជីវកម្ម<br>○ ស្តង់ដានៃការបង្ហាញព័ត៌មាន | • តាមដានអនុលោមភាពរបស់ក្រុម-ហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលចុះបញ្ជីលក់មូលបត្រ តាមស្តង់ដាដែលបានដាក់ចេញ<br>• បន្តពិនិត្យ និងធ្វើបច្ចុប្បន្នកម្មស្តង់ដា តាមការចាំបាច់ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ○ របាយការណ៍ហិរញ្ញវត្ថុ | | |
| ៤. | **សិក្សាស្រាវជ្រាវលើការដាក់ចេញនូវយន្តការនៃការចូលរួមរបស់មូលនិធិទ្រព្យសម្បត្តិរដ្ឋនៅក្នុងទីផ្សារមូលបត្រ** | • សិក្សាសមិទ្ធិលទ្ធភាពនៃការដាក់ចេញនូវយន្តការនៃការចូលរួមរបស់មូលនិធិទ្រព្យសម្បត្តិរដ្ឋនៅក្នុងទីផ្សារមូលបត្រ<br>• សិក្សាស្រាវជ្រាវក្របខ័ណ្ឌយន្តការនៃការចូលរួម | • ពិនិត្យ និងសម្របសម្រួលជាមួយស្ថាប័នទទួលបន្ទុកលើការគ្រប់គ្រងមូលនិធិទ្រព្យសម្បត្តិរដ្ឋ<br>• រៀបចំសេចក្តីព្រាងក្របខ័ណ្ឌយន្តការនៃការចូលរួម | • អនុម័ត និងដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិ |
| ៥. | **បង្កើតមូលនិធិអភិវឌ្ឍន៍ទីផ្សារមូលបត្រ** | • សិក្សាសមិទ្ធិលទ្ធភាពនៃការបង្កើតមូលនិធិអភិវឌ្ឍន៍ទីផ្សារមូលបត្រដើម្បីគាំទ្រដល់សកម្មភាពជួញដូរក្នុងទីផ្សារមូលបត្រ ដោយប្រតិបត្តិករ និងភាគីពាក់ព័ន្ធនៅក្នុងទីផ្សារមូលបត្រ<br>• បង្កើត និងដំណើរការមូលនិធិអភិវឌ្ឍន៍ទីផ្សារមូលបត្រ | • គ្រប់គ្រង និងតាមដានប្រតិបត្តិការរបស់មូលនិធិអភិវឌ្ឍន៍ទីផ្សារមូលបត្រ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ៦. | **អនុវត្តគំនិតផ្តួចផ្តើមដើម្បីផ្តល់ភាពងាយស្រួលវិនិយោគ និងជួយសម្រួលដល់ដំណើរការជួញដូរ** | • កំណត់ផ្នែកនានានៃដំណើរការនៃការវិនិយោគដែលត្រូវកែសម្រួល ដើម្បីបង្កើនភាពងាយស្រួលក្នុងការវិនិយោគ<br>• ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឱ្យកាន់តែទូលំទូលាយដើម្បីបង្កើនប្រសិទ្ធភាព និងបទពិសោធន៍របស់វិនិយោគិនសម្រាប់ការជួញដូរមូលបត្រ (ការបើកគណនីជួញដូរ និងលេខអត្តសញ្ញាណវិនិយោគិន, ការជួញដូរ, ការផាត់ទាត់, ការទូទាត់)<br>• ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធជួញដូរចល័តជាប្រចាំ | • បន្តកែលម្អផ្នែកនីមួយៗនៃដំណើរការនៃការវិនិយោគ<br>• ពង្រីកការប្រើប្រាស់បច្ចេកវិទ្យារួមទាំងថ្នាលជួញដូរសាកល្បង ដើម្បីលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្ត ឱ្យមានបន្តអនុវត្តការចូលរួមកាន់តែច្រើន | • បន្តអនុវត្ត |
| ៧. | **ពង្រឹងប្រសិទ្ធភាពនៃការបង្ហាញព័ត៌មាន និងផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់វិនិ-យោគិនក្នុងការទទួលបានព័ត៌មាន** | • បង្កើនការយល់ដឹងដល់សាធារណ-ជនអំពីប្រភពព័ត៌មានដែលពាក់ព័ន្ធនឹងការវិនិយោគ<br>• ផ្សព្វផ្សាយព័ត៌មាន ឬការវិវត្តថ្មីៗសំខាន់ៗ (ឧទាហរណ៍ IPOs) តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា<br>• បង្កើតផតថលព័ត៌មានដើម្បីផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យ | • បន្តលើកកម្ពស់ការយល់ដឹង<br>• បន្តប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនានា<br>• តាមដានប្រសិទ្ធភាពនៃផតថលព័ត៌មាន និងប្រព័ន្ធបង្ហាញព័ត៌មាន | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ដែលពាក់ព័ន្ធនឹងការវិនិយោគក្នុងវិស័យមូលបត្រ<br>• ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបង្ហាញព័ត៌មានឌីជីថល សម្រាប់គោលបំណងត្រួតពិនិត្យ | | |
| ❖ **វិធានការយុទ្ធសាស្ត្រពង្រឹងសណ្តាប់ធ្នាប់ទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ** | | | | |
| ១. | **ពង្រឹងយន្តការការពារវិនិយោគិនក្នុងវិស័យមូលបត្រ** | • ពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃយន្តការនៃការដាក់ទណ្ឌកម្មក្នុងវិស័យមូលបត្រនាពេលបច្ចុប្បន្ន និងកែសម្រួលឡើងវិញ តាមការចាំបាច់<br>• លើកកម្ពស់ការយល់ដឹងដល់សាធារណជន អំពីច្បាប់ និងបទប្បញ្ញត្តិនៃការការពារវិនិយោគិនក្នុងវិស័យមូលបត្រ<br>• បង្កើតប្រព័ន្ធឃ្លាំមើលការជួញដូរមូលបត្រនៅ **ផមក**<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតមូលនិធិការពារវិនិយោគិន | • ពង្រឹងតួនាទីរបស់ការិយាល័យដោះស្រាយវិវាទ និងទទួលពាក្យបណ្តឹង តាមរយៈ៖<br>➢ ការដាក់ចេញនូវមធ្យោបាយឌីជីថលក្នុងការទទួល និងដោះស្រាយពាក្យបណ្តឹង<br>➢ ការកំណត់ពេលវេលា(turn-around-time) សម្រាប់ដោះស្រាយបណ្តឹង<br>• បង្កើត និងដាក់ឱ្យដំណើរការមូលនិធិការពារវិនិយោគិនរួមជាមួយនឹងការរៀបចំបទប្បញ្ញត្តិនិងគោលការណ៍ណែនាំចាំបាច់ | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលដោះស្រាយវិវាទឯករាជ្យ<br>• វាយតម្លៃពីប្រសិទ្ធភាពនៃដំណើរការមូលនិធិការពារវិនិយោគិន |

| | | | | |
|---|---|---|---|---|
| ២. | **ពង្រឹងការធ្វើនិយ័តកម្ម និងសមត្ថភាពនៃការអនុវត្តច្បាប់និងការសម្របសម្រួលអន្តរស្ថាប័ន** | • ផ្តល់ការបណ្តុះបណ្តាល និងឧបករណ៍គ្រប់គ្រាន់ដល់ក្រុមត្រួតពិនិត្យ និងក្រុមពង្រឹងការអនុវត្តច្បាប់<br>• ពិនិត្យឡើងវិញលើយន្តការនៃការសម្របសម្រួលជាមួយស្ថាប័នពង្រឹងការអនុវត្តច្បាប់ដទៃទៀត<br>• ចាត់វិធានការចំពោះការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ ទាន់ពេលវេលា និងមានប្រសិទ្ធភាពស្របតាមច្បាប់ដែលមានជាធរមាន | • បន្តអនុវត្ត | • បន្តអនុវត្ត |
| ៣. | **ពង្រឹងអាជីវកម្មរបស់អន្តរការីមូលបត្រដែលទទួលបានអាជ្ញាបណ្ណ** | • រៀបចំ និងអនុម័តក្របខ័ណ្ឌបទប្បញ្ញត្តិផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងគ្រប់គ្រងភ្នាក់ងារណែនាំក្នុងវិស័យមូលបត្រ ដើម្បីឱ្យអន្តរការីមូលបត្រអាចផ្តល់សេវាកាន់តែទូលំទូលាយ<br>• ផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងគ្រប់គ្រងភ្នាក់ងារណែនាំក្នុងវិស័យមូលបត្រ | • បន្តផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងគ្រប់គ្រងភ្នាក់ងារណែនាំក្នុងវិស័យមូលបត្រ<br>• រៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិបន្ថែមសម្រាប់គ្រប់គ្រងក្រមសីលធម៌វិជ្ជាជីវៈ និងការវាយការណ៍របស់ភ្នាក់ងារណែនាំក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត<br>• ពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិទាំងនេះ |

| | | | | |
|---|---|---|---|---|
| ៤. | **វិភាគស៊ីជម្រៅលើខ្សែ-ច្រវាក់តម្លៃប្រតិបត្តិករទីផ្សារ ប្រតិបត្តិប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ** | | • ពិនិត្យសមិទ្ធិលទ្ធភាពក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារឡើងវិញ<br>• វាយតម្លៃអំពីតម្រូវការនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារឡើងវិញរបស់ប្រតិបត្តិករទីផ្សារមូលបត្រ, ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ | • បង្កើត និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីផ្សារឡើងវិញ |
| ៥. | **បង្កើនប្រសិទ្ធភាព និងនិរន្តរភាពនៃហេដ្ឋារចនាសម្ព័ន្ធទីផ្សារ** | • សិក្សាសមិទ្ធិលទ្ធភាពលើការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធជួញដូរ និងទូទាត់ដើម្បីអាចទ្រទ្រង់ការដាក់ឱ្យដំណើរការនូវផលិតផលថ្មីៗ និងកាត់បន្ថយហានិភ័យ<br>• ពិនិត្យសមត្ថភាពនៃប្រព័ន្ធជួញដូរ និងទូទាត់នៅក្នុងការដាក់ឱ្យដំណើរការផលិតផលថ្មី | • ធ្វើផែនការលើកកម្ពស់ហេដ្ឋារចនា-សម្ព័ន្ធនៃប្រព័ន្ធជួញដូរ និងទូទាត់ និងអនុវត្តផែនការ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • ពិនិត្យហានិភ័យនៃការជួញដូរមុនការទូទាត់ និងកំណត់ផ្នែកដែលត្រូវកែលម្អ ឬបទប្បញ្ញត្តិដែលត្រូវកែសម្រួល | | |
| | | • រៀបចំផែនការបម្រុងគ្រប់គ្រាន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ដើម្បីជៀសវាង និងកាត់បន្ថយការរំខាន តាមរយៈ៖<br>➢ ការវាយតម្លៃផលប៉ះពាល់ពីស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធទីផ្សារនីមួយៗ<br>➢ ការបង្កើតប្រព័ន្ធបម្រុងសមស្រប | • វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ស្របតាមការវិវត្តនៃទីផ្សារ ដោយត្រូវ ៖<br>➢ ព្យាករណ៍តម្រូវការថវិកាសម្រាប់រយៈពេល ១០ ឆ្នាំ<br>➢ បែងចែកថវិកាតាមដំណាក់កាល | |
| ៦ | **តភ្ជាប់ការទូទាត់ឆ្លងដែន ក្នុងវិស័យមូលបត្រ** | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការតភ្ជាប់ការទូទាត់ឆ្លងដែនក្នុងតំបន់អាស៊ាន និងតំបន់អាស៊ានបូក៣ | • តភ្ជាប់ការទូទាត់ឆ្លងដែននៅក្នុងតំបន់អាស៊ាន និងតំបន់អាស៊ានបូក៣ | • បន្តអនុវត្ត |

| ❖ វិធានការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពទីផ្សារ | | | | |
|---|---|---|---|---|
| ១. | **ពិនិត្យឡើងវិញនូវថ្លៃចំណាយ សម្រាប់អ្នកចូលរួមក្នុងវិស័យ** | • ប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងការចំណាយថ្លៃដើម, កម្រៃសេវា និងការចំណាយផ្សេងៗដើម្បីចូលរួមក្នុង | • ពិនិត្យឡើងវិញនូវប្រសិទ្ធភាពរចនាសម្ព័ន្ធនៃកម្រៃសេវា | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | **មូលបត្រ** | វិស័យមូលបត្រ សម្រាប់វាយតម្លៃ និងសម្រេចចិត្ត<br>• រៀបចំវេទិកាពិភាក្សាជាមួយអ្នកចូលរួមក្នុងទីផ្សារពាក់ព័ន្ធនឹងកម្រៃសេវានៃការចូលរួមក្នុងទីផ្សារដើម្បីពិនិត្យលទ្ធភាពដាក់ចេញនូវរចនា-សម្ព័ន្ធកម្រៃសេវាដែលមានការប្រកួតប្រជែង<br>• ជំរុញឱ្យមាននវានុវត្តន៍ និងការប្រើ-ប្រាស់បច្ចេកវិទ្យា ដើម្បីកាត់បន្ថយការចំណាយចំពោះការចូលរួមក្នុងទីផ្សារ | • បន្តលើកទឹកចិត្តឱ្យមាននវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីកាត់បន្ថយការចំណាយចំពោះការចូលរួមក្នុងទីផ្សារ | |
| ២. | **ផ្តល់ការលើកទឹកចិត្តជាទម្រង់ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ** | • សិក្សាសមិទ្ធលទ្ធភាព និងរៀបចំក្របខ័ណ្ឌនៃការផ្តល់ការលើកទឹក-ចិត្តផ្នែកពន្ធដាររយៈពេលវែងដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ វិនិយោគិន អន្តរការីមូលបត្រ និងអ្នកចូលរួមផ្សេងទៀត ក្នុងវិស័យមូលបត្រ<br>• ផ្តល់ការលើកទឹកចិត្តពិសេស៖ | • បន្តអនុវត្ត | • វាយតម្លៃពីឥទ្ធិពលនៃការលើកទឹកចិត្តនីមួយៗ និងការសម្រេច-បាននូវលទ្ធផលដែលចង់បាន<br>• ពិនិត្យជាមួយអ្នកចូលរួមទីផ្សារ និងអ្នកពាក់ព័ន្ធផ្សេងទៀតពីលទ្ធផលនៃវិធានការដែលបានដាក់ចេញ និងកែសម្រួលតាមការចាំបាច់ |

| | | | | |
|---|---|---|---|---|
| | | ➢ កំណត់ផ្នែកគោលដៅដែលត្រូវលើកទឹកចិត្ត<br>➢ ផ្ដល់អាទិភាពដល់ផ្នែកដែលមានសក្ដានុពលកំណើនខ្លាំងបំផុត និង/ឬមានឥទ្ធិពលជាវិជ្ជមានខ្ពស់បំផុតលើការអភិវឌ្ឍវិស័យមូលបត្រ និងរបៀបវារៈជាតិក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុចីរភាព<br>➢ កំណត់ភាគីពាក់ព័ន្ធដែលត្រូវទទួលបានការលើកទឹកចិត្ត ដូចជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អន្តរការីមូលបត្រ និងវិនិយោគិន | | |
| ៣. | **បន្ថយឧបសគ្គចំពោះការអភិវឌ្ឍទីផ្សារមូលបត្រដែលបង្កឡើងដោយការបោះផ្សាយលក់មូលបត្រជាប្រាក់រៀល** | • បង្កើតក្រុមការងារអន្តរស្ថាប័នរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ន.ម.ក.** និងធនាគារជាតិនៃកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នដឹកនាំដើម្បីអង្កេតពីផលប៉ះពាល់ដល់វិស័យមូលបត្រ ដែលបង្កឡើងដោយការបោះផ្សាយលក់មូលបត្រជាប្រាក់រៀល និងដាក់ចេញ | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | សកម្មភាពដើម្បីដោះស្រាយបញ្ហាទាំងនោះ<br>• សហការជាមួយតួអង្គនៅក្នុងទីផ្សារ ដើម្បីវាយតម្លៃផលប៉ះពាល់នានា ចំពោះវិស័យមូលបត្រ<br>• បង្កើតនូវក្របខ័ណ្ឌសម្រាប់ការបោះ-ផ្សាយលក់មូលបត្រជារូបិយប័ណ្ណបរទេស | | |
| ៤. | **ជំរុញប្រសិទ្ធភាពដំណើរការ និងសុចរិត-ភាពក្នុងទីផ្សារ** | • ពិនិត្យ និងកែសម្រួលឡើងវិញទៅលើដំណើរការនៃការផ្ដល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់, ការបោះផ្សាយលក់មូលបត្រ , ការចុះបញ្ជីលក់មូលបត្រ និងការវិនិយោគ ជាដើមតាមការចាំបាច់<br>• ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធី និងយន្តការនៃការជួញដូរ, ការទូទាត់ និងប្រតិបត្តិការដទៃទៀតស្របតាមឧត្តមានុវត្តន៍ | • បន្តអនុវត្ត | • បន្តអនុវត្ត |

| II. ក្របខ័ណ្ឌយុទ្ធសាស្ត្រពង្រីកទីផ្សារមូលបត្រ | | | | |
|---|---|---|---|---|
| ❖ វិធានការយុទ្ធសាស្ត្រអភិវឌ្ឍហិរញ្ញវត្ថុចីរភាព | | | | |
| ១. | **ជំរុញការបោះផ្សាយលក់មូលបត្រចីរភាព** | • ពង្រីកកម្មវិធីជំរុញការបោះផ្សាយលក់សញ្ញាបណ្ណចីរភាពនៅកម្ពុជា<br>• ផ្តល់ជំនួយបច្ចេកទេស និងកិច្ចគាំទ្រសម្រាប់ការបោះផ្សាយលក់សញ្ញា-បណ្ណចីរភាព | • បន្តអនុវត្ត | • បន្តអនុវត្ត |
| | | • រៀបចំ និងដាក់ឱ្យប្រើប្រាស់គោល-ការណ៍ណែនាំសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណផ្សារភ្ជាប់នឹងចីរភាពដែលស្របតាមស្តង់ដាសញ្ញាបណ្ណផ្សារភ្ជាប់នឹងចីរភាពអាស៊ាន<br>• រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុអន្តរកាលដោយផ្អែកលើគោលការណ៍ណែនាំហិរញ្ញវត្ថុអន្តរកាលអាស៊ាន | • រៀបចំ និងដាក់ឱ្យប្រើប្រាស់គោល-ការណ៍ណែនាំសម្រាប់ការបោះផ្សាយលក់មូលនិធិចីរភាព ស្របតាមស្តង់ដាមូលនិធិចីរភាព និងទំនួលខុសត្រូវអាស៊ាន<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការអភិវឌ្ឍ៖<br>➢ ហិរញ្ញវត្ថុផ្អែកលើធម្មជាតិ (Nature-based Finance)<br>➢ ហិរញ្ញវត្ថុរួមរវាងឯកជន និងសាធារណៈ សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | • ពិនិត្យឡើងវិញនូវគោលការណ៍ណែនាំ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ |

| | | | | |
|---|---|---|---|---|
| ២. | **ចូលរួមបង្កើតមូលដ្ឋានទិន្នន័យ (Database) នៃគម្រោងចីរភាព និងការបំភាយឧស្ម័នកាបូន** | • ចូលរួមប្រមូលផ្តុំគម្រោងចីរភាពនៅកម្ពុជា<br>• ចូលរួមស្វែងរកលទ្ធភាពនៃការទទួលបានទិន្នន័យសម្រាប់ការបំភាយឧស្ម័នកាបូន<br>• ចូលរួមអំពាវនាវឱ្យមានក្រុមការងារថ្នាក់ជាតិ ឬគំនិតផ្តួចផ្តើមលើការប្រមូលទិន្នន័យ, វិធីសាស្ត្រ និងការចេញផ្សាយ ដែលស្របនឹងកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ | • ចូលរួមបង្កើតមូលដ្ឋានទិន្នន័យនៃគម្រោងចីរភាពនៅកម្ពុជា<br>• ចូលរួមបង្កើតមជ្ឈមណ្ឌលទិន្នន័យស្តីពីការបំភាយឧស្ម័នកាបូនសម្រាប់ការលើកកម្ពស់ការបង្ហាញព័ត៌មានចីរភាព | • បន្តអនុវត្ត |
| ៣. | **លើកកម្ពស់ស្តង់ដាបង្ហាញព័ត៌មានចីរភាព** | • លើកកម្ពស់ការអនុវត្តការបង្ហាញព័ត៌មានចីរភាព | • បង្កើតក្របខ័ណ្ឌជាតិ ឬគោលការណ៍ណែនាំសម្រាប់ការបង្ហាញព័ត៌មានចីរភាព<br>• អនុវត្តវិធីសាស្ត្រជាដំណាក់កាល និងតាមសមាមាត្រ សម្រាប់ការបង្ហាញព័ត៌មានហានិភ័យអាកាសធាតុ<br>• វាយតម្លៃពីតម្រូវការថ្នាលទិន្នន័យ ដើម្បីគាំទ្រការរាយការណ៍ និងការបង្ហាញព័ត៌មានចីរភាព | • ពិនិត្យប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំនៃការបង្ហាញព័ត៌មានចីរភាព និងធ្វើការកែសម្រួលតាមការចាំបាច់<br>• រៀបចំក្របខ័ណ្ឌសម្រាប់ការបង្ហាញព័ត៌មានដោយផ្អែកលើធម្មជាតិ (Nature-based disclosure) |

| | | | | |
|---|---|---|---|---|
| ៤. | **កសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងហិរញ្ញវត្ថុចីរភាព** | • រៀបចំសិក្ខាសាលាសម្រាប់និយ័តករ និងភាគីពាក់ព័ន្ធដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍<br>• វាយតម្លៃការរៀបចំកម្មវិធីជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការរៀបចំសិក្ខាសាលា | • បន្តអនុវត្ត | • បន្តអនុវត្ត |
| | | • រៀបចំសិក្ខាសាលាបច្ចេកទេសសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អន្តរការីមូលបត្រ និងវិនិយោគិនសក្តានុពល | • បន្តអនុវត្ត | • បន្តអនុវត្ត |
| | | • រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងដល់ភាគីពាក់ព័ន្ធ និងសាធារណជន | • បង្កើតកម្មវិធីផ្សព្វផ្សាយហិរញ្ញវត្ថុចីរភាព និងគំនិតផ្តួចផ្តើមអប់រំជាសាធារណៈ<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំកិច្ចប្រជុំកំពូលហិរញ្ញវត្ថុចីរភាពនៅកម្ពុជា | • បន្តអនុវត្ត |
| ៥. | **សម្របសម្រួលការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាព** | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលចំណេះដឹងស្តីពីហិរញ្ញវត្ថុចីរភាពជាមួយភាគីពាក់ព័ន្ធ | • បង្កើតមជ្ឈមណ្ឌលចំណេះដឹងរួមស្តីពីហិរញ្ញវត្ថុចីរភាពនៅកម្ពុជា<br>• ពង្រឹង និងពង្រីកកិច្ចសហការទ្វេភាគី ឬពហុភាគីជាមួយស្ថាប័ន- | • រៀបចំសិក្ខាសាលា និងសន្និសីទកម្រិតអាស៊ាន |

| | | | | |
|---|---|---|---|---|
| | | • បង្កើតកិច្ចសហការទ្វេភាគី ឬពហុភាគីជាមួយស្ថាប័ន-សមាគមក្នុងវិស័យមូលបត្រ នៃយុត្តាធិការពាក់ព័ន្ធ<br>• សហការជាមួយធនាគារអភិវឌ្ឍន៍ពហុភាគី (MDBs) និងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODAs) លើកម្មវិធីកសាងសមត្ថភាព | សមាគមក្នុងវិស័យមូលបត្រនៃយុត្តាធិការពាក់ព័ន្ធ | |
| ៦. | **បោះផ្សាយលក់មូលបត្ររដ្ឋបែតង** | • សិក្សាបទពិសោធន៍អាស៊ានក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋបែតង | • បោះផ្សាយលក់មូលបត្ររដ្ឋបែតងតាមលទ្ធភាព | • វាយតម្លៃលើចំណាប់អារម្មណ៍របស់វិនិយោគិន និងសាធារណជនចំពោះមូលបត្ររដ្ឋបែតង |
| **❖ វិធានការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបច្ចេកវិទ្យាឌីជីថល** | | | | |
| ១. | **បង្កើតផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍបច្ចេក-វិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យមូលបត្រ** | • រៀបចំ និងដាក់ឱ្យប្រើប្រាស់ផែនទីបង្ហាញផ្លូវ | • អនុវត្តអនុសាសន៍ក្នុងផែនទីបង្ហាញផ្លូវ<br>• តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត និងលើកជាការស្នើសុំកែលម្អ តាមការចាំបាច់ | • បន្តអនុវត្ត |
| ២. | **ពង្រឹងការកសាងសមត្ថភាព និងការយល់ដឹងជាសាធារណៈអំពីបច្ចេកវិទ្យាហិរញ្ញ-** | • ចូលរួមព្រឹត្តិការណ៍សាធារណៈដើម្បីផ្សព្វផ្សាយបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ | • បន្តពង្រឹងការកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | **វត្ថុក្នុងវិស័យមូលបត្រ** | • ផ្សព្វផ្សាយខ្លឹមសារអប់រំ អំពីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ<br>• បង្កើត ឬចាប់ដៃគូជាមួយស្ថាប័នរដ្ឋ និងស្ថាប័នឯកជនដែលពាក់ព័ន្ធ ដើម្បីដាក់ចេញគំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់ការយល់ដឹង<br>• បង្កើតកិច្ចសហប្រតិបត្តិការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំ និងដាក់ចេញកម្មវិធីស្តីពី អក្ខរកម្មឌីជីថល | • បង្កើតសកម្មភាពគាំទ្រភាពជាសហគ្រិនបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>• សហការជាមួយនិយ័តករ និងអ្នកជំនាញផ្សេងទៀត ដើម្បីចែករំលែកការយល់ដឹង និងបទពិសោធន៍<br>• ចាប់ដៃគូជាមួយស្ថាប័នអប់រំឬស្ថាប័នដែលមានបទពិសោធន៍ ដើម្បីកសាងសមត្ថភាពមន្ត្រី អំពីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងវិស័យមូលបត្រ | |
| ៣. | **បង្កើតបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ** | • ពិនិត្យលើពាក្យស្នើសុំចូលរួមបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ | • បន្តពិនិត្យពាក្យស្នើសុំ និងធ្វើនិយ័តកម្មក្រុមហ៊ុនចូលរួមបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត |
| ៤. | **បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ** | • រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ និងគោលនយោបាយពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញវត្ថុវិមជ្ឈការ (DeFi) ក្នុងវិស័យមូលបត្រ | • សិក្សាពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងករណីប្រើប្រាស់ហិរញ្ញវត្ថុវិមជ្ឈការ (DeFi) ក្នុងវិស័យមូលបត្រ<br>• អនុវត្តអនុលោមតាមគោលនយោបាយ និងបទប្បញ្ញត្តិដែលបានដាក់ចេញ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ៥. | **ជំរុញការអភិវឌ្ឍ និងនវានុវត្តន៍នៃសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ** | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតក្រុមអ្នកជំនាញពហុភាគីបច្ចេកវិទ្យាហិរញ្ញវត្ថុ (Multi-FinTech Think-Tank) ដែលមានការចូលរួមពីភាគីពាក់ព័ន្ធដើម្បីជំរុញសកម្មភាពនវានុត្តន៍ នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>• សិក្សាស្រាវជ្រាវពីការវិវត្តសកលនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងករណីប្រើប្រាស់សំខាន់ៗ សំដៅជំរុញនវានុវត្តន៍ក្នុងវិស័យមូលបត្រ<br>• គ្រប់គ្រង និងគាំទ្រនវានុវត្តន៍ក្នុងសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ | • បន្តអនុវត្ត | • បន្តអនុវត្ត |
| ៦. | **គាំទ្រការអនុវត្តវិធាន-ការក្រោមគោល-នយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨** | • ចូលរួមអនុវត្តការងារក្នុងក្រុមការងារពាក់ព័ន្ធ និង/ឬគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល<br>• កំណត់ក្របខ័ណ្ឌពេលវេលាសមស្របសម្រាប់អនុវត្តវិធានការដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងវិស័យមូលបត្រ | • បន្តអនុវត្តវិធានការពាក់ព័ន្ធ<br>• វាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តវិធានការពាក់ព័ន្ធក្រោម **គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨** ព្រមទាំងកំណត់ផ្នែកសម្រាប់បន្តតាមដាន និងបន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ៧. | **ប្រើប្រាស់បច្ចេកវិទ្យាជាឃ្នាស់ក្នុងវិស័យមូលបត្រ** | • វាយតម្លៃលម្អិតដើម្បីកំណត់ផ្នែកដែលគួរផ្តល់អាទិភាពសម្រាប់ធ្វើស្វ័យប្រវត្តិកម្ម<br>• ផ្ទៀងផ្ទាត់លទ្ធផលវាយតម្លៃធៀបនឹងការត្រៀមខ្លួនរួចរាល់របស់ទីផ្សារក្នុងការចាប់យកបច្ចេកវិទ្យាដែលពាក់ព័ន្ធ<br>• បង្កើត និងអនុវត្តគំនិតផ្តួចផ្តើមស្វ័យប្រវត្តិកម្ម ដោយផ្អែកលើបញ្ជីអាទិភាព<br>• ផ្តល់ការលើកទឹកចិត្ត និងការគាំទ្រសមស្រប និងអាចអនុវត្តបាន ដើម្បីសម្រួលដល់ការអនុវត្ត<br>• តម្រូវឱ្យអន្តរការីមូលបត្របង្កើតគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យាឱ្យបានសមស្រប | • តាមដាន និងវាយតម្លៃវឌ្ឍនភាព និងឥទ្ធិពលនៃគំនិតផ្តួចផ្តើមស្វ័យប្រវត្តិកម្មនិងកែសម្រួលតាមការចាំបាច់<br>• បែងចែកថវិកាឱ្យបានគ្រប់គ្រាន់ក្នុងរយៈពេលមធ្យមទៅរយៈពេលវែងសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល<br>• បង្កើតក្របខ័ណ្ឌសម្រាប់ RegTech និង SupTech | • បន្តអនុវត្ត |
| ៨. | **បង្កើតក្របខ័ណ្ឌគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យា និងសន្តិសុខសាយប័រក្នុង** | • ប្រមូលធាតុចូល និងរៀបចំសេចក្តីព្រាងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យា និងសន្តិសុខសាយប័រ ក្នុងវិស័យមូលបត្រ | • រៀបចំសិក្ខាសាលាកសាងសមត្ថភាព និងចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងហានិភ័យសន្តិសុខសាយប័រ,កម្មវិធីសាកល្បងជាដើម | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | **វិស័យមូលបត្រ** | • ដាក់ចេញក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសន្តិសុខសាយប័រក្នុងវិស័យមូលបត្រ<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការរួម-បញ្ចូលការការពារទិន្នន័យ និងក្របខ័ណ្ឌចែករំលែកទិន្នន័យ<br>• បង្កើតក្រុមការងារជំនាញនៃ ន.ម.ក. ក្នុងការគ្រប់គ្រងហានិភ័យ<br>• សម្របសម្រួលជាមួយនិយ័តករទូរគមនាគន៍ និងស្ថាប័នពាក់ព័ន្ធ ដែលមានជំនាញក្នុងវិស័យបច្ចេកវិទ្យា ដើម្បីទទួលបានចំណេះដឹង និងធាតុចូលបន្ថែមសម្រាប់អភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យា និងសន្តិសុខសាយប័រក្នុងវិស័យមូលបត្រ | • តាមដានការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសន្តិសុខសាយប័រក្នុងវិស័យមូលបត្រ | |
| ៩. | **បង្កើតនាយកដ្ឋានបច្ចេកវិទ្យាហិរញ្ញវត្ថុ ឬឌីជីថល នៅក្នុង ន.ម.ក.** | • បង្កើតនាយកដ្ឋានជាក់លាក់ដែលទទួលខុសត្រូវលើឌីជីថលូបនីយកម្មសម្រាប់វិស័យមូលបត្រ | • ពិនិត្យមើលភាពសមស្រប និងភាពគ្រប់គ្រាន់របស់នាយកដ្ឋាន ធៀបនឹងការអភិវឌ្ឍ និងតម្រូវការទីផ្សារ និង | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • រៀបចំរចនាសម្ព័ន្ធនាយកដ្ឋាន និងមន្ត្រីស្របតាមនិន្នាការសកល តម្រូវការ និងការចង្អុលបង្ហាញពីគោល-នយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល | គោលនយោបាយរបស់រាជរដ្ឋា-ភិបាល<br>• បង្កើតបណ្តាញចែករំលែកបទពិ-សោធន៍ជាមួយនិយ័តករផ្សេងទៀត | |
| ១០. | **គាំទ្រការអនុវត្តយុទ្ធ-សាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨** | • ចូលរួមអនុវត្តការងារក្នុងក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច<br>• កំណត់ក្របខ័ណ្ឌពេលវេលាសមស្របសម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាព និងវិធានការគន្លឹះដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ | • បន្តអនុវត្តយុទ្ធសាស្ត្រអាទិភាព និងវិធានការគន្លឹះដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត |
| ❖ **វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ** | | | | |
| ១. | **បង្កើត និងពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិករទីផ្សារ និងសមាជិក** | • រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការដាក់បញ្ចាំមូលបត្រ និងការធានាបំណុលដោយមូលបត្រ (Securities Pledge and mortgage)<br>• សិក្សាសមិទ្ធិលទ្ធភាពក្នុងការវាយ-តម្លៃពីអត្ថប្រយោជន៍សក្តានុពល, | • ផ្តល់ការទទួលស្គាល់ភ្នាក់ងារផ្តល់សេវាពាក់ព័ន្ធនឹងការបញ្ចាំមូលបត្រ និងការធានាបំណុលដោយមូលបត្រ<br>• ពិនិត្យបទប្បញ្ញត្តិដែលមានស្រាប់ដើម្បីធ្វើវិសិដ្ឋកម្មប្រតិបត្តិកររក្សាទុកមូលបត្រ ជាមជ្ឈមណ្ឌលរក្សាទុកមូលបត្រកណ្តាល | • ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការដាក់បញ្ចាំមូលបត្រ និងការធានាបំណុលដោយមូលបត្រ<br>• បន្តអនុវត្ត និងត្រួតពិនិត្យក្របខ័ណ្ឌបទប្បញ្ញត្តិ |

| | | | | |
|---|---|---|---|---|
| | | ការចំណាយ និងបញ្ហាប្រឈមនៃមជ្ឈការមុខងារប្រព័ន្ធទីផ្សារ (centralizing the securities function) | | |
| ២. | **រៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងហិរញ្ញប្ប-ទានមូលបត្រ និងការជួញដូរមូលបត្រតាមម៉ាជីន** | • រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មហិរញ្ញប្បទានមូលបត្រ<br>• រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់ការអនុញ្ញាត និងការគ្រប់គ្រងការជួញដូរមូលបត្រតាមម៉ាជីន<br>• ផ្តល់ការអនុញ្ញាតឱ្យមានការជួញដូរមូលបត្រតាមម៉ាជីន<br>• រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងសំណងមូលនិធិរួម និងវិធានប្រតិបត្តិការស្តីពីការជួញដូរមូលបត្រតាមម៉ាជីនរបស់ប្រតិបត្តិករទីផ្សារមូលបត្រ | • ផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដើម្បីធ្វើអាជីវកម្មហិរញ្ញប្បទានមូលបត្រ<br>• តាមដានអនុលោមភាពរបស់បុគ្គលក្រោមនិយ័តកម្ម | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ៣. | **ដាក់ឱ្យប្រើប្រាស់ និងលើកកម្ពស់ក្រមអភិបាលកិច្ចសាជីវកម្ម** | • រៀបចំ និងដាក់ឱ្យប្រើប្រាស់ក្រមអភិបាលកិច្ចសាជីវកម្ម<br>• លើកកម្ពស់ការយល់ដឹងអំពីក្រមអភិបាលកិច្ចសាជីវកម្ម | • តាមដានការអនុវត្តក្រមអភិបាល-កិច្ចសាជីវកម្ម<br>• បន្តលើកកម្ពស់ការយល់ដឹងអំពីក្រមអភិបាលកិច្ចសាជីវកម្ម<br>• បង្កើតវិទ្យាស្ថានបណ្តុះបណ្តាលអភិបាលសម្រាប់វិស័យមូលបត្រ និងផ្តល់ការបណ្តុះបណ្តាលដល់អភិបាល នៃក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ | • បន្តតាមដានការអនុវត្តក្រមអភិបាលកិច្ចសាជីវកម្ម<br>• គាំទ្រវិទ្យាស្ថានបណ្តុះបណ្តាលអភិបាលសម្រាប់វិស័យមូលបត្រ ដើម្បីទាក់ទាញអភិបាលនៃក្រុមហ៊ុនដែលមិនទាន់ចុះបញ្ជីលក់មូលបត្រ |
| ៤. | **អភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិទ្រព្យឌីជីថល** | • រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងទ្រព្យឌីជីថល<br>• ផ្តល់អាជ្ញាបណ្ណដល់បុគ្គលផ្តល់សេវាទ្រព្យឌីជីថល និងអន្តរការីទ្រព្យឌីជីថល | • តាមដានការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិ និងអនុលោមភាពរបស់បុគ្គលក្រោមនិយ័តកម្ម<br>• បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិគាំទ្របន្ថែមទៀត | • បន្តអនុវត្ត |
| ៥. | **បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងអាជីវកម្មហិរញ្ញប្បទានពីបុគ្គលទៅបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ** | • រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មហិរញ្ញប្បទានពីបុគ្គលទៅបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ | • តាមដានការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិ និងអនុលោមភាពរបស់បុគ្គលក្រោមនិយ័តកម្ម<br>• បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិគាំទ្របន្ថែមទៀត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • ផ្តល់អាជ្ញាបណ្ណ ដើម្បីធ្វើអាជីវកម្មហិរញ្ញប្បទានពីបុគ្គលទៅបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ | | |
| ៦. | **បង្កើតក្របខ័ណ្ឌបទ-ប្បញ្ញត្តិពាក់ព័ន្ធនឹងក្រោដហ្វាន់ឌីង** | • រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រតាមរយៈក្រោដហ្វាន់ឌីង<br>• រៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងការពង្រឹងការត្រួតពិនិត្យអន្តរការីក្រោដហ្វាន់ឌីង និងថ្នាលក្រោដហ្វាន់ឌីង | • តាមដានការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិ និងអនុលោមភាពរបស់បុគ្គលក្រោមនិយ័តកម្ម<br>• បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិគាំទ្របន្ថែមទៀត | • បន្តអនុវត្ត |
| ៧. | **បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការកាន់កាប់បន្ត ការរួមបញ្ចូលគ្នា និងការទិញយកដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ** | • រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកាន់បន្ត ការរួមបញ្ចូលគ្នា និងការទិញយកដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រ | • ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងអនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិ | |
| **❖ វិធានការយុទ្ធសាស្ត្រអភិវឌ្ឍក្របខ័ណ្ឌត្រួតពិនិត្យ** | | | | |
| ១. | **ដាក់ចេញក្របខ័ណ្ឌគ្រប់គ្រងហានិភ័យដើម្បីគ្រប់គ្រង** | • រៀបចំ និងដាក់ចេញក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យ | • តាមដានការអនុវត្ត និងឥទ្ធិពលនៃក្របខ័ណ្ឌ | • បញ្ចូលម៉ាទ្រីសនៃការគ្រប់គ្រងហានិភ័យទៅក្នុងការត្រួតពិនិត្យ |

| | | | | |
|---|---|---|---|---|
| | ប្រតិបត្តិករទីផ្សារមូលបត្រដែលទទួលបានការអនុញ្ញាត (ទីផ្សារមូលបត្រ, ទីផ្សារឌុម៉ូឌីធីអនាគត, ទីផ្សាររំលងបញ្ជរ) | | | |
| ២. | ធ្វើអន្តរកាលឆ្ពោះទៅការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ ដើម្បីគ្រប់គ្រង៖<br>• ប្រតិបត្តិករទីផ្សារមូលបត្រដែលទទួលបានការអនុញ្ញាត (ទីផ្សារមូលបត្រ,ទីផ្សារឌុម៉ូឌីធីអនាគត, ទីផ្សាររំលងបញ្ជរ)<br>• អ្នកចូលរួមក្នុងទីផ្សារ ដូចជាភ្នាក់ងារទូទាត់ | • រៀបចំយុទ្ធសាស្ត្រសម្រាប់ការធ្វើអន្តរកាលឆ្ពោះទៅជាការត្រួតពិនិត្យផ្អែកលើហានិភ័យ<br>• រៀបចំឧបករណ៍របាយការណ៍ត្រួតពិនិត្យលើឯកសារផ្អែកលើសាធនភាព ១ នាបច្ចុប្បន្ន | • រៀបចំការវាយតម្លៃការត្រួតពិនិត្យសម្រាប់ការធ្វើអន្តរកាលឆ្ពោះទៅកម្រិតសាធនភាព ២ | • អនុវត្តកម្រិតសាធនភាពដែលសមស្របទៅនឹងការវិវត្តនៃវិស័យមូលបត្រ |

| | | | | |
|---|---|---|---|---|
| | សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ, ភ្នាក់ងារបញ្ជិកាមូលបត្រ, ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ, និងភ្នាក់ងារទូទាត់, ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ | | | |
| ៣. | **ពង្រឹងការត្រួតពិនិត្យអន្តរការីមូលបត្រ** | • បង្កើត និងដាក់ចេញក្របខ័ណ្ឌសម្រាប់ការត្រួតពិនិត្យផ្អែកលើហានិភ័យនៃអន្តរការីមូលបត្រ | • តាមដានការអនុវត្ត និងកែលម្អតាមការចាំបាច់ | • ពិនិត្យឡើងវិញនូវលក្ខខណ្ឌតម្រូវជាអប្បបរមាសម្រាប់ការផ្តល់អាជ្ញាបណ្ណ/ ការអនុញ្ញាតធ្វើជាអន្តរការីមូលបត្រ |
| ៤. | **បង្កើតបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការប្រព្រឹត្តល្មើសក្នុងទីផ្សារ** | • រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រជាមួយនឹងបុគ្គលពាក់ព័ន្ធ | • អនុវត្តផែនការយុទ្ធសាស្ត្រ | |
| | | • បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិដើម្បីត្រួតពិនិត្យការចូលក្នុងទីផ្សាររបស់អ្នកផ្ទៃក្នុង ក្នុងចំណោមនីតិបុគ្គល | • ធានានូវអនុលោមភាពទៅនឹងក្របខ័ណ្ឌផែនការ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | |

| | | | | |
|---|---|---|---|---|
| | | ដែលស្ថិតក្រោមនិយ័តកម្មរបស់ **ន.ម.ក.** និងស្ថាប័នផ្សេងទៀត | | |
| | | • រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ និង គោលនយោបាយដើម្បីផ្តល់ជាក្របខ័ណ្ឌសម្រាប់ការធ្វើសកម្មភាពនៅក្នុងទីផ្សាររបស់អ្នកផ្ទៃក្នុងពិសេស ជាអាទិ៍មន្ត្រីនៃស្ថាប័នអនុវត្តច្បាប់ជាដើម | • អនុវត្តផែនការសកម្មភាព ដែលកំណត់ក្នុងគោលនយោបាយ និងបទប្បញ្ញត្តិ | |
| | | • សហការជាមួយក្រសួងយុត្តិធម៌ដើម្បីរៀបចំនីតិវិធីរួមសម្រាប់ការគ្រប់គ្រង និងការបញ្ជូនសំណុំរឿងពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ | | |
| ៩. | **រៀបចំប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានសម្រាប់ការរាយការណ៍ក្នុងទម្រង់ឌីជីថល និង ស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ** | • អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ត្រួតពិនិត្យប្រតិបត្តិការ និងអាជីវកម្មជួញដូរឧបករណ៍និស្សន្ទដំណាក់កាលទី១<br>• ទិញ និងដំឡើងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រដល់ការតាមដានលើការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ | • អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ត្រួតពិនិត្យប្រតិបត្តិការ និងអាជីវកម្មជួញដូរឧបករណ៍និស្សន្ទដំណាក់កាលទី២ | • បន្តអភិវឌ្ឍប្រព័ន្ធទាំងនេះឱ្យកាន់តែប្រសើរឡើង |

| | | | | |
|---|---|---|---|---|
| | | និងកសាងសមត្ថភាពដោយអ្នកផ្គត់ផ្គង់បច្ចេកវិទ្យាព័ត៌មាន<br>• អភិវឌ្ឍសមត្ថភាពមន្ត្រីនៃ **ន.ម.ក.** ដើម្បីតាមដាន និងស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ និងគ្រប់គ្រងការងារ | | |
| **III. ក្របខ័ណ្ឌយុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍទីផ្សារមូលបត្រ** | | | | |
| **❖ វិធានការយុទ្ធសាស្ត្រកសាងសមត្ថភាព លើកកម្ពស់ចំណេះដឹង និងអភិវឌ្ឍសមត្ថភាព** | | | | |
| ១. | **លើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ** | • រៀបចំនិងដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រដើម្បីលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ ដូចជា៖<br>➢ បង្កើតគណៈកម្មាធិការអក្ខរកម្មហិរញ្ញវត្ថុដោយមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងទីផ្សារ<br>➢ បញ្ចូលមាតិកាអំពីវិស័យមូលបត្រក្នុងកម្មវិធីសិក្សា<br>➢ បោះពុម្ព និងផ្សព្វផ្សាយឯកសារងាយស្រួលអាន (easy-to-read booklets) ពាក់ព័ន្ធនឹងមូលបត្រ | • បន្តអនុវត្តផែនការយុទ្ធសាស្ត្រ<br>• លើកទឹកចិត្តតួអង្គក្នុងវិស័យ ដើម្បីបង្កើតកម្មវិធីកម្សាន្ត និងកម្មវិធីប្រកួតប្រជែង (simulation-based applications) ដើម្បីលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ | • បន្តអនុវត្ត<br>• វាយតម្លៃប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រ និងកែសម្រួលតាមការចាំបាច់ |

| | | | | |
|---|---|---|---|---|
| | | ➢ រៀបចំកម្មវិធីប្រកួតប្រជែង "ការជួញដូរមូលបត្រ"<br>➢ រៀបចំកម្មវិធីផ្សេងៗ (សិក្ខា-សាលា, វគ្គបណ្តុះបណ្តាលខ្លីៗ) សម្រាប់ចំណេះដឹងគ្រប់កម្រិត ដោយពិចារណាលើការៀបចំមាតិកាសម្រាប់ស្ត្រីផងដែរ<br>➢ បង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល | | |
| ២. | **លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យមូលបត្រ** | • រៀបចំ ឬចូលរួមកម្មវិធីសាធារណៈ ដើម្បីផ្សព្វផ្សាយអំពីវិស័យមូលបត្រ<br>• បង្កើត ឬចាប់ដៃគូជាមួយស្ថាប័នសាធារណៈ និងឯកជន សម្រាប់យុទ្ធនាការផ្សព្វផ្សាយ<br>• សម្រួលឱ្យសាធារណជនអាចទទួលបានព័ត៌មានដោយងាយស្រួល ច្បាស់លាស់ និងទាន់ពេល<br>• ជំរុញសមាគមក្នុងទីផ្សាររៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការវិនិយោគ(ឧទាហរណ៍៖ ភ្នាក់ងារ/ | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ឈ្នួញជើងសាមូលបត្រ/ឧបករណ៍និស្សន្ទ) | | |
| ៣. | **អភិវឌ្ឍធនធានមនុស្សដែលមានជំនាញ និងបទពិសោធន៍** | • បង្កើតកិច្ចសហការរវាងភាគីពាក់ព័ន្ធ (ដូចជា និយ័តករ និងអ្នកចូលរួមក្នុងទីផ្សារ) និងស្ថាប័នអប់រំ<br>• ពិនិត្យមើលកម្មវិធីបណ្តុះបណ្តាលដែលមានបច្ចុប្បន្ន ធៀបនឹងតម្រូវការដែលមាននៅក្នុងទីផ្សារ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ | • បញ្ចូលមាតិកាអំពីវិស័យមូលបត្រទៅក្នុងកម្មវិធីសិក្សា ជាពិសេសការអប់រំក្នុងកម្រិតឧត្តមសិក្សា<br>• រៀបចំវគ្គបង្វឹកសម្រាប់សាស្ត្រាចារ្យឧត្តមសិក្សា<br>• ពិនិត្យសមិទ្ធិលទ្ធភាពធ្វើការវាយតម្លៃយេនឌ័រក្នុងវិស័យមូលបត្រដើម្បីកំណត់យុទ្ធសាស្ត្រក្នុងការទាក់ទាញ រក្សា និងលើកកម្ពស់បុគ្គលិកស្ត្រីដែលមានជំនាញក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត |
| | **បង្កើតមូលធនមនុស្សជំនាញ ក្នុងឯកទេសសំខាន់ៗ ដូចជា ហិរញ្ញវត្ថុ, ច្បាប់, គណនេយ្យ, ការវិភាគទិន្នន័យ, បច្ចេកវិទ្យា** | • សហការជាមួយភាគីពាក់ព័ន្ធដើម្បីផ្តល់ការបណ្តុះបណ្តាល និងកម្មវិធីអភិវឌ្ឍន៍ដល់បុគ្គលកំពុងបំពេញការងារក្នុងវិស័យមូលបត្រ រួមទាំងបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ទៅតាមកម្រិត និងលក្ខខណ្ឌការងារផ្សេងៗគ្នា | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | **ព័ត៌មាន និងមុខជំនាញពាក់ព័ន្ធ** | • ទាក់ទាញអ្នកជំនាញពីបរទេស ដើម្បីបំពេញជំនាញដែលកំពុងខ្វះខាត<br>• ពិចារណាផ្តល់ការលើកទឹកចិត្តដល់អ្នកដែលមានជំនាញចូលរួមក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត | • បន្តអនុវត្ត |
| ៤. | **លើកកម្ពស់ចំណេះដឹងផ្នែកមូលបត្រ និងពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលបម្រើការក្នុងវិស័យមូលបត្រ** | • សិក្សាសមិទ្ធិលទ្ធភាពក្នុងការបង្កើតវិទ្យាស្ថានជាតិមូលបត្រ<br>• រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិដើម្បីបង្កើតវិទ្យាស្ថានជាតិមូលបត្រ | • អនុម័តដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិនិងបង្កើតវិទ្យាស្ថានជាតិមូលបត្រ | |
| ៥. | **ពង្រឹងសេវាអន្តរការីមូលបត្រ** | • លើកកម្ពស់ជំនាញវិជ្ជាជីវៈចំណេះដឹងថ្មីៗ និងជំនាញទំនាក់ទំនង តាមរយៈ៖<br>➢ ការផ្តល់ការបណ្តុះបណ្តាលសម-ស្រប លើជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់បុគ្គលិកអន្តរការីមូលបត្រ<br>➢ ការផ្តល់ជូនបុគ្គលិកនូវមធ្យោ-បាយសមស្រប ដើម្បីទទួលបាននូវព័ត៌មានថ្មីៗដែលពាក់ព័ន្ធ | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ➢ ការចែករំលែកបទពិសោធន៍ពីឧត្តមានុវត្តន៍អន្តរជាតិតាមរយៈកម្មវិធីសន្និសីទ សិក្ខាសាលាជាដើម<br>• អនុវត្តអភិក្រមផ្ដោតលើតម្រូវការអតិថិជនក្នុងការផ្ដល់អនុសាសន៍ និងសេវាប្រឹក្សានានា<br>• ជំរុញអន្តរការីមូលបត្រឱ្យមានការផ្ដល់សេវាបន្ថែមតាមតម្រូវការជាក់ស្ដែង | | |

| | | | | |
|---|---|---|---|---|
| ❖ វិធានការយុទ្ធសាស្ត្រគ្រប់គ្រង និងវិភាគទិន្នន័យ | | | | |
| ១. | **រៀបចំយុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ ក្នុងការរៀបចំផែនការ និងគាំទ្រការអភិវឌ្ឍវិស័យមូលបត្ររយៈពេលវែងប្រកបដោយចីរភាព** | • កំណត់ប្រភេទទិន្នន័យដែលត្រូវប្រមូល<br>• បង្កើតវិធីសាស្ត្រនៃការប្រមូល និងការផ្ទុកទិន្នន័យប្រកបដោយប្រសិទ្ធភាព ដោយ៖<br>➢ វាយតម្លៃសមត្ថភាពផ្ទៃក្នុង និងជំនាញដែលត្រូវការពង្រឹងបន្ថែម<br>➢ ដាក់ចេញកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី<br>➢ ប្រឹក្សាជាមួយអ្នកជំនាញការ | • ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យជាប្រចាំ<br>• ធ្វើបច្ចុប្បន្នកម្មកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • រៀបចំ និងដាក់ចេញគោលការណ៍ណែនាំ ស្តីពីការប្រើប្រាស់ទិន្នផលដែលទទួលបានពីការវិភាគទិន្នន័យ | • ចែករំលែកទិន្នផលដែលទទួលបានពីការវិភាគទិន្នន័យជាមួយតួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ<br>• ដាក់ចេញនូវ គំនិតផ្តួចផ្តើមដាក់លាក់សម្រាប់អភិវឌ្ឍផ្នែកផ្សេងៗនៃទីផ្សារ | • បន្តអនុវត្ត |
| ២. | **បង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យក្នុងវិស័យមូលបត្រ** | • បង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធមូលដ្ឋានទិន្នន័យក្នុងវិស័យមូលបត្រ | • ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធមូលដ្ឋានទិន្នន័យក្នុងវិស័យមូលបត្រ | • បន្តអនុវត្ត |
| ❖ វិធានការយុទ្ធសាស្ត្រសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងចែករំលែកធនធាន | | | | |
| ១. | **ដាក់ចេញយន្តការនៃការសម្របសម្រួលជាមួយស្ថាប័នដែលពាក់ព័ន្ធ** | • រៀបចំ និងកំណត់ផ្នែកសម្រាប់ការសម្របសម្រួល និងស្ថាប័នដែលត្រូវចូលរួម<br>• កំណត់លក្ខខណ្ឌនៃការសម្របសម្រួល រួមមានតួនាទី និងការទទួលខុសត្រូវ<br>• រៀបចំ និងដាក់ចេញនូវយន្តការនៃការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ តាមរយៈ៖ | • ត្រួតពិនិត្យជាប្រចាំនូវការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការផ្សេងៗ និងរៀបចំឡើងវិញតាមការចាំបាច់ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | ➢ ការចុះអនុស្សរណៈនៃការយោគ-យល់គ្នាជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗ ឬការបង្កើតក្រុមការងារ<br>➢ ការដាក់ចេញនូវយន្តការនៃការអនុវត្តអនុស្សរណៈនៃការយោគ-យល់គ្នា និងការបង្កើតក្រុមការងារតាមការចាំបាច់<br>➢ ការដាក់ចេញរបាយការណ៍វឌ្ឍន-ភាព និងសមិទ្ធផលនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា | | |
| ២. | **បង្កើតភាពជាដៃគូ និងការសហការជាមួយនិយ័តករ និងតួអង្គពាក់ព័ន្ធ** | • សហការ បង្កើតគំនិតផ្តួចផ្តើមរួមទាំងកម្មវិធីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង, វគ្គបណ្តុះបណ្តាល, ការស្រាវជ្រាវ និងកម្មវិធីអភិវឌ្ឍន៍ និងនិយ័តកម្មផ្សេងទៀត ដែលឆ្លើយតបនឹងតម្រូវការ | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | | • បង្កើតបណ្តាញទំនាក់ទំនងដើម្បីសម្រួលដល់ការចែករំលែកព័ត៌មានលើបញ្ហាដែលអាចប៉ះពាល់ដល់ទំនុកចិត្តទីផ្សារ | | |
| ❖ វិធានការយុទ្ធសាស្ត្រពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ | | | | |
| ១. | **ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយទីផ្សារក្នុងយុត្តាធិការផ្សេងៗ** | • ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន និងនិយ័តករបរទេសដោយ៖<br>➢ កំណត់ទីផ្សារ និងយុត្តាធិការ ក៏ដូចជាផ្នែកអភិវឌ្ឍ និងផ្នែកនិយ័ត-កម្មសម្រាប់កិច្ចសហប្រតិបត្តិការ<br>➢ ផ្តល់អាទិភាពដល់ផ្នែកថ្មីៗសម្រាប់កិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍ ជាពិសេសផ្នែកហិរញ្ញវត្ថុចីរភាព និងបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>➢ បង្កើតយន្តការនៃការអនុវត្តកិច្ច-សហប្រតិបត្តិការ ដើម្បីធានាបាននូវផលប្រយោជន៍ទៅវិញទៅមក | • បន្តអនុវត្ត | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| ២. | **លើកកម្ពស់កិច្ចសហ-ប្រតិបត្តិការអាស៊ាន** | • ពង្រឹងកិច្ចសហប្រតិបត្តិការដែលមានស្រាប់ និងកំណត់ផ្នែកថ្មីៗសម្រាប់កិច្ចសហការ<br>• ពង្រីកគំនិតផ្តួចផ្តើមកសាងសមត្ថភាព និងលើកកម្ពស់ការចែករំលែកបទពិសោធន៍ និងចំណេះដឹង<br>• ក្លាយជាសមាជិកសកម្មនៃក្រុមការងារ និងគណៈកម្មាធិការពាក់ព័ន្ធអាស៊ាន | • បន្តអនុវត្ត | • បន្តអនុវត្ត |
| ៣. | **ពង្រីកខ្លួនលើវេទិកាអន្តរជាតិផ្សេងទៀត** | • ចូលរួមក្នុងកម្មវិធីដែលរៀបចំដោយ IOSCO ជាពិសេសតាមរយៈ មជ្ឈមណ្ឌល IOSCO អាស៊ីប៉ាស៊ីហ្វិក<br>• អភិវឌ្ឍ និងលើកកម្ពស់ទំនាក់ទំនង និងបណ្តាញទំនាក់ទំនងជាមួយស្ថាប័នពហុភាគី និងភាគីពាក់ព័ន្ធអន្តរជាតិដទៃទៀត<br>• បន្តនីតិវិធីចូលជាសមាជិកពេញសិទ្ធិនៃIOSCO | • បន្តអនុវត្ត | • បន្តអនុវត្ត |

| ❖ វិធានការយុទ្ធសាស្ត្រពង្រឹង និងពង្រីកសមត្ថភាពនៃការអនុវត្ត | | | | |
|---|---|---|---|---|
| **១.** | **អភិវឌ្ឍសមត្ថភាពមន្ត្រី ន.ម.ក.** | • បន្ត និងពង្រីកកម្មវិធីចុះហ្វឹកហាត់ការងារដល់ទីកន្លែងដល់មន្ត្រីជាមួយនិយ័តករក្នុង និងក្រៅតំបន់ | • បន្តអនុវត្ត | • បន្តអនុវត្ត |
| | | • លើកទឹកចិត្ត និងចូលរួមក្នុងការបង្កើតសមាគមនៃអ្នកចូលរួមទីផ្សារ<br>• រៀបចំឱ្យមានកិច្ចប្រជុំ សន្និសីទឬសិក្ខាសាលារួម រវាង **ន.ម.ក.** និងអ្នកចូលរួមទីផ្សារ | • បន្តអនុវត្ត | • បន្តអនុវត្ត |
| **២.** | **ពង្រឹងសមត្ថភាពត្រួតពិនិត្យ និងវាយតម្លៃ** | • បង្កើតក្រុមខ័ណ្ឌស្ដីពីយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ, សេចក្ដីណែនាំ, គំនិតផ្ដួចផ្ដើមជាយុទ្ធសាស្ត្រជាដើម ដែលដាក់ចេញ ឬអនុវត្តដោយ **ន.ម.ក.**<br>• ផ្ដល់ការបណ្ដុះបណ្ដាលសម្រាប់មន្ត្រី **ន.ម.ក.** ដែលពាក់ព័ន្ធ | • ពិនិត្យមើលប្រសិទ្ធភាពនៃក្របខ័ណ្ឌ និងសមត្ថភាពមន្ត្រីសម្រាប់ការពង្រឹងបន្ថែមជាសក្ដានុពល | • បន្តអនុវត្ត |
| **៣.** | **ពង្រឹងប្រព័ន្ធផ្ទៃក្នុង ន.ម.ក. ដើម្បីគាំទ្រ និងគ្រប់គ្រងដំណើរ-** | • វិភាគដំណើរការប្រតិបត្តិការការងាររបស់ **ន.ម.ក.** | • អភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធសម្រាប់ដំណើរការស្វ័យប្រវត្តិកម្មតាមលំដាប់អាទិភាពអនុវត្តផែនការ | • បន្តអនុវត្ត |

| | | | | |
|---|---|---|---|---|
| | **ការស្វ័យប្រវត្តិកម្ម** | • បង្កើតបញ្ជីអាទិភាពនៃដំណើរការផ្ទៃក្នុង ដើម្បីធ្វើស្វ័យប្រវត្តិកម្ម<br>• កំណត់វិសាលភាព និងតម្រូវការសម្រាប់ប្រព័ន្ធ RegTech និងបង្កើតផែនការដើម្បីអនុវត្ត | និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី | |

និយ័តករមូលបត្រកម្ពុជា

SECURITIES AND EXCHANGE REGULATOR OF CAMBODIA

**ជំរុញការអភិវឌ្ឍវិស័យមូលបត្រ**
**ប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ជវភាព បរិយាបន្ន និរន្តរភាព និងនវានុវត្តន៍**
**សំដៅចូលរួមលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងបរិបទប្រក្រតីភាពថ្មី**

Telegram Channel | SERC Alert Channel | Facebook Page | LinkedIn | YouTube Channel | Website


(855)23 885 611

(855)23 885 622

INFO@SERC.GOV.KH

WWW.SERC.GOV.KH

WWW.FACEBOOK.COM/SERC.GOV.KH

អគារ ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ